សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

**របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា**

# ការគ្រប់គ្រងភតិសន្យាហិរញ្ញវត្ថុ

ស្រាវជ្រាវ ពីថ្ងៃទី ០២ ខែ មេសា ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៨

ឈ្មោះស្ថាប័ន៖ **ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ មេហ្គា លីស៊ីង ភីអិលស៊ីសាខាភ្នំពេញ**

ស្រាវជ្រាវដោយ៖ | សាស្ត្រាចារ្យណែនាំ៖
---|---
និស្សិតឈ្មោះ **ចាន់ វៀក** | លោក **ជា សែម**
ថ្នាក់បរិញ្ញាបត្រធនាគារ និងហិរញ្ញវត្ថុ | ឆ្នាំចូលសិក្សា **២០១៤**
ជំនាន់ទី **១១** | ឆ្នាំសរសេររបាយការណ៍ **២០១៨**

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទ ឈ្មោះ ចាន់ ជៀក ភេទ ប្រុស ជានិស្សិត បរិញ្ញាបត្រ ធនាគារ និងហិរញ្ញវត្ថុ ជំនាន់ទី ១១ ឆ្នាំទី៤ ថ្នាក់បរិញ្ញាបត្រ ធនាគារ និងហិរញ្ញវត្ថុ នៃសាកលវិទ្យាល័យ ភូមិន្ទ និតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានចុះកម្មសិក្សានៅក្រុមហ៊ុន ភិតិសន្យាហិរញ្ញវត្ថុមេហ្គាលីស៊ីង ភីអិលស៊ីង សាខាភ្នំពេញ លើប្រធានបទស្តីពី ការគ្រប់គ្រង ភតិសន្យាហិរញ្ញវត្ថុ ។

## សូមគោរព ថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ

លោកឪពុក អ្នកម្តាយ របស់ខ្ញុំទាំងពីររូប ដែលបានផ្តល់កំណើតដល់ខ្ញុំ ព្រមទាំងចិញ្ចឹមបី បាច់ថែរក្សាខ្ញុំតាំងពីរតូចដល់ធំ នៅក្នុងសង្គមគ្រួសារមួយដែលពោពេញដោយសុភមង្គល ។ ជាពិសេសលោកទាំងពីរ ថែមទាំងបានអប់រំទូន្មានប្រៀនប្រដៅ អោយខ្ញុំបាទក្លាយជាកូនល្អ ពលរដ្ឋល្អមួយរូបនៅក្នុងសង្គម ។មិនតែប៉ុណ្ណោះលោកទាំងពីរថែមទាំងបាន បំពេញការងារជាច្រើន ដើម្បីប្តូរនូវថវិកាមួយចំនួនសម្រាប់ ផ្គត់ផ្គង់អោយខ្ញុំបាទ បានចូលរៀនតាំងពីថ្នាក់ បឋមសិក្សា រហូតដល់ថ្នាក់បរិញ្ញបត្រ នាពេលបច្ចុប្បន្ននេះ។ ទាំងនេះ ជាមហាករុណាគុណ ដ៏ធំធេងសម្រាប់ខ្ញុំបាទ ដែលមិនអាចយកអ្វីមកប្រៀបប្រដូចស្មើនឹង អ្វីៗ ដែលលោកទាំងពីរបានធ្វើសម្រាប់ខ្ញុំបាទ ។

ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង និង សាស្ត្រាចារ្យទាំងអស់ នៃសាកលវិទ្យាល័យភូមិន្ទ និតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានជ្រោមជ្រែង និងបង្ហាត់បង្ហាញឲ្យខ្ញុំបាទទទួលបាននូវ ចំណេះដឹង និង ជំនាញច្បាស់លាស់ ដែលជាធនធានដ៏សំខាន់មួយ ដើម្បីប្រលូកក្នុងវិស័យការងារ នាពេលបច្ចុប្បន្ននេះ ។ ជាពិសេស ខ្ញុំបាទសូមគោរព និងថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ សាស្ត្រាចារ្យ ជា សែម ដែលបានចំណាយពេលដ៏មានតម្លៃ សម្រាប់ខ្ញុំបាទ ក្នុងការបង្ហាត់បង្ហាញ ណែនាំក្នុងការសរសេររបាយការណ៍ កម្មសិក្សានេះព្រមទាំង ព្រមទាំងបានផ្តល់ឯកសារមួយចំនួន ដែលទាក់ទងនឹងប្រធានបទនេះ ។ លើសពីនេះទៀត លោកសាស្ត្រាចារ្យបានផ្តល់គំនិត យោបល់ល្អៗ និងជួយកែលំអរសារណាបញ្ចប់ការសិក្សា មួយនេះអោយសម្រេចបានជោគជ័យជាស្ថាពរ ។

ប្រធានគណៈគ្រប់គ្រង និងមន្ត្រី បុគ្គលិកគ្រប់ជាន់ថ្នាក់ នៃក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុមេហ្គាលីស៊ីង ភីអិលស៊ី ដែលបាន ផ្តល់ឪកាសអោយខ្ញុំបាទ បានចុះកម្មសិក្សា និងចូលរួមសហការ យ៉ាងសកម្មជាមួយខ្ញុំបាទ ក្នុងការផ្តល់ ឯកសារ និងការអនុវត្តន៍ការងារជាក់ស្តែង ដើម្បីសរសេរចងក្រងជារបាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សាមួយនេះដោយជោគជ័យ ។ព្រមទាំងមិត្តភក្តិទាំងអស់

ដែលបានជួយផ្តល់យោបល់ និងបានធ្វើការពិគ្រោះសម្រាប់ការស្រាវជ្រាវរបស់ខ្ញុំបាទ ។

ជាចុងក្រោយខ្ញុំបាទ សូមគោរពជូនពរ ចំពោះលោកឪពុក អ្នកម្តាយ សាកលវិទ្យាធិការ សាកលវិទ្យាធិការរង លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យទាំងអស់ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជាពិសេស សាស្ត្រាចារ្យ ជា សែម គណៈគ្រប់គ្រង និងបុគ្គលិកទាំងអស់របស់ នៃក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុមេហ្គាលីស៊ីង ភីអិលស៊ី ព្រមទាំងមិត្តភក្តិ ទាំងអស់ សូមអោយជួបប្រទះតែសេចក្តីសុខសុភមង្គល និងភាពរីកចំរើន ទាំងក្នុងសង្គមការងារ និងសង្គមគ្រួសារ ។

# អារម្ភកថា

ខ្ញុំបាទ បានធ្វើការសិក្សាស្រាវជ្រាវចងក្រង ជារបាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សាលើប្រធានបទស្តីពី ការគ្រប់គ្រង ភតិសន្យាហិរញ្ញវត្ថុ នៅក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុមេហ្គាលីស៊ីង ភីអិលស៊ី អស់រយៈពេលជាច្រើនខែកន្លងមក ។ វាជាស្នាដៃរបស់ខ្ញុំ សម្រាប់ការបញ្ចប់ការ សិក្សាថ្នាក់បរិញ្ញាបត្រ ដែលបានសិក្សាអស់រយៈពេលបួនឆ្នាំកន្លងមកនេះ ។

របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សានេះ ត្រូវបានរៀបចំឡើងស្របពេល នៃការរីកចម្រើននូវ វិស័យសេដ្ឋកិច្ច ជាពិសេសការរីកចម្រើនលើវិស័យហិរញ្ញវត្ថុនៅ ប្រទេសកម្ពុជានាឆ្នាំ ២០១៨ ដែលបង្កើតអោយមាន ស្ថានប័នធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងក្រុមហ៊ុន ហិរញ្ញវត្ថុជាច្រើន ។ ឆ្លងតាមរយៈរបាយការណ៍បញ្ចប់ការសិក្សានេះ នឹងជួយអោយអ្នកបានយល់ពីការវិវត្តន៍ របស់ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ មេហ្គាលីស៊ីង ជាពិសេសនឹងជួយអោយអ្នកយល់ពីដំណើរការ នៃការគ្រប់គ្រង ភតិសន្យាហិរញ្ញវត្ថុ ផ្ទាល់តែម្តង ។ អ្នកនឹងយល់ពី សារៈសំខាន់ នៃវិស័យភតិសន្យាហិរញ្ញវត្ថុ នៅក្នុងសេដ្ឋកិច្ច ជាពិសេស អ្នកនឹងយល់ពីវិធីសាស្ត្រ នៃការគ្រប់គ្រងភតិសន្យាហិរញ្ញវត្ថុ អោយមានប្រសិទ្ធិភាព និងទទួលបាននូវភាពជោគជ័យ ។ ហេតុដូចនេះ យើងខ្ញុំសង្ឃឹមថា របាយការណ៍បញ្ចប់ការសិក្សានេះ នឹងមានសារៈប្រយោជន៍ ចំពោះអ្នកអានគ្រប់ៗរូប និងអ្នកចង់ធ្វើការសិក្សាស្រាវជ្រាវដើម្បីបំពេញបន្ថែម ឬអ្នកស្រាវជ្រាវ ពីប្រធានបទផ្សេងៗ ដែលមានការពាក់ពន្ធ័ នឹងរបាយការណ៍កម្មសិក្សា ឬដើម្បីស្វែងយល់ពីវិស័យភតិសន្យាហិរញ្ញវត្ថុ និងទុកជាឯកសារសម្រាប់ ប្អូនៗជំនាន់ក្រោយ ៗ ។

បើទោះបីជាមានការត្រួតពិនិត្យ និងកែសម្រួលជាច្រើនលើកក៏ដោយ ក៏ខ្ញុំបាទប្រាកដថា នៅតែមានចំនុចខ្វះចន្លោះណាមួយជាក់ជាពុំខានឡើយ ។ ដូច្នេះហើយខ្ញុំបាទ សូមអភ័យទោសទុកជាមុន នូវរាល់កំហុសឆ្គងដែលកើតមានឡើង ដោយអចេតនា ហើយខ្ញុំបាទ នឹងរង់ចាំទទួលនូវការរិះគន់ ដើម្បីកែលំអរ និងទទួលយកនូវទស្សនៈថ្មីៗ ដោយក្តីសោមនស្ស ។

ជាចុងក្រោយ ខ្ញុំបាទ សូមថ្លែងអំណរគុណ ដល់អ្នកអានទាំងអស់ និងសូមអោយមិត្តអ្នកអានទាំងអស់ជួបតែសេចក្តីសុខ សិរីសួស្តី និងជោគជ័យគ្រប់ភារកិច្ច ។

សូមអរគុណ!

# មាតិកា


បញ្ជីអក្សរកាត់ ........ ix
បញ្ជីរូប ........ x
បញ្ជីតារាង ........ xi
បញ្ជីដ្យាក្រាម ........ xii
បញ្ជីឧបសម្ព័ន្ធ ........ xii


# សេចក្តីផ្តើម


១. លំនាំបញ្ហា ........ ១
២. ចំណោទបញ្ហា ........ ១
៣. គោលបំណង នៃការស្រាវជ្រាវ ........ ២
៤. វិធីសាស្រ្ត នៃការស្រាវជ្រាវ ........ ២
៥. គម្រោង នៃការស្រាវជ្រាវ ........ ៣
៦. សារៈសំខាន់ នៃការស្រាវជ្រាវ ........ ៣
៧. ទំហំនិងដែនកំណត់ នៃការស្រាវជ្រាវ ........ ៤


# ជំពូកទី ១ រំលឹកទ្រឹស្តី


១.១. ទិដ្ឋភាពទូទៅ នៃសេដ្ឋកិច្ចកម្ពុជា ........ ៥
១.២. ទិដ្ឋភាពទូទៅ នៃវិស័យភតិសន្យាហិរញ្ញវត្ថុ នៅកម្ពុជា ........ ៦
  ១.២.១.និយមន័យ នៃភតិសន្យាហិរញ្ញវត្ថុ ........ ៦
  ១.២.២. ប្រវត្តិ នៃវិស័យភតិសន្យាហិរញ្ញវត្ថុ នៅកម្ពុជា ........ ៧
១.៣. សេវាកម្ម និងផលិតផល ភតិសន្យាហិរញ្ញវត្ថុ ........ ៨
  ១.៣.១. ភតិសន្យាហិរញ្ញវត្ថុ លើទោចក្រយានយន្ត ........ ៨
  ១.៣.២. ភតិសន្យាហិរញ្ញវត្ថុ លើរថយន្ត ........ ៨
  ១.៣.៣. ភតិសន្យាហិរញ្ញវត្ថុ លើគ្រឿងចក្រ ........ ៨
  ១.៣.៤. ភតិសន្យាហិរញ្ញវត្ថុ លើគ្រឿងអេឡិចត្រូនិច ........ ៨
  ១.៣.៥. ភតិសន្យាហិរញ្ញវត្ថុ លើគ្រឿងសង្ហារឹម ........ ៩
១.៤. តួនាទី និងមុខងារភតិសន្យាហិរញ្ញវត្ថុ ........ ៩
  ១.៤.១. ចំពោះភតិកៈ ........ ៩
  ១.៤.២. ចំពោះភតិបតី ........ ៩

១.៤.៣. ចំពោះសេដ្ឋកិច្ច ........................................................ ៩
១.៥. ប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុ ........................................................ ១០
១.៦. ការគ្រប់គ្រងភតិសន្យាហិរញ្ញវត្ថុ ........................................................ ១០
១.៦.១. គោលបំណង ........................................................ ១០
១.៦.២. ការលក់ និងទីផ្សារ ........................................................ ១១
១.៦.៣. នីតិវិធី នៃការផ្តល់ភតិសន្យាហិរញ្ញវត្ថុ ........................................................ ១១
១.៦.៣.១. ការត្រួតពិនិត្យ សំណើរលើកដំបូង ........................................................ ១១
១.៦.៣.២. ការស៊ើបអង្កេតឥណទាន ........................................................ ១២
១.៦.៣.៣. ការសម្រេចចិត្ត ........................................................ ១៣
១.៦.៤. ការគ្រប់គ្រងប្រព័ន្ធទារប្រមូល ប្រាក់ឈ្នួល ........................................................ ១៣
១.៦.៤.១. គោលដៅ នៃប្រព័ន្ធទារប្រមូល ........................................................ ១៤
១.៦.៤.២. មូលហេតុដែលអតិថិជនបង់សងប្រាក់ឈ្នួលយឺត ........................................................ ១៤
១.៦.៥. ការកំណត់ប្រភេទអតិថិជន ........................................................ ១៥
១.៦.៦. ការកំណត់ចំណាត់ថ្នាក់ឥណទាន និងធ្វើសំវិធានធនឥណទាន ........................................................ ១៦
១.៦.៦.១.ការកំណត់ចំណាត់ថ្នាក់ឥណទាន ........................................................ ១៦
១.៦.៦.២. ការធ្វើសំវិធានធនឥណទាន ........................................................ ១៧
១.៧. ហានិភ័យ របស់ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ ........................................................ ១៧
១.៧.១. ហានិភ័យឥណទាន ឬសមភាគី ........................................................ ១៨
១.៧.២. ហានិភ័យទីផ្សារ ........................................................ ១៨
១.៧.៣. ហានិភ័យ អត្រាការប្រាក់ ........................................................ ១៨
១.៧.៤. ហានិភ័យប្រតិបត្តិការ ........................................................ ១៩
១.៧.៥. ហានិភ័យគតិយុត្ត ........................................................ ១៩
១.៧.៦. ហានិភ័យ សន្ទនីយភាព ........................................................ ១៩
១.៧.៧. ហានិភ័យឯកសារ ........................................................ ១៩
១.៧.៨. ហានិភ័យប្រមូលផ្តុំ ........................................................ ១៩
**ជំពូកទី ២ ស្ថានភាពទូទៅ នៃក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ មេហ្គាលីស៊ីង ភីអិលស៊ី**
២.១. ទិដ្ឋភាពទូទៅ នៃក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុមេហ្គាលីស៊ីង ភីអីលស៊ី ........................................................ ២០
២.២. ចក្ខុវិស័យ បេសកកម្ម និងតម្លៃស្នូល ........................................................ ២១

២.២.១. ចក្ខុវិស័យ ........ ២១
២.២.២. បេសកកម្ម ........ ២១
២.២.៣. តម្លៃស្នូល ........ ២១
២.៣. អត្តសញ្ញាណរបស់ក្រុមហ៊ុន ........ ២១
២.៣.១. ផ្លាកសញ្ញា និងនាមករណ៍ ........ ២១
២.៣.២.រូបសញ្ញា ........ ២២
២.៣.៣. អត្ថន័យ ........ ២២
២.៤. រចនាសម្ព័ន្ធ ........ ២២
២.៥. តួនាទី និងភារកិច្ច នៃផ្នែកនិមួយៗ ........ ២២
២.៥.១. ប្រធានសាខា ........ ២៣
២.៥.២. ប្រធានមន្រ្តីឥណទាន ........ ២៣
២.៥.៣. មន្រ្តីឥណទាន ........ ២៣
២.៥.៤. គណនេយ្យករ ........ ២៣
២.៥.៥. បេឡាករ និងហិរញ្ញិក ........ ២៤
២.៦. តំបន់ប្រតិបត្តិការសាខាភ្នំពេញ ........ ២៤
២.៦.១. ទីតាំងសាខាភ្នំពេញ ........ ២៤
២.៦.២. ទីតាំងអនុសាខាគីរីរម្យ ........ ២៥
២.៦.៣. ទីតាំងអនុសាខាតាខ្មៅ ........ ២៥
២.៦.៤. ទីតាំងអនុសាខាខ្សាច់កណ្តាល ........ ២៦
២.៦.៥. ទីតាំងអនុសាខាបែកចាន ........ ២៦
២.៧. ផលិតផល និងសេវាកម្ម ........ ២៧
២.៧.១. ភតិសន្យាហិរញ្ញវត្ថុលើ រថយន្តទេសចរណ៍ ........ ២៧
២.៧.២. ភតិសន្យាហិរញ្ញវត្ថុលើ រថយន្តដឹកទំនិញ ........ ២៨
២.៧.៣. ភតិសន្យាហិរញ្ញវត្ថុលើ ទោចក្រយានយន្ត ........ ២៨
**ជំពូកទី ៣ គ្រប់គ្រងភតិសន្យាហិរញ្ញវត្ថុ របស់ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ មេហ្គាលីស៊ីង សាខាភ្នំពេញ**
៣.១. ការកំណត់ គោលនយោបាយភតិសន្យាហិរញ្ញវត្ថុ ........ ២៩
៣.១.១. ភតិសន្យាហិរញ្ញវត្ថុលើ រថយន្តទេសចរណ៍ ........ ២៩

៣.១.២. ភតិសន្យាហិរញ្ញវត្ថុលើ រថយន្តដឹកទំនិញ ........................................................ ២៩
៣.១.៣. ភតិសន្យាហិរញ្ញវត្ថុលើ ទោចក្រយានយន្ត.................................................... ៣០
៣.១.៤. ការជ្រើសរើសអតិថិជន ............................................................................ ៣០
៣.១.៥. ការកំណត់សាច់ប្រាក់បដិភាគ..................................................................... ៣១
៣.១.៦. ការកំណត់សមត្ថភាពបង់សង...................................................................... ៣១
៣.២. ការផ្សព្វផ្សាយ........................................................................................... ៣២
៣.២.១. មុនពេលផ្សព្វផ្សាយ ................................................................................ ៣៣
៣.២.២. ក្នុងពេលផ្សព្វផ្សាយ ................................................................................ ៣៣
៣.២.៣. ក្រោយពេលផ្សព្វផ្សាយ ............................................................................ ៣៤
៣.៣. ការវិភាគ និងវាយតម្លៃភតិសន្យាហិរញ្ញវត្ថុ........................................................... ៣៤
៣.៣.១. ការប្រមូលពត៌មាន .................................................................................. ៣៤
៣.៣.២. ការសិក្សា វិភាគ និងវាយតម្លៃអតិថិជន......................................................... ៣៥
៣.៣.២.១. ការវិភាគលើអត្តចរិក............................................................................. ៣៥
៣.៣.២.២. ការវិភាគលើ ស្ថានភាពរសនៅ.................................................................. ៣៦
៣.៣.២.៣. ការវិភាគលើ សមត្ថភាពសង់បំណុល.......................................................... ៣៦
៣.៣.២.៤. ការវិភាគលើ លក្ខខណ្ឌផ្សេងៗ................................................................... ៣៧
៣.៤. ការកំណត់សិទ្ធិក្នុងការអនុម័តភតិសន្យាហិរញ្ញវត្ថុ ................................................. ៣៧
៣.៥. នីតិវិធី ក្នុងការផ្តល់ភតិសន្យាហិរញ្ញវត្ថុ ............................................................... ៣៨
៣.៥.១. ការដាក់ពាក្យស្នើសុំ.................................................................................. ៣៨
៣.៥.២. ការចុះអង្កេតដល់ទីកន្លែង............................................................................ ៣៨
៣.៥.៣. ការអនុម័តផ្តល់សេវាភតិសន្យាហិរញ្ញវត្ថុ........................................................ ៣៩
៣.៥.៤. ការចុះឈ្មោះអតិថិជនទៅក្នុងប្រព័ន្ធ............................................................. ៣៩
៣.៥.៥. ការរក្សាទុកឯកសារ................................................................................... ៣៩
៣.៦. ការគ្រប់គ្រងប្រាក់ឈ្នួល................................................................................ ៤០
៣.៦.១. វិធីសាស្ត្រ បង់សង ................................................................................... ៤០
៣.៦.២. ការទារប្រមូលប្រាក់ ................................................................................. ៤៣
៣.៧. ការដោះស្រាយភតិសន្យាហិរញ្ញវត្ថុដែលមានបញ្ហា................................................. ៤៤
៣.៧.១. គោលបំណងនៃការដោះស្រាយ..................................................................... ៤៤

៣.៧.២. នីតិវិធី នៃការដោះស្រាយអតិថិជនមានបញ្ហា ........ ៤៥

## ជំពូកទី ៤ ការវិភាគទិន្នន័យ នៃប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុ

៤.១. កម្មវត្ថុ នៃការវិភាគទិន្នន័យ ........ ៤៨
៤.២. ការវិភាគទិន្នន័យភតិសន្យាហិរញ្ញវត្ថុ ........ ៤៨
៤.២.១. រថយន្តទេសចរណ៍ ........ ៤៨
៤.២.២. ទោចក្រយានយន្ត ........ ៤៩
៤.២.៣. រថយន្តដឹកទំនិញ ........ ៥១
៤.៣. ការវិភាគទិន្នន័យរួម ........ ៥២
៤.៤. ការវិភាគ SWOT ........ ៥៣
៤.៤.១. ចំណុចខ្លាំង ........ ៥៤
៤.៤.២. ចំណុចខ្សោយ ........ ៥៤
៤.៤.៣. ឱកាស ........ ៥៤
៤.៤.៤. ការគំរាមកំហែង ........ ៥៥

## សេចក្ដីសន្និដ្ឋាន និងអនុសាសន៍

១. សេចក្ដីសន្និដ្ឋាន ........ ៥៦
២. អនុសាសន៍ ........ ៥៧
៣. ឯកសារយោង ........ ៥៨

## បញ្ជីអក្សរកាត់

- CO : Credit Officer : មន្ត្រីឥណទាន
- CCO: Chief of Credit Officer: ប្រធានមន្ត្រីឥណទាន
- BM : Branch Manager : ប្រធានសាខា
- SLR : Senior of Lease recovery: មន្ត្រីស្តារបំណុល ជាន់ខ្ពស់
- T : Truck: រថយន្តដឹកទំនិញ
- C : Car : រថយន្តទេសចរណ៍
- M : Motorbike : ទោចក្រយានយន្ត
- LAF: Lease Application Form: ពាក្យស្នើសុំភតិសន្យាហិរញ្ញវត្ថុ
- LC : Lease Contract: កិច្ចសន្យាភតិសន្យាហិរញ្ញវត្ថុ
- CU : Customer : អតិថិជន

# បញ្ជីរូបភាព

រូបទី១ .................................................................................................... ១០
រូបទី២ .................................................................................................... ២៥
រូបទី៣ .................................................................................................... ២៥
រូបទី៤ .................................................................................................... ២៦
រូបទី៥ .................................................................................................... ២៧

# បញ្ជីតារាង

តារាងទី១ ........................................................................................................ ៤៣
តារាងទី២ ........................................................................................................ ៤៨
តារាងទី៣ ........................................................................................................ ៥០
តារាងទី៤ ........................................................................................................ ៥១
តារាងទី៥ ........................................................................................................ ៥២

# បញ្ជីដ្យាក្រាម

ដ្យាក្រាមទី១ .......... ៤៩
ដ្យាក្រាមទី២ .......... ៥០
ដ្យាក្រាមទី៣ .......... ៥១
ដ្យាក្រាមទី៤ .......... ៥៣

## បញ្ជីឧបសម្ព័ន្ធ

១. ទម្រង់ឯកសារភតិសន្យាហិរញ្ញវត្ថុលើ រថយន្តទេសចរណ៍( Lease file for Car )

២. ទម្រង់ឯកសារភតិសន្យាហិរញ្ញវត្ថុលើ ទោចក្រយានយន្ត( Lease file for Vehicle )

៣. ទម្រង់ឯកសារភតិសន្យាហិរញ្ញវត្ថុលើ រថយន្តដឹកទំនិញ( Lease file for Truct )

៤. ប្រកាសស្តីពី ចំណាត់ថ្នាក់ និងសំវិធានធនលើឥណទាន

# សេចក្តីផ្តើម

## ១. លំនាំដើម

ចាប់តាំងពីទសវត្សឆ្នាំ ៩០ មក រាជរដ្ឋាភិបាលកម្ពុជា បានខិតខំយ៉ាងខ្លាំង ក្នុងការស្តារ និង អភិវឌ្ឍសេដ្ឋកិច្ចកម្ពុជាអោយមានភាពរីកចម្រើនឡើងវិញ។ ហើយក្នុងនោះផងដែររដ្ឋាភិបាល ក៏ បានអនុវត្តនូវនិន្នាកាសេដ្ឋកិច្ចទីផ្សារសេរី ក្នុងគោលបំណងបើកអោយទូលំទូលាយ និងទាក់ទាញ វិនិយោគិន ជាតិ និងអន្តរជាតិអោយមកបណ្តាក់ទុន វិនិយោគ នៅប្រទេសកម្ពុជា លើគ្រប់វិស័យ ។ ហើយជាលទ្ធផលយើងឃើញថា ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជាពីទសវត្សឆ្នាំ ៩០ មក ដល់បច្ចុប្បន្ននេះសេដ្ឋកិច្ចកម្ពុជាមានការរីកចម្រើន គួរអោយកត់សម្គាល់ ជាពិសេសគឺ វិស័យ ធនាគារ និងហិរញ្ញវត្ថុ ដែលមានតួនាទីយ៉ាងសំខាន់ ក្នុងការផ្តល់សេវាធនាគារ និងសេវាហិរញ្ញវត្ថុ ផ្សេងៗ ជាពិសេសផ្តល់ហិរញ្ញប្បទានដល់ប្រជាជនកម្ពុជា គ្រប់វណ្ណៈ ទាំងកសិករ ពាណិជ្ជករ កម្ម ករ ផលិតករ និងអ្នកដែលពាក់ពន្ធ័ផ្សេងៗទៀត ដែលមានតម្រូវការហិរញ្ញវត្ថុ ក្នុងការប្រកបអាជីវ កម្ម និងពង្រីកអាជីវកម្មរបស់ខ្លួនបន្ថែមទៀត ។

ក្នុងនោះផងដែរក៏ឃើញមាន ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ ជាច្រើននៅប្រទេសកម្ពុជា ជា ពិសេសគឺក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុមេហ្គាលីស៊ីង ភីអិលស៊ី ដែលនឹងកំពុងធ្វើប្រតិបត្តិការបំរើ អតិថិជនរបស់ខ្លួន ក្នុងការផ្តល់សេវាភតិសន្យាហិរញ្ញវត្ថុ លើចលនៈវត្ថុ ដូចជាភតិសន្យាហិរញ្ញវត្ថុ លើអេឡិចត្រូនិច គ្រឿងសង្ហារឹម រថយន្តទេសចរណ៍ គ្រឿងចក្រធនធ្ងន់ គ្រឿងចក្រកសិកម្ម និងស ម្ភារៈប្រើប្រាស់ផ្សេងៗ ជាច្រើនទៀត ក្នុងគោលបំណងសម្រួលដល់ ការរសនៅ និងអាជីវកម្មរបស់ ប្រជាជនកម្ពុជា អោយកាន់តែមានលក្ខណៈល្អប្រសើរ ។

## ២. ចំណោទបញ្ហា

ផ្នែកគ្រប់គ្រងសេវាភតិសន្យាហិរញ្ញវត្ថុ គឺជាសេវាកម្មស្នូលរបស់ ក្រុមហ៊ុនភតិសន្យាហិរញ្ញ វត្ថុទាំងមូល វាប្រៀបដូចជា ឆ្អឹងខ្នងរបស់មនុស្ស ដែលអាចជួយអោយមនុស្សងើបឈរ និងដើរទៅ មុខបានយ៉ាងប្រសើរ។ ដូច្នេះក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ រីកចម្រើន ឬអន់ថយគឺអាស្រ័យ លើ ផ្នែកគ្រប់គ្រងភតិសន្យាហិរញ្ញវត្ថុនេះហើយ ។ ដូចនេះតើក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ មេហ្គាលី

ស៊ីងភីអិលស៊ីមាននីតិវិធី និងគោលការណ៍យ៉ាងណាខ្លះ ដើម្បីគ្រប់គ្រងភតិសន្យាហិរញ្ញវត្ថុ អោយមានប្រសិទ្ធិភាព ?

## ៣. គោលបំណង នៃការស្រាវជ្រាវ

ក្នុងការចុះកម្មសិក្សាស្រាវជ្រាវទាក់ទងនឹង ការគ្រប់គ្រងភតិសន្យាហិរញ្ញវត្ថុ នៅក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ មេហ្គាលីស៊ីង ភីអិលស៊ីសាខាភ្នំពេញនេះ ខ្ញុំបាទមានគោលបំណងសំខាន់ៗមួយចំនួនដូចជា៖

- ✓ ដើម្បីស្វែងយល់អំពីទីផ្សារ នៃវិស័យភតិសន្យាហិរញ្ញវត្ថុនៅកម្ពុជា
- ✓ ដើម្បីស្វែងយល់អំពី ស្ថានភាពទូទៅរបស់ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុមេហ្គាលីស៊ីង
- ✓ ស្វែងយល់អំពី លក្ខខណ្ឌតម្រូវ និងការធានាសុវត្ថិភាព ភតិសន្យាហិរញ្ញវត្ថុ
- ✓ ស្វែងយល់អំពីគោលការណ៍និងនីតិវិធីនៃការផ្តល់សេវា ភតិសន្យាហិរញ្ញវត្ថុរបស់ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ មេហ្គាលីស៊ីង ភីអិលស៊ី
- ✓ ស្វែងអំពីនីតិវិធី នៃការកំណត់ប្រាក់បដិភាគ របៀបសងប្រាក់ អត្រាការប្រាក់ និងរយៈពេលនៃភតិសន្យាហិរញ្ញវត្ថុនិមួយៗ
- ✓ ស្វែងយល់អំពីយុទ្ធសាស្ត្រ នៃការគ្រប់គ្រងហានិភ័យឥណទាន អោយមានប្រសិទ្ធភាព

## ៤. វិធីសាស្ត្រ នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទ ការគ្រប់គ្រងភតិសន្យាហិរញ្ញវត្ថុ របស់ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ មេហ្គាលីស៊ីង ភីអិលស៊ីសាខាភ្នំពេញ គឺយើងខ្ញុំបានធ្វើការការសិក្សាស្រាវជ្រាវលើប្រភពទិន្នន័យពីរ គឺទិន្នន័យចម្បង ( Primary Data ) និងទិន្នន័យបន្ទាប់បន្សំ (Secondary Data) ។

ចំពោះទិន្នន័យចម្បង៖ គឺយើងខ្ញុំបានសម្ភាសន៍ និងអង្កេតដោយផ្ទាល់ ជាមួយមន្ត្រីឥណទាន ប្រធានមន្ត្រីឥណទាន ប្រធានសាខា និងប្រធានផ្នែកឥណទាន ។

ចំពោះទិន្នន័យបន្ទាប់បន្សំ គឺ យើងខ្ញុំបានដកស្រង់ចេញពី ៖

- ✓ ច្បាប់ នឹងបទបញ្ញាត្តិរបស់ធនាគារជាតិ នៃកម្ពុជា
- ✓ សៀវភៅទាក់ទងនឹងប្រធានបទនេះនៅក្នុងបណ្ណាល័យ
- ✓ សៀវភៅមេរៀនដែលធ្លាប់រៀន

- ✓ របាយការណ៍កម្មសិក្សា និងសារណារបស់រៀបច្បងជំនាន់មុន
- ✓ ប្រពន្ធ័អិនធើណេត
- ✓ សៀវភៅគោលការណ៍ភតិសន្យាហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមេហ្គា
- ✓ គេហទំព័ររបស់ក្រុមហ៊ុនមេហ្គាលីស៊ីង
- ✓ ឯកសារដែលទទួលបានពីក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ មេហ្គា លីស៊ីង សាខាភ្នំពេញ

## ៥. គម្រោង នៃការស្រាវជ្រាវ

គម្រោង នៃការសិក្សាស្រាវជ្រាវពិតជាមានសារៈសំខាន់ ដែលអាចធ្វើអោយអ្នកអាន ងាយស្រួល ក្នុងការរកមើលចំណុចណាមួយនៅក្នុងរបាយការណ៍កម្មសិក្សាមួយនេះ ។ គម្រោងនៃការសិក្សា មានដូចខាងក្រោមៈ

- ➢ ផ្នែកទី១ គឺផ្នែកដំបូងមួយដែលបកស្រាយអំពី សេចក្តីផ្តើម និងជំពូកទី១ "រំលឹកទ្រឹស្តី"
- ➢ ផ្នែកទី២ ជាផ្នែកមួយដែលមានសារៈសំខាន់ដែលក្តោបនូវអត្តន័យទាំងមូល នៃរបាយការណ៍ចុះកម្មសិក្សានេះ ដែលបកស្រាយអំពី លទ្ធផលនៃការស្រាវជ្រាវ រួមមានៈ ស្ថានភាពទូទៅរបស់ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុមេហ្គាលីស៊ីង ភីអិលស៊ី ការគ្រប់គ្រងភតិសន្យាហិរញ្ញវត្ថុ និង ការវិភាគលើប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុ ។
- ➢ ផ្នែកទី៣ ជាផ្នែកមួយដែលបកស្រាយពីសេចក្តីសន្និដ្ឋាន និងវិភាគពីចំណុចខ្លាំង និង ខ្សោយលើការគ្រប់គ្រងប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុ ឯកសារយោង និងឧបសម្ព័ន្ធផ្សេង ៗ ។

## ៦. សារៈសំខាន់ នៃការស្រាវជ្រាវ

សម្រាប់ការស្រាវជ្រាវចងក្រងនូវរបាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សានេះ បានផ្តល់នូវអត្ថប្រយោជន៍ចំពោះអ្នកស្រាវជ្រាវផ្ទាល់ និងដល់សាធារណៈជនមួយចំនួន ផងដែរ ។ សារៈប្រយោជន៍ទាំងនោះ មានដូចខាងក្រោមៈ

- ✓ បង្កើតចំណេះដឹង និងបទពិសោធន៍ ពាក់ពន្ធ័ នឹងវិស័យឥណទាន និង ភតិសន្យាហិរញ្ញវត្ថុ
- ✓ ឆ្លុះបញ្ចាំងអំពីភាពខុសគ្នា រវាង ទ្រឹស្តី និងការអនុវត្តន៍ជាក់ស្តែង
- ✓ ចងក្រងទុកជាឯកសារជំនួយ ដល់ការសិក្សារបស់និស្សិតជំនាន់ក្រោយ និងធ្វើជាឯកសារគោលមួយសម្រាប់ធ្វើការសិក្សាស្វែងយល់បន្ថែម

✓ ផ្តល់នូវអនុសាសន៍មួយចំនួនសម្រាប់ការកែលម្អ ដើម្បីអោយការគ្រប់គ្រងភតិសន្យាហិរញ្ញវត្ថុកាន់តែមានប្រសិទ្ធភាព ។

## ៧. ទំហំ និងដែនកំណត់ នៃការសិក្សាស្រាវជ្រាវ

✓ **ទំហំ:** ការសិក្សាស្រាវជ្រាវនេះ ខ្ញុំបាទនឹងធ្វើការសិក្សាស្រាវជ្រាវតែនៅក្នុងក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ មេហ្គាលីស៊ីង ភីអិលស៊ី សាខាភំពេញ ។

✓ **ដែនកំណត់:** ចំពោះការស្រាវជ្រាវក្រោមប្រធានបទ **ការគ្រប់គ្រងភតិសន្យាហិរញ្ញវត្ថុ** ខ្ញុំនឹងធ្វើការសិក្សាស្រាវជ្រាវតែ បីផលិតផលប៉ុណ្ណោះរបស់ក្រុមហ៊ុន រួមមានភតិសន្យាហិរញ្ញវត្ថុលើទោចក្រយានយន្ត រថយន្តទេសចរណ៍ និងរថយន្តដឹកទំនិញ ត្រឹម ឆ្នាំ២០១៧ ។

# ជំពូកទី១ រំលឹកទ្រឹស្តី

## ១.១. ស្ថានភាពទូទៅ នៃសេដ្ឋកិច្ចកម្ពុជា[1]

បើយើងទៅតាមរបាយការណ៍ប្រចាំឆ្នាំ ២០១៧ ដែលបានបោះផ្សាយដោយធនាគារជាតិ នៃកម្ពុជាបានសរបញ្ជាក់ថា វិស័យសេដ្ឋកិច្ចចម្បងៗនៅប្រទេសកម្ពុជាដែលបាននឹងកំពុងបន្តធ្វើកំណែទម្រងស៊ីជម្រៅ និងអនុវត្តគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រកដដោយប្រសិទ្ធភាព បានធ្វើអោយសេដ្ឋកិច្ចកម្ពុជារីកលូតលាស់គួរអោយគត់សម្គាល់ ក្នុងអំឡុងពេលមួយទស្សន៍ចុងក្រោយនេះ នេះដោយសារតែភាពអំណោយផល នៃស្ថាន ភាពសេដ្ឋកិច្ចពិភពលោក និងក្នុងតំបន់ ដែលបានចូលរួមយ៉ាងសំខាន់ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចនៅ ប្រទេសកម្ពុជា ។ សេដ្ឋកិច្ចកម្ពុជា នៅតែបន្តកើនឡើង ៦,៩ ភាគរយនៅឆ្នាំ ២០១៧ និង ដែលមានផលិតផលក្នុងស្រុកសរុប (GDP) មានចំនួនប្រមាណ ៨៩ ទ្រីលានរៀល (ស្មើនឹង ២២ប៊ីលានសហរដ្ឋអាមេរិក) នាំអោយចំណូលសម្រាប់ប្រជាជនម្នាក់កើនឡើងដល់ ១,៤៣៤ ដុល្លារអាមេរិក( មានកំណើនទ្វេដងក្នុងរយៈពេល មួយទស្សន៍វត្សចុងក្រោយនេះ)។ ការរីចម្រើន និងរីកលូតលាស់យ៉ាងឆាប់រហ័យបែបនេះ ក៏ដោយសារការកំទ្រពីកំណើនវិស័យធំៗនៅកម្ពុជាមួយចំនួនដូចជា៖ វិស័យកាត់ដេរ វិស័យសំណង់ ទេសចរណ៍ និងការកើនឡើងវិញ នៃវិស័យកសិកម្ម វិស័យធនាគារ និងហិរញ្ញវត្ថុ ហើយលើសពីនេះទៀត ធនាគារជាតិ នៃកម្ពុជា បាននឹងបន្តធ្វើកំណែទម្រង់លើ គោលនយោបាយរូបិយវត្ថុដើម្បីអោយការអនុវត្តន៍ នូវគោលនយោបាយរូបិយវត្ថុអោយមានប្រសិទ្ធិភាព ដើម្បីរក្សា ស្ថេរភាព អត្រាប្តូរប្រាក់ អត្រាអតិផរណានៅប្រទេសកម្ពុជា ។ ការទទួលបានកំណើន សេដ្ឋកិច្ចខ្ពស់រឹងមាំ បែបនេះបានធ្វើអោយប្រទេសកម្ពុជាឈរលេខរៀងទី ៦ ជាប្រទេសដែលមាន កំណើនសេដ្ឋកិច្ចលឿនជាងគេ បំផុតលើពិភពលោក បើយោងតាមរបាយការណ៍ធនាគារពិភពលោក ខែតុលា ឆ្នាំ ២០១៧ ។ លើសពីនេះទៀត ប្រទេសកម្ពុជាបានទទួលបានសមទ្ធិផលដ៏ល្អប្រសើរ ជាមួយគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រដ្ឋាភិបាល បានធ្វើអោយប្រទេសកម្ពុជា ឈរលេខរៀងទី ៤ នៃប្រទេសដែលទទួលបានភាពជោគជ័យលើការកាត់បន្ថយភាពក្រីក្រ ( ក្នុងអត្រា៥៣,៥% នៅឆ្នាំ ២០០៤ មក ត្រឹម អត្រា ១៣,៥% នៅឆ្នាំ ២០១៤ បើយោងតាមរបាយការណ៍ធនាគារពិភពលោក និងថែមទាំងនៅតែបន្តធ្លាក់ចុះ ក្នុងអត្រា ១% ជារៀងរាល់ឆ្នាំ ) ដែលជាគោលដៅអភិវឌ្ឍន៍ សហសវត្សរ៍ ( MDG ) របស់អង្គសហប្រជាជាតិ ។ ទាំងនេះគឺសមទ្ធិផលដ៏វិសេសវិសាលសម្រាប់ប្រទេសកម្ពុជា ។

[1] របាយការណ៍ធនាគារជាតិ នៃកម្ពុជា, ២០១៧, ទំព័រ ।

## ១.២. ស្ថានភាពទូទៅ នៃវិស័យភតិសន្យាហិរញ្ញវត្ថុ

មុននឹងខ្ញុំបាទធ្វើការបកស្រាយពី ខ្លឹមសារនៃចំណុចនេះ ខ្ញុំបាទសុំធ្វើការបង្ហាញនូវ អត្ថន័យពាក្យមួយចំនួនដែលតែងតែប្រើប្រាស់នៅក្នុង ការសរសេរសារណាមួយនេះ៖ **ភតិសន្យាហិរញ្ញវត្ថុ** សំដៅលើ ការបង់រំលស់លើចលនវត្ថុតាមរយៈក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ ធនាគារ ឬគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលផ្តល់សេវាកម្មភតិសន្យាហិរញ្ញវត្ថុដល់អតិថិជន រីឯ **ភតិបតី**[2] គឺសំដៅលើ រូបវន្តបុគ្គលឬនិតិបុគ្គលដែលផ្ទេរសិទ្ធិកាន់កាប់និងប្រើប្រាស់ចលនវត្ថុទៅអោយភតិកៈ ចំណែកឯ **ភតិកៈ**[3] វិញ គឺសំដៅលើរូបវន្តបុគ្គល ឬនិតិបុគ្គល ដែលទទួលបានសិទ្ធិកាន់កាប់ និងប្រើប្រាស់លើចលនវត្ថុពីភតិបតី ។

វិស័យភតិសន្យាហិរញ្ញវត្ថុ គឺជាវិស័យថ្មីមួយនៅក្នុងសេដ្ឋកិច្ចកម្ពុជា ប៉ុន្តែវិស័យនេះមានការការរីកចម្រើនគួរអោយកត់សម្គាល់ ។ បច្ចុប្បន្នក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុមានចំនួន ១១ ក្រុមហ៊ុនឯណោះ ដែលបាននឹងកំពុងផ្តល់សេវាភតិសន្យាហិរញ្ញវត្ថុលើចលនវត្ថុ រួមមាន៖ ទោចក្រ យានយន្ត រថយន្តទេសចរណ៍ គ្រឿងចក្រសម្រាប់សាងសង់ គ្រឿងចក្រប្រើប្រាស់ក្នុងវិស័យកសិកម្ម គ្រឿងអេឡិចត្រូនិច គ្រឿងសង្ហារឹម សម្ភារៈប្រើប្រាស់ក្នុងគ្រួសារ និងចលនវត្ថុផ្សេងៗ ទៀត ដល់អតិថិជន ។ វិស័យចម្បងៗ ដែលទទួលបានសេវាភតិសន្យាហិរញ្ញវត្ថុ រួមមាន៖ កសិកម្ម ២៥% ក្រុមគ្រួសារ ៤០ % ពាណិជ្ជកម្ម ១០ % និងសំណង់ ១០% ផងដែរ។ ជាមួយគ្នានេះដែរតម្រូវការប្រើប្រាស់របស់អតិថិជនបានជំរុញអោយទីផ្សារភតិសន្យាហិរញ្ញវត្ថុមានការចាប់អារម្មណ៍ខ្លាំង ផងដែរពីសំណាក់វិនិយោគិនក្នុង និងក្រៅប្រទេស ។ ជាលទ្ធផលទ្រព្យសកម្មសរុប បានកើនឡើង ១៩.៥ % ជារៀងរាល់ឆ្នាំគឺ ០.៧ ទ្រីលានរៀល និងឥណទានភតិសន្យាហិរញ្ញវត្ថុ សរុបកើនឡើង ១.៩% គឺ ០.៥ ទ្រីលានរៀល និងមានអតិថិជនចំនួន ៦៧,៧៩១ នាក់ ដែលនឹងកំពុងប្រើប្រាស់ សេវាកម្មភតិសន្យាហិរញ្ញវត្ថុរបស់ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុនៅកម្ពុជា ។

### ១.២.១. និយមន័យ នៃភតិសន្យាហិរញ្ញវត្ថុ

គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុជាគ្រឹះស្ថាន ដែលបានទទួលអជ្ញាប័ណ្ណពីធនាគារជាតិ ក្នុងការធ្វើអាជីវកម្ម ភតិសន្យាហិរញ្ញវត្ថុលើចលនវត្ថុដោយស្របច្បាប់ និងស្ថិតនៅក្រោមអាណាព្យាបាលរបស់ធនាគារជាតិ នៃកម្ពុជា ។

[2] ធនាគារជាតិនៃកម្ពុជា, ច្បាប់ភតិសន្យាហិរញ្ញវត្ថុ,២០០៩, ជំពូកទី១,ទំព័រ ៣៩៤

[3] ធនាគារជាតិនៃកម្ពុជា, ច្បាប់ភតិសន្យាហិរញ្ញវត្ថុ,២០០៩, ជំពូកទី១,ទំព័រ ៣៩៤

ភតិសន្យាហិរញ្ញវត្ថុ[4] គឺជា ការជួលឧបករណ៍ ឬសម្ភារៈសម្រាប់ប្រើប្រាស់ ក្នុងអាជីវកម្ម ដែលម្ចាស់អាជីវកម្មគ្មានលទ្ធភាពទិញ ឧបករណ៍ ឬសម្ភារៈនោះបាន ។ ម្យ៉ាងទៀត ភតិសន្យាហិរញ្ញវត្ថុ[5] (Financial Leasing) អនុញ្ញាតឲ្យអតិថិជន ឬក្រុមហ៊ុនជួលនូវចលនវត្ថុ ដូចជា ម៉ាស៊ីន គ្រឿងចក្រ និងសម្ភារ ផលិតផ្សេងៗតាមរយៈកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុដែលនៅក្នុងនោះធនាគារ ឬគ្រឹះស្ថានភតិសន្យាហរិញ្ញវត្ថុផ្សេងៗទិញសម្ភារៈហើយជួលឲ្យអតិថិជន ដែលមានរយៈពេលស្មើ ឬច្រើនជាង ១ឆ្នាំ។ ភតិបតី ជាអ្នកកំណត់ថ្លៃជួលដែលត្រូវបង់តាំងពីដើមគ្រារហូតដល់ចុងបញ្ចប់នៃកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ និង គ្រប់គ្រាន់សម្រាប់ចំណាយទិញសម្ភារ ឬក្នុងរយៈពេលជួលភតិកៈ មានសិទ្ធិទិញដាច់ គឺកម្មសិទ្ធិ នឹងក្លាយជារបស់ភតិកៈ ក៏ប៉ុន្តែភតិកៈ ជាអ្នករ៉ាប់រងនូវការជួសជុលនិងពន្ធ។

### ១.២.២. ប្រវត្តិ នៃវិស័យភតិសន្យាហិរញ្ញវត្ថុនៅកម្ពុជា

នៅឆ្នាំ ២០០៩ ធនាគារជាតិ នៃកម្ពុជាបានបង្កើតសេចក្តីព្រាងច្បាប់ភតិសន្យាហិរញ្ញវត្ថុមួយឡើង ដើម្បីគ្រប់គ្រងលើអាជីវកម្មភតិសន្យាហិរញ្ញវត្ថុ និងត្រៀមខ្លួនដើម្បីទទួលយកនូវវិស័យនេះនៅកម្ពុជា ។ បើយោងទៅតាមរបាយការណ៍របស់ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ ជីអិល ( GL Finance Plc.) ដែលជាក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុដំបូងគេបង្អស់នៅក្នុងសេដ្ឋកិច្ចកម្ពុជា ដែលបានចុះបញ្ជី និងទទួលបានអជ្ញាប័ណ្ណពីធនាគារជាតិ នៃកម្ពុជាដើម្បីដំណើរការអាជីវកម្មភតិសន្យាហិរញ្ញវត្ថុដោយស្របច្បាប់ នៅក្នុងប្រទេសកម្ពុជា នៅឆ្នាំ២០១២ នេះសរបង្ហាញអោយឃើញថា វិស័យភតិសន្យាហិរញ្ញវត្ថុ បានឈានចូលសេដ្ឋកិច្ចកម្ពុជាដំបូងក្នុងឆ្នាំ ២០១២ ។ គិតត្រឹមឆ្នាំ ២០១៧ នេះយើងឃើញមានក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុចំនួន ១១ ក្រុមហ៊ុន ដែលកំពុងដំណើរការអាជីវកម្មក្នុងសេដ្ឋកិច្ចកម្ពុជា ក្រុមហ៊ុនទាំងនោះរួមមានៈ ក្រុមហ៊ុន ភតិសន្យាហិរញ្ញវត្ថុ ជីអិល ហ្វាយនែន ឆាយឡឹស រ៉ូយាល់ លីស៊ីង តូយ៉ូតា ស៊ុយស៊ូ ហ្វាយនែន ប៊ីអេសភី ហ្វាយនែន លីហ្វរ លីស៊ីង អអិមអេ ហ្វាយនែនសល់ សីវីស អាយហ្វាយនែន ឡឺរ៉ូសេ ហ្វាយនែនសល់ លីស៊ីង អេលីន លីស៊ីង ខេខេហ្វាន់លីស៊ីង សួស្តីហ្វាយនែន និង ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ មេហ្គា លីស៊ីង ភីអិលស៊ី ។

[4] https://www.postkhmer.com/ (03 April 2018)

[5] https://www.facebook.com/Khemsarithedu/posts/961379903955028(03 April 2018)

## ១.៣. សេវាកម្ម និងផលិតផលភតិសន្យាហិរញ្ញវត្ថុ

ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ គឺជាក្រុមហ៊ុនហិរញ្ញវត្ថុមួយប្រភេទ ដែលផ្តល់សេវាភតិសន្យាហិរញ្ញវត្ថុ ដល់អតិថិជនរបស់ខ្លួន ។ សេវាភតិសន្យាហិរញ្ញវត្ថុនោះរួមមាន៖ ភតិសន្យាហិរញ្ញវត្ថុលើទោចក្រយានយន្ត រថយន្តទេសចរណ៍ គ្រឿងចក្រកសិកម្ម គ្រឿងចក្រសម្រាប់សាងសង់ រថយន្តដឹកទំនិញ គ្រឿងអេឡិចត្រូនិច គ្រឿងសង្ហារឹម និងចលនផ្សេងៗទៀតត្រូវការជាចាំបាច់ក្នុងសកម្មភាពអាជីវកម្ម និងការរសនៅប្រចាំថ្ងៃនៅក្នុងសង្គមកម្ពុជា ។

### ១.៣.១. ភតិសន្យាហិរញ្ញវត្ថុលើ ទោចក្រយានយន្ត

ប្រភេទ នៃភតិសន្យាហិរញ្ញវត្ថុនេះ សំដៅលើការផ្តល់សេវាំលស់លើ ទោចក្រយានយន្តទាំងឡាយណាដែលត្រូវបានកំណត់ដោយរដ្ឋាភិបាល មានដូចជា ម៉ូតូ ព្រមទាំងម៉ូតូកង់បី និង តុតុជាដើម ។ សេវាភតិសន្យាហិរញ្ញវត្ថុនេះ នឹងត្រូវបានផ្តល់ជូន អតិថិជនទាំងឡាយណាដែលមានបំណងចង់ទទួលបាន ទោចក្រយានយន្តទៅប្រើប្រាស់ តាមរយៈសេវាភតិសន្យាហិរញ្ញ មិនថាគាត់ជាអ្នកមាន ឬអ្នកក្រ ពាណិជ្ជករ ឬកសិករ ឬក៏ផលិតករ នៅក្នុងក្រុង ឬជនបទ នោះទេ ។

### ១.៣.២. ភតិសន្យាហិរញ្ញវត្ថុ លើរថយន្ត

ភតិសន្យាហិរញ្ញវត្ថុលើរថយន្តនេះ សំដៅលើការផ្តល់សេវាំលស់លើ រថយន្តអស់ដែលត្រូវបានកំណត់ដោយរដ្ឋាភិបាលទាំងរថយន្តទេសចរណ៍ និងរថយន្តដឹកទំនិញ រួមមាន លុចស៊ីស តូយ៉ូតា សាំយ៉ុង ហៃឡៃងឌើ ហៀយេនដាយ និងរថយន្តផ្សេងៗជាច្រើនទៀត ។ ផលិតផលនេះ នឹងផ្តល់ជូន សម្រាប់ប្រជាជន កម្ពុជាទាំងអស់ ទាំងនីតិបុគ្គល និង រូបវន្តបុគ្គល ដែលមានបំណងចង់ប្រើប្រាស់សម្ភារៈទាំងនេះ តាមរយៈភតិសន្យាហិរញ្ញវត្ថុ ។

### ១.៣.៣. ភតិសន្យាហិរញ្ញវត្ថុលើ គ្រឿងចក្រ

ចំពោះផលិតផលនេះ សំដៅលើ ការផ្តល់សេវាបង់រំលស់លើ គ្រឿងចក្រគ្រប់ប្រភេទដែលបានកំណត់ដោយរដ្ឋាភិបាល រួមមាន គ្រឿងចក្រសម្រាប់បម្រើអោយវិស័យសាងសង់រួមមាន៖ អាប៊ិលឈូសដី អាឡូកិនដី និងវិស័យកសិកម្ម រួមមាន៖ ម៉ាស៊ីនច្រូតកាត់ស្រូវ ត្រាក់ទ័រ គោយន្ត ជាដើម ។ ផលិតផលនេះ នឹងផ្តល់ជូនសម្រាប់អតិថិជនទាំងអស់ ដែលមានបំណងចង់ប្រើប្រាស់សម្ភារៈ នេះតាមរយៈ សេវាភតិសន្យាហិរញ្ញវត្ថុ ។

### ១.៣.៤. ភតិសន្យាហិរញ្ញវត្ថុលើ គ្រឿងអេឡិចត្រូនិច

គ្រឿងអេឡិចត្រូនិច គឺជាសម្ភារៈប្រើប្រាស់យ៉ាងចាំបាច់ សម្រាប់បុគ្គលម្នាក់ៗ ទាំងក្នុងជីវិតការងារ គ្រួសារ និងសិក្សា ។ ផលិតផលនេះ នឹងអនុញ្ញាតអោយអតិថិជន ធ្វើការបង់រំលស់គ្រប់

ប្រភេទទាំងអស់ នៃគ្រឿងអេឡិចត្រូនិច រួមមាន ទូរស័ព្ទ កុំព្យូទ័រ ម៉ាស៊ីនបោកខោអាវ និងគ្រឿងអេឡិចត្រូនិចផ្សេងៗ ជាច្រើនទៀត ។

### ១.៣.៥. ភតិសន្យាហិរញ្ញវត្ថុលើ គ្រឿងសង្ហារឹម

គ្រឿងសង្ហារឹម ជាសម្ភារៈប្រើប្រាស់ និងលម្អក្នុងផ្ទះ អាជីវកម្ម និងសាលារៀនជាដើម ។ ចំពោះផលិតផលនេះ អតិថជនអាចធ្វើការស្នើសុំប្រើប្រាស់សម្ភារៈ តាមរយៈសេវាភតិសន្យាហិរញ្ញវត្ថុ បានគ្រប់ប្រភេទនៃគ្រឿងសង្ហារឹម ដែលគាត់ចង់បាន រួមមាន៖ តុ ទូរ កៅអី គ្រែ និងគ្រឿងសង្ហារឹមផ្សេងៗជាច្រើនទៀត ។

## ១.៤. តួនាទី និងមុខងារភតិសន្យាហិរញ្ញវត្ថុ

ភតិសន្យាហិរញ្ញវត្ថុ មានមុខងារ និងតួនាទីសំខាន់ៗនៅក្នុងចរន្តសេដ្ឋកិច្ចរួមមាន ៖

### ១.៤.១.ចំពោះភតិកៈ

- ជួយសម្រួលដល់ប្រជាជនដែលមានចំណូលតិច មានលទ្ធភាពអាចទទួលបានសម្ភារៈ ដែលពួកគាត់ចង់បាន
- សម្រួលដល់សកម្មភាពអាជីវកម្ម និង ការរសនៅប្រចាំថ្ងៃ របស់គាត់អោយកាន់តែមានភាពងាយស្រួល និងទាន់សម័យ
- សម្រួលដល់លំហូរសាច់ប្រាក់ តាមរយៈការបំលែងពីការចំណាយដុល មកចំណាយតិចៗបង់ទៅគ្រាដែលបានព្រមព្រៀងគ្នារវាងភតិបតី និងភតិកៈ

### ១.៤.២. ចំពោះភតិបតី

- ទទួលបានប្រាក់ចំណេញ ពីប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុ
- ប្រជាជនស្គាល់ច្រើនពីនាមករណ៍របស់ក្រុមហ៊ុន
- ទទួលបានទំនុបចិត្ត និងការជឿទុកចិត្ត ពីអតិថិជន
- ធ្វើអោយទ្រព្យសកម្មមានការកើនឡើង

### ១.៤.៣. ចំពោះសេដ្ឋកិច្ច

- បង្កើនផលិតផលក្នុងស្រុក តាមរយៈភតិសន្យាហិរញ្ញវត្ថុលើ វិស័យឧស្សាហកម្ម កសិកម្មដែលធ្វើអោយពួកគាត់មានលទ្ធភាពច្រើនក្នុងការពង្រីកផ្ទៃដីដាំដុះ ឬផលិតផលដើម្បីលក់
- ចូលរួមយ៉ាងសំខាន់ក្នុងគោលនយោបាយរបស់រដ្ឋាភិបាល ក្នុងការកាត់បន្ថយភាពក្រីក្រ ដោយគាតអាចយកភតិសន្យាហិរញ្ញវត្ថុលើចលនវត្ថុនឹងដើម្បីពង្រីកមុខរបរ បង្កើត

មុខរបរថ្មី នឹងធ្វើអោយតម្រូវការកម្លាំងពលកម្មកាន់តែខ្ពស់ ដែលនាំអោយប្រជាជនកម្ពុជាមានការងារ និងអាចរកចំណូលបានច្រើន

- បង់ពន្ធចូលរដ្ឋជារៀងរាល់ខែ និងឆ្នាំទៅតាមប្រភេទ នៃពន្ធនិមួយៗដែលត្រូវបានកំណត់ដោយច្បាប់ពន្ធដារ

## ១.៥. ប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុ

រូបភាពដែលបង្ហាញ ពីលំហូរ នៃប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុ៖




(រូបទី១)

## ១.៦. ការគ្រប់គ្រងភតិសន្យាហិរញ្ញវត្ថុ

### ១.៦.១. គោលបំណង

ការគ្រប់គ្រងភតិសន្យាហិរញ្ញវត្ថុ គឺដើម្បី៖

បំពេញតម្រូវការ និងធ្វើអោយកាន់តែប្រសើរឡើង នូវស្ថានភាពអាជីវកម្ម និងការរសនៅរបស់ភតិក:

- ✓ អោយមានប្រសិទ្ធភាពក្នុងការផ្តល់សេវាភតិសន្យាហិរញ្ញវត្ថុពោលគឺរាល់ភតិសន្យាហិរញ្ញវត្ថុទាំងអស់ដែលបានផ្តល់អោយភតិក: អាចប្រមូលបានមកវិញ
- ✓ ម្យ៉ាងទៀត ធ្វើអោយភតិក:មានជីវភាពកាន់តែប្រសើរជាងមុន

- ✓ ស្វែងរកប្រាក់ចំណេញ ជូនម្ចាស់ភាគហ៊ុនិក
- ✓ សម្រេចបានគោលបំណងរយៈពេលវែង របស់ក្រុមហ៊ុន ឬចក្ខុវិស័យ
- ✓ ចូលរួមជាមួយគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ។

### ១.៦.២. ការលក់ និងទីផ្សារ[6]

ការលក់ គឺជាការដោះដូររវាងទំនិញ និងទំនិញ ឬ សាច់ប្រាក់ ដើម្បីបំពេញតម្រូវការ ឬចំណង់ ឬក៏ដើម្បីអត្ថប្រយោជន៍ផ្សេងៗ។

ទីផ្សារ គឺជាសកម្មភាពទាំងឡាយណាដែលក្រុមហ៊ុនធ្វើឡើងដើម្បីបញ្ចុះបញ្ចូល ឬក៏ជាកត្តាជំរុញអោយអតិថិជនប្រើប្រាស់នូវផលិតផលរបស់ខ្លួន។ លើសពីនេះទៅទៀត វាក៏ត្រូវបានគេចាត់ទុកថាជាកត្តាមួយដែលជួយបង្កើននូវចំណង់ចង់បានរបស់បុគ្គលម្នាក់ៗផងដែរ ។ ក្រុមហ៊ុនធ្វើការបង្កើននូវចំណង់របស់អ្នកប្រើប្រាស់ អោយប្រើប្រាស់ ផលិតផលរបស់ខ្លួនតាមរយៈការផ្សាយពាណិជ្ជកម្ម ការបង្ហាញពីអត្ថប្រយោជន៍របស់ផលិតផល ភាពងាយស្រួល ទៅកាន់អតិថិជនគោលដៅ ។

ក្រុមហ៊ុនភាគច្រើននៅលើពិភពលោក ជាពិសេសក្រុមហ៊ុនលក់សេវាកម្មហិរញ្ញវត្ថុ តែងតែអនុវត្តនូវគោលនយោបាយទីផ្សារមួយ គឺ គោលនយោបាយទីផ្សារចំរុះ ឬ 7 Ps ដើម្បីជំរុញ ការលក់អោយកាន់តែច្រើន ។ គោលនយោបាយទីផ្សារចំរុះនេះមានដូចជា[1]៖ ផលិតផល ( product ) ការកំណត់តម្លៃលក់ ( Pricing ) ការដាក់ទីតាំង ( Placing ) ការផ្សព្វផ្សាយ ( Promotion ) សមត្ថភាពអ្នកធ្វើទីផ្សារ ( People ) និតិវិធី ឬតំណើរការនៃការផ្តល់សេវាកម្ម ឬទំនិញដល់អតិថិជន ( Processes ) ភស្តុតាងជារូបវន្ត នៃក្រុមហ៊ុន ( Physical evident ) ។

### ១.៦.៣. នីតិវិធី នៃការផ្តល់សេវាភតិសន្យាហិរញ្ញវត្ថុ ( Lease offering procedure )

#### ១.៦.៣.១ ការពិនិត្យសំណើរសុំលើកដំបូង ( Initial Screening of application )

ទម្រង់សំណើរស្នើសុំភតិសន្យាហិរញ្ញវត្ថុ ត្រូវតែជាទំរង់មួយដែលមានលក្ខណៈខ្លី ងាយស្រួលនិងមានពត៌មានគ្រប់គ្រាន់ដើម្បីធ្វើការអង្កេតនៅពេលដែលអតិថិជនស្នើរសុំភតិសន្យាហិរញ្ញវត្ថុ ។ នាពេលបច្ចុប្បន្ននេះ អ្នកផ្តល់សេវាភតិសន្យាហិរញ្ញវត្ថុ សម្រាប់អ្នកប្រើប្រាស់ជាច្រើន

[6] https://www.professionalacademy.com/blogs-and-advice/marketing-theories---the-marketing-mix---from-4-p-s-to-7-p-s, 20/05/18

បានប្រើប្រាស់ប្រពន្ធ័ក្នុងការផ្តល់ពន្ទុឥណទានសម្រាប់ត្រួតពិនិត្យលើសំណើរសុំភតិសន្យាហិរញ្ញវត្ថុថ្មីៗ ។ ចំពោះភតិសន្យាហិរញ្ញវត្ថុទាំងអស់ ក្នុងការវាយតម្លៃឥណទានរបស់អ្នកស្នើសុំ ភតិសន្យាហិរញ្ញវត្ថុ ត្រូវបានយោងទៅតាមអនុបាតហិរញ្ញវត្ថុ ជាគោលសម្រាប់ផ្តល់ពិន្ទុឥណទាន (ដោយប្រើប្រាស់) ទ្រព្យសម្បត្តិ បំណុល និងប្រាក់ចំណេញសម្រាប់គណនា ) ។ ការវាយតម្លៃ និងដាក់ពិន្ទុហិរញ្ញវត្ថុ នេះ គឺដើម្បីបង្ហាញអោយឃើញអំពីលទ្ធភាព នៃការបំពេញកតព្វកិច្ច ទូទាត់បំណុលរបស់ភតិក: នៅក្នុងកំឡុងពេលភតិសន្យាហិរញ្ញវត្ថុ នោះ ។

**១.៦.៣.២. ការស៊ើបអង្កេតឥណទាន** ( Credit Investigation )

ការស៊ើបអង្កេត ភតិសន្យាហិរញ្ញវត្ថុក៏ដូចទៅនឹង ការស៊ើបអង្កេតឥណទានដែរ គឺជាការប្រមូល និងផ្ទៀងផ្ទាត់ពត៌មាន ថាតើពត៌មានដែលទទួលបានពីអតិថិជន ពិតជាត្រឹមត្រូវ និងគ្រប់គ្រាន់ដែរ ឬទេ ? ការស៊ើបអង្កេតឥណទាន ពិតជាមានសារ:សំខាន់ចំពោះការសម្រេចចិត្ត ។ វាជាមូលដ្ឋានគ្រឹះក្នុងការសម្រេចចិត្ត ហើយការសម្រេចចិត្ត នឹងមានប្រសិទ្ធិភាពប្រសិនបើ យើងប្រមូល ពត៌មានបាន គ្រប់គ្រាន់ និងត្រឹមត្រូវ ។ ម្យ៉ាងទៀត ការស៊ើបអង្កេតឥណទាន ក៏ជាមធ្យោបាយមួយ ក្នុងការវាស់វែងហានិភ័យឥណទានផងដែរ ។ ការស៊ើបអង្កេតឥណទាន នេះត្រូវបានអនុវត្តដោយ អនុលោមទៅតាមគោលនយោបាយស៊ើបអង្កេតពត៌មានឥណទាន[7] 5C's និង ។ ទម្រង់នៅអក្សរកាត់ 5C's នេះរួមមាន៖ Character, Capacity or Cash flow, Capital, Collateral and Condition ។

អ្នកគ្រប់គ្រងឥណទាន ឬភតិសន្យាហិរញ្ញវត្ថុ ជាច្រើនបាន អនុវត្តនូវគោលនយោបាយនេះធ្វើជាមូលដ្ឋានគ្រឹះក្នុងការស៊ើបអង្កេត និងវាយតម្លៃ ពីគុណភាពភតិសន្យាហិរញ្ញវត្ថុមុននឹងធ្វើការសម្រេចចិត្ត ផ្តល់ភតិសន្យាហិរញ្ញវត្ថុទៅអតិថិជន ។

**ក. ចរិកលក្ខណៈ** ( Character )

ចំណុចនេះ គឺផ្តោតសំខាន់លើ ភាពទទួលខុសត្រូវ និងឆន្ទ:សងបំណាំងរបស់អតិថិជន ។ ចរិកសំដៅលើ ការប្រព្រឹត្ត ឬកពារ ឬកិរិយាមាយាទរបស់អតិថិជន ។ ចរិកកំណត់ដោយទម្លាប់ និងអាកប្បកិរិយា ដែលសំដែងចេញ តាមរយ:ការដើរដេក និយាយស្តី ការប្រាស្រ័យទាក់ទង ការរៀបចំខ្លួន និងផ្ទះសម្បែងជាដើម ។ ចរិកលក្ខណ: នឹងបង្ហាញពីឆន្ទ:សងបំណុលរបស់កូន

[7] ផែនសុខហេង, របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា ២០១៦, ការគ្រប់គ្រងឥណទានអាជីវកម្ម និងកសិកម្ម,ទំព័រ ១៤

បំណុល ។

**ខ. សមត្ថភាពសងបំណុល ឬ លំហូរសាច់ប្រាក់** ( Capacity or Cash flow )

សមត្ថភាពសងបំណុល គឺជាចំណុចក្តៅសម្រាប់អ្នកផ្តល់ភតិសន្យាហិរញ្ញវត្ថុ ឬឥណទាន ។ វាជះឥទ្ធិពលយ៉ាងខ្លាំងដល់ គុណភាពភតិសន្យាហិរញ្ញវត្ថុ ឬឥណទាន ។ ជាទូទៅដើម្បីកំណត់ ថាតើអតិថិជន មានសមត្ថភាពសងបំណុលដែរ ឬទេ ? គឺអ្នកផ្តល់សេវាភតិសន្យាហិរញ្ញវត្ថុ នឹងធ្វើការសិក្សាលើ ប្រភពចំណូល ថាតើអតិថិជនមានប្រភពចំណូលពីណាខ្លះ ហើយមាននិរន្តភាពដែរ ឬទេ? ដោយមើលលើ ប្រភេទការងារ ក្រុមហ៊ុន ឬអាជីវកម្មរបស់គាត់ ។ ហើយជាចាំបាច់បំផុត ដើម្បីកំណត់ពីលទ្ធភាពសងបំណុល អ្នកផ្តល់ភតិសន្យាហិរញ្ញវត្ថុ ត្រូវតែធ្វើការសិក្សាអោយបានច្បាស់នូវប្រភពចំណាយរបស់គាត់ ។ ការធ្វើបែបនេះ គឺដើម្បីដឹងពីថា តើប្រាក់ចំណេញសុទ្ធរបស់គាត់វិជ្ជមាន ឬក៏អវិជ្ជមាន បន្ទាប់ពីទូទាត់ចំណាយទាំងអស់នោះរួច ។

**គ. មូលធន** ( Capital )

មូលធន សំដៅលើទ្រព្យបម្រុងទុកទាំង រូបិយ និងអរូបិយរបស់អតិថិជនដើម្បីធានាគុណភាពភតិសន្យាហិរញ្ញវត្ថុ នៅពេលដែលអតិថិជនបាត់បង់ប្រាក់ចំណូល ឬអសមត្ថភាពសងបំណុលរយៈពេលខ្លី ។ មូលធន សំដៅលើភាពខ្លាំងលើផ្នែកហិរញ្ញវត្ថុ របស់អ្នកស្នើសុំភតិសន្យាហិរញ្ញវត្ថុ ឬឥណទាន រួមមានៈ សមតុល្យប្រាក់បញ្ញើនៅធនាគារ ផ្ទះ ដីធ្លី អាគារ រថយន្ត ជាដើម ។

**ឃ. ទ្រព្យធានា** ( Collateral )

ទ្រព្យធាន គឺជាទ្រព្យដែល កូនបំណុលដាក់ធានានូវបំណុលដែលខ្លួនបានស្នើសុំ ។ ទ្រព្យធានា ផ្តល់សុវត្ថិភាពសម្រាប់ ភតិសន្យាហិរញ្ញវត្ថុ ឬឥណទានដែលកូនបំណុលបានស្នើសុំ ។ ជាទូទៅអ្នកផ្តល់ភតិសន្យាហិរញ្ញវត្ថុ ឬឥណទាន តែងតែធ្វើការសិក្សាលើ ភាពត្រឹមត្រូវ គ្រប់គ្រាន់ និងស្របច្បាប់នៃទ្រព្យនោះ ជាពិសេស គឺសិក្សាលើ ភាពងាយស្រួលបំលែងជាសាច់ប្រាក់ និង បម្រែបម្រួលតម្លៃនៅលើទីផ្សារ ។

**ង. លក្ខខណ្ឌទូទៅ** ( Condition )

លក្ខខណ្ឌទូទៅ គឺជាផ្នែកមួយ នៃការវាយតម្លៃពីគុណភាពភតិសន្យាហិរញ្ញវត្ថុ ឬឥណទាន ។ ជាទូទៅអ្នកផ្តល់សេវាភតិសន្យាហិរញ្ញវត្ថុ ឬឥណទាន ត្រូវតែធ្វើការសិក្សាលើ បម្រែបម្រួល នៃនិន្នាការសេដ្ឋកិច្ច នយោបាយ និងសង្គ្រាម ដែលអាចជះឥទ្ធិពលដល់ លទ្ធភាពនៃការទូទាត់សំណង់របស់កូនបំណុល ។

**១.៦.៣.៣. ការសម្រេចចិត្ត**

ការសម្រេចចិត្តផ្តល់ភតិសន្យាហិរញ្ញវត្ថុ ទៅដល់អតិថិជនគឺជាការវិនិច្ឆ័យដោយវិជ្ជាជីវៈមួយ ដែលត្រូវបានធ្វើឡើងដោយអ្នកគ្រប់គ្រងភតិសន្យាហិរញ្ញវត្ថុ ថាតើគួរតែផ្តល់អោយ ឬកាត់បន្ថយ ទំហំភតិសន្យាហិរញ្ញវត្ថុ ឬមិនផ្តល់អោយតែម្តង ដោយយោងទៅតាមពត៌មានស្ថានភាពជាក់ស្តែង របស់អតិថិជន ។

### ១.៦.៤. ការគ្រប់គ្រងប្រពន្ធ័ នៃការទារ ប្រមូលប្រាក់ឈ្នួល

ការប្រមូលប្រាក់ឈ្នួល គឺជាកត្តាមួយយ៉ាងសំខាន់ចំពោះគុណភាពភតិសន្យាហិរញ្ញវត្ថុ ដែល អាចជួយអោយភតិកៈទូទាត់ប្រាក់ឈ្នួលបាន គ្រប់ចំនួន និងទៀតទាត់ទៅតាមពេលវេលាដែល បានកំណត់ក្នុងកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ។ គ្រប់ក្រុមហ៊ុន ភតិសន្យាហិរញ្ញវត្ថុនិមួយៗ បាន បង្កើតនូវគោលនយោបាយ ឬវិធីសាស្ត្រក្នុងការប្រមូលប្រាក់ឈ្នួលអោយមានប្រសិទ្ធ ភាព ដែលអាចសម្រួលដល់ភតិកៈ ក្នុងការបង់ប្រាក់ឈ្នួល អោយមានភាពងាយស្រួល និងសុវត្ថ ភាព ខ្ពស់ ។ ប្រព័ន្ធនៃការទារប្រមូលនេះ អនុញ្ញាតអោយអតិថិជនធ្វើការបង់ប្រាក់ឈ្នួលតាមរយៈ កញ្ចុះ បង់ប្រាក់របស់ក្រុមហ៊ុនផ្ទាល់ ទ្រូម៉ាន់នី វីង អ៊ីម៉ាន់នី និងតាមធនាគារផ្សេងៗ ជាច្រើនទៀត ដែល នៅជិតអតិថិជនបំផុត ។

#### ១.៦.៤.១. គោលដៅនៃប្រព័ន្ធទារប្រមូល

គោលដៅនៃ ប្រព័ន្ធទារប្រមូល គឺធ្វើយ៉ាងណា អោយភតិសន្យាហិរញ្ញវត្ថុទាំងអស់ដែលបាន ផ្តល់ទៅភតិកៈប្រមូលបានគ្រប់ចំនួន និងទាន់ពេលវេលា ហើយមានភាពងាយស្រួល និងសុវត្ថិ ភាព ។ប្រព័ន្ធទារប្រមូល អាចប្រមូលប្រាក់ឈ្នួលបាន តែវាពិតជាពិបាក នៅពេលក្រុមហ៊ុន គិតគូរ ពីកេរ្តិ៍ឈ្មោះរបស់អតិថិជន ។ ប្រសិនបើក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ រៀបចំនូវប្រព័ន្ធទារប្រមូល ប្រាក់ឈ្នួលដោយ ការពារភតិកៈពេក នោះភតិកៈអាចទូទាត់ប្រាក់ឈ្នួលយឺត និងមិនគ្រប់តាម ចំនួនដែលបានព្រមព្រៀង ក្នុងតារាងបង់សងប្រាក់ឈ្នួល ។ ដូច្នេះហើយបានជាក្រុមហ៊ុនរៀបចំ អោយភតិកៈអាចធ្វើការបង់សងតាមរយៈទ្រូម៉ាន់នី ឬវីង ឬក៏ធនាគារ ដែលនៅជិតគាត់បំផុត ព្រម ទាំងការខិតខំយ៉ាងមោះមត់ ពីផ្នែកប្រតិបត្តិការ នៃក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ រួមមាន៖ មន្ត្រី ឥណទាន ប្រធានមន្ត្រីឥណទាន និងបុគ្គលិកដែលពាក់ព័ន្ធផ្សេងៗទៀត ជាពិសេស មន្ត្រីស្តារបំណុល ។

#### ១.៦.៤.២. មូលហេតុដែលភតិកៈ មិនបង់សងប្រាក់ឈ្នួល

អតិថិជនទាំងអស់មិនដូចគ្នាទេ ហើយទោះបីជាអ្នកផ្តល់សេវាភតិសន្យាហិរញ្ញវត្ថុខិតខំ សម្រិតសម្រាំង និងជ្រើសរើសអតិថិជនយ៉ាងណាក៏ដោយ ក៏នៅតែមិនអាចទទួលបានអតិថិជនល្អ

១០០ ភាគរយដែរគ្រាន់តែមានតិច ឬ ច្រើនប៉ុណ្ណោះ ។ ដូច្នេះហើយ វាមានកត្តាច្រើន ដែលធ្វើអោយ អតិថិជនបង់សង ឬមិនបង់សងប្រាក់ឈ្នួល ។ កត្តាទាំងនោះរួមមាន៖

**ក. កត្តាអតិថិជន**

- ✓ ភតិកៈបាត់បង់សមត្ថភាពទូទាត់ប្រាក់ឈ្នួល ៖ ភតិកៈ នឹងបាត់បង់សមត្ថភាពសងនៅពេលណាដែល គាត់ជួបប្រទះនូវការបាត់បង់ការងារ ការបរាជ័យក្នុងអាជីវកម្មរបស់គាត់ ដែលជាប្រភពចំណូលយ៉ាងសំខាន់របស់គាត់ ។
- ✓ យឺតជាទំលាប់ ឬធម្មជាតិ ៖ អតិថិជនមានទំលាប់យឺតក្នុងការបង់សងក្រុមហ៊ុនវិញ
- ✓ ខ្សោយក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ ៖ អតិថិជនមួយចំនួន មិនមានសមត្ថភាពក្នុងការគ្រប់គ្រង និងបែងចែកសាច់ប្រាក់អោយសមមូលទៅនឹងសាច់ប្រាក់ដែលគាត់ទទួលបាន ។នេះជាមូលហេតុដែលធ្វើអោយចេះតែកង្វះខាត និងយកកម្ចីថ្មីៗបន្ថែមទៀត ដែលនាំ អោយគាត់បាត់បង់សមត្ថភាពទូទាត់ប្រាក់ឈ្នួលមក្រុមហ៊ុនវិញ ។

**ខ. កត្តាក្រុមហ៊ុន**

- ✓ មន្ត្រីឥណទាន មិនបានបណ្តុះវិន័យឥណទានបានគ្រប់គ្រាន់ ដែលធ្វើអោយអតិថិជនយល់ខុសនូវលក្ខខណ្ឌ។
- ✓ ការបរាជ័យនៃអាជីវកម្ម របស់ក្រុមហ៊ុន៖ អតិថិជនមិនធ្វើការទូទាត់ប្រាក់ឈ្នួលមកក្រុមហ៊ុនវិញពេលណាក្រុមហ៊ុនក្ស័យធន ។

### ១.៦.៥. ការកំណត់ ប្រភេទអតិថិជន

ដោយមើលឃើញថា ស្ថានភាពរបស់អតិថិជនម្នាក់ៗ មិនដូចគ្នាទេ អ្នកខ្លះមាន អ្នកខ្លះក្រ និងអ្នកខ្លះក៏មានអត្តចរិកល្អ ប៉ុន្តែក៏មានអ្នកខ្លះទៀតក៏មានចរិកមិនល្អ ។ កត្តាទាំងនេះពិតជាមានការប៉ះពាល់ខ្លាំងដល់អជីវកម្មឥណទាន ឬភតិសន្យាហិរញ្ញវត្ថុ ។ ដូចនេះហើយអ្នកគ្រប់គ្រងក្រុមហ៊ុនឬ ប្រតិបត្តិការរបស់ក្រុមហ៊ុន ត្រូវតែធ្វើបំណែងចែក នៃប្រភេទអតិថិជននិមួយៗ ដោយយោងទៅតាម ស្ថានភាពជាក់ស្តែង និងប្រវត្តិរបស់អតិថិជន ដើម្បីអោយការគ្រប់មានប្រសិទ្ធិភាព ។ ប្រភេទអតិថិជនរួមមានដូចខាងក្រោម ៖

- ✓អតិថិជនមាន សមត្ថភាពបង់សង និងមានឆន្ទៈបង់សង
- ✓អតិថិជនមានសមត្ថភាពបង់សង តែមិនមានឆន្ទៈបង់សង
- ✓អតិថិជនគ្មានសមត្ថភាពបង់សង តែគាត់មានឆន្ទៈបង់សង
- ✓អតិថិជនមិនមានសមត្ថភាពបង់សង និងមិនមានឆន្ទៈបង់សង

### ១.៦.៦. ការកំណត់ចំណាត់ថ្នាក់ឥណទាន និងសំវិធានធន

#### ១.៦.៦.១. ការកំណត់ចំណាត់ថ្នាក់ឥណទាន[៨]

បើយោងតាមប្រកាសរបស់ធនាគារជាតិ នៃកម្ពុជា ដែលបានបោះផ្សាយ នៅថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០០២ ស្តីអំពី ចំណាត់ថ្នាក់ និង សំវិធានធនលើឥណទានបានចែងថា គ្រប់គ្រឹះស្ថាន ធនាគារ មីក្រូហិរញ្ញវត្ថុ និងក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ ទាំងអស់ដែលបានទទួលអជ្ញាប័ណ្ណ ត្រូវធ្វើ ចំណាត់ថ្នាក់ឥណទាន របស់ខ្លួនជា បួនថ្នាក់ ដោយផ្អែកលើស្ថានភាពហិរញ្ញវត្ថុរបស់ អ្នកខ្ចី ឬភតិក: និងឥណប្រតិទាន នៃការទូទាត់សង់ ប្រាក់ដើម និង ការប្រាក់ ឬប្រាក់ឈ្នួល ។

**ក. បំណុលស្តង់ដារ**

បំណុលស្តង់ដារជាបំណុលដែលមានលក្ខណ: ដូចជា៖

- ✓ ទូទាត់បំណុល បានគ្រប់ចំនួន និងទៀតទាត់ពេលវេលា
- ✓ ការទូទាត់សងបំណុលមិនលើសពី ៣០ ថ្ងៃនៃកាលបរិច្ឆេទដែលត្រូវទូទាត់សង់

**ខ. បំណុលក្រោមស្តង់ដារ**

បំណុលក្រោមស្តង់ដារ ជាបំណុលដែលមានលក្ខណ:ដូចខាងក្រោម៖

- ✓ ការទូទាត់សងត្រឡប់មានការយឺតយ៉ាវ
- ✓ ការទូទាត់សងត្រឡប់មានការយឺតយ៉ាវ ហួសកាលកំណត់ ៣០ ថ្ងៃឬច្រើនជាង

**គ. បំណុលសង្ស័យ**

បំណុលសង្ស័យ ជាបំណុលដែលមានការបង់សងយឺតយ៉ាងខ្លាំង និងប្រឈមទៅនឹងការ បាត់បង ។ បំណុលនេះមានលក្ខណ: ដូចជា៖

- ✓ ការទូទាត់បង់សងមានការយឺតយ៉ាវខ្លាំង
- ✓ ការទូទាត់សងត្រឡប់មានការយឺតយ៉ាវហួសកាលកំណាត់ដូចខាងក្រោម៖
    - ៦០ថ្ងៃ ឬច្រើនជាងនេះ ក្នុងករណីឥណទានមានប្រតិទាន ១ឆ្នាំ ឬតិចជាងមួយឆ្នាំ
    - ១៨០ ថ្ងៃឬច្រើនជាងនេះ ក្នុងករណីឥណទានមានឥណប្រតិទាន លើសពី១ ឆ្នាំ

**ឃ. បំណុលបាត់បង់**

បំណុលដែលបាត់បង ជាបំណុលដែលធ្វើចំណាត់ថ្នាក់ខាតបង់ដោយសន្មត់ថាមិនអាច ប្រមូលបានមកវិញ តែបើបានក៏បានតិចតួចដែរ ។ បំណុលនេះមានលក្ខណ:សង់ដើម ការ ឬប្រាក់

[៨] ផែន សុខហេង, របាយការណ៍បញ្ចប់ការសិក្សា ២០១៦, ការគ្រប់គ្រងឥណទានអាជីវកម្ម និងកសិកម្ម ទំព័រ ១២ និង ធនាគារជាតិនៃកម្ពុជា, ប្រកាស ឆ្នាំ ២០០២, ចំណាត់ថ្នាក់ និងសំវិធានធនលើឥណទាន, ប្រការ២

ឈ្នួលមានយឺតយ៉ាវដូចខាងក្រោម៖

- ✓ យឺត៩០ ថ្ងៃ ឬច្រើនជាងនេះ ក្នុងករណីឥណប្រតិទាន ១ ឆ្នាំ ឬតិចជាង
- ✓ យឺត ៣៦០ ថ្ងៃ ឬច្រើនជាង ក្នុងករណីឥណប្រតិទាន លើសពីមួយឆ្នាំ ។

### ១.៦.៦.២. ការធ្វើសំវិធានធនលើឥណទាន ឬភតិសន្យាហិរញ្ញវត្ថុ[9]

ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុទាំងអស់ត្រូវធ្វើសំវិធានធនលើភតិសន្យាហិរញ្ញវត្ថុទាំងភតិសន្យាហិរញ្ញវត្ថុដែលប្រមូលបាន និងភតិសន្យាហិរញ្ញវត្ថុដែលមិនអាចប្រមូលបាន ដោយយោងទៅ តាមប្រកាសស្តីអំពី ចំណាត់ និងសំវិធានធនលើឥណទាន ។ សំវិធានធន នេះត្រូវបានបែងចែកជា ២ ប្រភេទគឺ សំវិធានធនទូទៅ និងសំវិធានធនជាក់លាក់ ។

**សំវិធានធនសរុប = សំវិធានធនទូទៅ + សំវិធានធនជាក់លាក់ ឬ សំវិធានធនសរុប = សមតុល្យភតិសន្យាហិរញ្ញវត្ថុសរុប * ១២៥ % នៃការធ្វើសំវិធានធនជាក់លាក់ ។**

សំវិធានធនភតិសន្យាហិរញ្ញវត្ថុ ឬឥណទាន ត្រូវបានបង្ហាញដូចខាងក្រោម ៖

- ✓ចំពោះបំណុលស្តង់ដារ ១% ដោយមិនគិតតម្លៃទ្រព្យសកម្មដែលបានដាក់ធានា លើកលែងតែសាច់ប្រាក់
- ✓ចំពោះ បំណុលក្រោមស្តង់ដារ ១០% ដោយមិនគិតតម្លៃទ្រព្យសកម្មដែលបានដាក់ធានា លើកលែងតែសាច់ប្រាក់
- ✓ចំពោះបំណុលសង្ស័យ ៣០% ដោយមិនគិតតម្លៃទ្រព្យសកម្មដែលបានធានាលើកលែងតែសាច់ប្រាក់
- ✓ចំពោះបំណុលបាត់បង់ ១០០% បើគ្រឹះស្ថាន ឬក្រុមហ៊ុនអាច បង្ហាញភស្តុតាងតាមករណីនិមួយៗ នូវតម្លៃទីផ្សារជាក់ស្តែង នៃទ្រព្យដែលបានដាក់ធានា ឬបញ្ចាំ និងមានការយល់ព្រមពីធនាគារជាតិនៃកម្ពុជា និងចំនួនឥណទាន ឬភតិសន្យាហិរញ្ញវត្ថុដែលមិនមានសម្ភារៈធានាត្រូវធ្វើសំវិធានធន ។

## ១.៧. ហានិភ័យរបស់ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ

ហានិភ័យមានន័យច្រើនផ្សេងៗគ្នានៅក្នុងធុរកិច្ច និងជីវិតរសនៅប្រចាំថ្ងៃ ។ ហានិភ័យ គឺជា ការជះឥទ្ធិពលអវិជ្ជមាន ដោយកត្តាផ្សេងៗ ដែលធ្វើអោយមានភាពខុសគ្នារវាងលទ្ធផល

[9] ផែនសុខហេង, របាយការណ៍បញ្ចប់ការសិក្សា ២០១៦, ការគ្រប់គ្រងឥណទានអាជីវកម្ម និងកសិកម្ម ទំព័រ ១៣

ជាក់ស្តែងជាមួយនឹងអ្វីដែលបានរំពឹងទុក ។ ហានិភ័យ អាចកើតមានឡើង បានគ្រប់ពេលវេលាមិនថានៅផ្ទះ នៅកន្លែងធ្វើការ វិនិយោគតិច ឬច្រើនទេ ។ ហានិភ័យមានច្រើនចំពោះ គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ រួមមាន[10]៖ ហានិភ័យសន្ទនីយភាព អត្រាការប្រាក់ កាលវសាន្ត (ការគ្រប់គ្រងទ្រព្យសកម្ម និងអកម្ម ) ហានិភ័យឥទាន ហានិភ័យប្រតិបត្តិការ ហានិភ័យទីផ្សារ ហានិភ័យទ្រព្យសកម្ម ហានិភ័យឯកសារ ហានិភ័យប្រមូលផ្តុំ និងហានិភ័យផ្សេងៗទៀតដែលអាចកើត ចំពោះក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ នៅពេលធ្វើប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុ តាមផែនការអាជីវកម្ម ។

**១.៧.១. ហានិភ័យឥណទាន ឬ ហានិភ័យសមភាគី**[11] **៖**

ហានិភ័យនេះកើតឡើងដោយសារតែការខកខានមិនបានគោរពតាមកិច្ចសន្យាមួយផ្នែក ឬទាំងស្រុង ដោយសមភាគីណាមួយ ឬសមភាគីច្រើនដែលរួមគ្នាជា អត្តគាហក ។ ហានិភ័យនេះ គឺជាចំណុចយ៉ាងក្តៅ ចំពោះអ្នកគ្រប់គ្រងភតិសន្យាហិរញ្ញវត្ថុ ដែលត្រូវគិត វិភាគ អោយបានច្បាស់លាស់ លើគុណភាពឥណទាន មុននឹងសម្រេចចិត្តផ្តល់សេវាភតិសន្យាហិរញ្ញវត្ថុ ដើម្បីធានាគុណភាពភតិសន្យាហិរញ្ញវត្ថុ ។

**១.៧.២. ហានិភ័យទីផ្សារ** ( Market Risk )

ហានិភ័យទីផ្សារ គឺជាហានិភ័យ នៃការខាតបង់ហិរញ្ញវត្ថុដែលបណ្តាលមកពីបម្រែបម្រួលថ្លៃទ្រព្យសកម្មនៅលើទីផ្សាររូបិយវត្ថុ ទីផ្សារទុន និងហិរញ្ញវត្ថុ ។ ហានិភ័យទីផ្សារ រួមបញ្ចូលទាំងហានិភ័យ អត្រាការប្រាក់ អត្រាប្តូរប្រាក់ ហានិភ័យដើមទុន និងហានិភ័យពាក់ព័ន្ធនឹងទំនិញ ។

**១.៧.៣. ហានិភ័យអត្រាការប្រាក់** ( Interest rate Risk )

ហានិភ័យអត្រាការប្រាក់គឺជា ហានិភ័យដែលមាននៅក្នុងបញ្ជីការធនាគារ ( Banking Book Transaction) ទាំងក្នុងនិងក្រៅតារាងតុល្យការ នៅពេលមានបម្រែបម្រួលអត្រាការប្រាក់ដែលកើតឡើងពីអតុល្យភាព រវាងលក្ខខណ្ឌនៃការទទួលទុន និងការអោយខ្ចី ។

ហានិភ័យនេះប៉ះពាល់ដោយ ផ្ទាល់ ទៅលើកំលាតការប្រាក់ សុទ្ធរបស់គ្រឹះស្ថាន ដែលគណៈកម្មការជាក់លាក់មួយ ដូចជាគណៈ កម្មការគ្រប់គ្រងទ្រព្យអកម្ម និងទ្រព្យសកម្ម ជាដើម ត្រូវតាមដាន និងគ្រប់គ្រងអោយបានត្រឹមត្រូវ រួមជាមួយស្ថានភាពសាច់ប្រាក់ងាយស្រួលជារួមផងដែរ ។

[10] ច្បាប់ភតិសន្យាហិរញ្ញវត្ថុ ២០១១, ជំពូកទី ២ មាត្រាទី ៤

[11] https://www.nbc.org.kh/download_files/legislation/prakas_kh/5028b7-010-172.pdf (២0/0៥/១៨ )

បញ្ជិការធនាគារ សំដៅលើ ខ្ទង់ចំណូល និងចំណាយនៅលើមូលដ្ឋានបង្គរ ។ហានិភ័យអត្រាការប្រាក់ដែលពាក់ព័ន្ធ នឹងបម្រែបម្រួលថ្លៃឧករណ៍អាចជួលដូរបាន ដែលកើតឡើងពីការចុះបញ្ជិកាតាមថ្លៃទីផ្សារ ឬថ្លៃសមស្រប ត្រូវតែចាត់ទុកជា ហានិភ័យទីផ្សារ ។

**១.៧.៤. ហានិភ័យប្រតិបត្តិការ** ( Operational Risk )

ហាភ័យប្រតិបត្តិការ ជាហានិភ័យដែលកើតឡើង ភាពមិនគ្រប់គ្រាន់ ឬកំហុសឆ្គងពីនីតិវិធីគ្រប់ គ្រងផ្ទៃក្នុងបុគ្គល ( Personnel ) ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ឬកត្តាខាងក្រៅផ្សេងទៀត ។

**១.៧.៥. ហានិភ័យ គតិយុត្ត** ( Legally Risk )

ហានិភ័យគតិយុត្ត ជាហានិភ័យមួយប្រភេទដែលស្ថិតនៅក្រោមហានិភ័យប្រតិបត្តិការ ។ ហានិភ័យនេះកើតឡើងពីវិវាទសមភាគី ណាមួយដែលបណ្តាលមកពីភាពមិនច្បាស់លាស់ ភាពមិនត្រឹមត្រូវ ភាពទន់ខ្សោយ ឬអ្វីផ្សេងទៀត ដែលអាចកើតឡើងចំពោះគ្រឹះស្ថាន ឬក្រុមហ៊ុន នៅពេលធ្វើប្រតិបត្តិការ ។

**១.៧.៦. ហានិភ័យសន្ទនីយភាព ឬសាច់ប្រាក់ងាយស្រួល** ( Liquidity Risk )

ហានិភ័យសន្ទនីយភាព គឺជា ហានិភ័យក្នុងលក្ខខណ្ឌទីផ្សារមួយ ដែលគ្រឹះស្ថាន ឬក្រុមហ៊ុនពុំមានលទ្ធភាពបំពេញកតព្វកិច្ចរបស់ខ្លួន ឬគ្មានលទ្ធភាពដោះស្រាយ ឬកាត់កងស្ថានភាពបំណុលមួយដែលជាលទ្ធផលគ្រឹះស្ថាន ឬក្រុមហ៊ុន នោះត្រូវបានចាត់ទុកថាត្រូវបានខកខាន មិនគោរពតាមកិច្ចសន្យាដោយអ្នកចូលរួមទីផ្សារដ៏ទៃទៀត ។ ហានិភ័យសន្ទនីយភាព ឬសាច់ប្រាក់ងាយស្រួល ត្រូវគិតទាំងសាច់ប្រាក់ជា រូបិយប័ណ្ណ និងរូបិយវត្ថុ និងទាំងទ្រព្យសកម្មចុះបញ្ជី ឬជួញដូរផ្សេងៗដែលគ្រឹះស្ថាន ឬក្រុមហ៊ុនកំពុងមានប្រតិបត្តិការ ។

**១.៧.៧. ហានិភ័យឯកសារ** ( Documentation Risk )

ហានិភ័យឯកសារ គឺជាហានិភ័យដែលកើតឡើងជាញឹកញាប់ចំពោះសកម្មភាពអាជីវកម្ម និងការរសនៅប្រចាំថ្ងៃ ។ ហានិភ័យនេះ កើតឡើងដោយសារតែភាពមិនស្របច្បាប់ នៃឯកសារ ភាពមិនលេញ នៃការបំពេញពត៌មាន ដែលនាំអោយឯកសារមួយមិនមានសុពលភាពចំពោះមុខច្បាប់។

**១.៧.៨. ហានិភ័យប្រមូលផ្តុំ** ( Concentration Risk )

ហានិភ័យប្រមូលផ្តុំ ជាហានិភ័យដោយផ្ទាល់ ឬដោយប្រយោល ដែលបណ្តាលមកពីហានិភ័យ ចំពោះសមភាគី/ក្រុម ឬសមភាគីពាក់ព័ន្ធផ្សេងៗទៀតតែមួយ ចំពោះអ្នកចេញផ្សាយតែមួយនៃមូលបត្រចំពោះវិស័យសេដ្ឋកិច្ច/តំបន់ភូមិសាស្ត្រ និងប្រទេសតែមួយ និងចំពោះប្រភេទទ្រព្យ

សកម្ម ឬវត្ថុបញ្ចាំណាមួយ ឬជាហានិភ័យដែលកើតឡើងពីហានិភ័យធំៗ ចំពោះសមភាគីមួយ ដែលគ្រឹះស្ថាន ឬក្រុមហ៊ុនមានប្រតិបត្តិការជាមួយ ដើម្បីកាត់បន្ថយហានិភ័យសំខាន់ៗ ។

# ជំពូកទី ២ ស្ថានភាពទូទៅរបស់ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ មេហ្គាលីស៊ីង ភីអិលស៊ី

## ២.១. ទិដ្ឋភាពទូទៅនៃក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ មេហ្គាលីស៊ីង ភីអិលស៊ី[12]

ក្រុមហ៊ុន មេហ្គាលីស៊ីង ភីអិលស៊ី ជាក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ ដែលត្រូវបានបង្កើតឡើង ក្រោមការសហការគ្នារវាង ក្រុមហ៊ុនមេហ្គាហ្សាន់ លីមីតធីត និង ក្រុមហ៊ុន លក្សីប្រាយម៍ អិនវេស មិន ក្នុងឆ្នាំ ២០១៣ និង បានទទួលអជ្ញាប័ណ្ណអនុញ្ញាតអោយធ្វើអាជីវកម្ម ពីធនាគារជាតិនៅ ឆ្នាំ ២០១៤ ។ នៅឆ្នាំ ២០១៣ គ្រឹះស្ថាន បានបើកតំណើរការតំបន់ប្រតិបត្តិការរបស់ខ្លួន នៅទីក្រុង ភ្នំពេញ ដែលមានបុគ្គលិកសរុបរួមទាំង គណៈគ្រប់គ្រង ចំនួន ២៤ នាក់ ក្នុងនោះមានមន្ត្រី ឥណ ទាន ចំនួន ១៧ នាក់ ហើយមកដល់ ឆ្នាំ ២០១៧ នេះ គ្រឹះស្ថានបានពង្រីកតំបន់ប្រតិបត្តិការ របស់ ខ្លួនទៅខេត្តក្រុងមួយចំនួន នៅទូទាំងប្រទេសដូចជា ៖ ភ្នំពេញ បាត់ដំបង សៀមរាប និងបន្ទាយ មានជ័យ ខេត្តព្រះសីហនុ និងខេត្តត្បូងឃ្មុំ ព្រមទាំងខេត្តកំពុងចាម កណ្ដាល ប៉ៃលិន ស្រុក បាធា យ ក្រឡាញ់ ពួក សូត្រនិគមន៍ និងព្រៃនប់ ។ ដើម្បីបង្ករលក្ខណៈ ងាយស្រួលដល់អតិថិជន និង សាធារណៈជនដែលមានកំណើនជាលំដាប់ ព្រមទាំងបង្កើតបរិស្ថានការងារល្អប្រសើរសម្រាប់ បុគ្គលិក ។

នៅថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ ២០១៥ ក្រុមហ៊ុនធ្វើការកែប្រែលក្ខន្តិកៈ ដើម្បីបង្កើនដើមទុន របស់ ក្រុមហ៊ុនពី ៤០០,០០០ដុល្លារ ទៅ ១,៤០០,០០០ ដុល្លារអាមេរិក តាមរយៈការបោះផ្សាយភាគហ៊ុន បន្ថែមចំនួន ១,០០០,០០០ ហ៊ុន ដែលមានតម្លៃចារឹក ១ដុល្លារក្នុង ១ហ៊ុន ។ ហើយក្នុងពេលនោះ ដែរ ក្រុមហ៊ុនបានបង់នូវដើមទុន បន្ថែមចំនួន ៣៥០,០០០ ដុល្លារអាមេរិក ដែលធ្វើអោយដើមទុន បានបង់របស់ ក្រុមហ៊ុនកើនពី ៤០០,០០០ ដុល្លារ ទៅ ៧៥០,០០០ ដុល្លារអាមេរិក ។ ការកែប្រែ លក្ខន្តិកៈរបស់ក្រុមហ៊ុន ត្រូវបានអនុម័តពីក្រសួងពាណិជ្ជកម្មនៅថ្ងៃទី ១៣ ខែមករា ឆ្នាំ ២០១៦ ។

យោងតាមរបាយការណ៍សនវកម្ម ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៦ នេះ ក្រុមហ៊ុន មានទ្រព្យ សកម្ម សរុបចំនួន ៩,៧៤៧,១៧២ ដុល្លារ អាមេរិក និងបំណុលសរុប ចំនួន ៧,៤១១,៥៨៩ ដុល្លារ អាមេរិក និង ដើមទុនសរុបចំនួន ២,៣៣៥,៥៨៣ ដុល្លារអាមេរិក ។ ហើយក្នុងនោះ ចំពោះសាខា ភ្នំពេញ មាន សមតុល្យភតិសន្យាហិរញ្ញវត្ថុ សរុបចំនួន ២, ៦៨៨,៧៩៦.៦៥ ដុល្លារ និងអតិថិជន ចំនួន ១,០៥៩ នាក់ ដែលបានប្រើប្រាស់សេវាភតិសន្យាហិរញ្ញវត្ថុ ។ គិតត្រឹមឆ្នាំ ២០១៧ ក្រុមហ៊ុន

[12] របាយការណ៍សវនកម្មឯករាជ្យ,២០១៦, ទំព័រទី ១០

ភតិសន្យាហិរញ្ញវត្ថុ មេហ្គាលីស៊ីង សាខាភ្នំពេញមាន បុគ្គលិកសរុបចំនួន ៣១ នាក់ ក្នុងនោះ បុគ្គលិកប្រុសចំនួន ២២ នាក់ និងស្រីចំនួន ៩ នាក់ ។

## ២.២. ចក្ខុវិស័យ បេសកម្ម និងតម្លៃស្នូលរបស់ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ មេហ្គាលីស៊ីង ភីអិលស៊ី

### ២.២.១. ចក្ខុវិស័យ

ក្រុមហ៊ុន មានចក្ខុវិស័យ ដ៏រឹងមាំមួយគឺ[13]៖ មេហ្គាលីស៊ីង ភីអិលស៊ី ជាគ្រឹះស្ថានផ្តល់សេវាហិរញ្ញវត្ថុ ឈានមុខគេនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

### ២.២.២. បេសកកម្ម

បេសកកម្ម របស់ក្រុមហ៊ុនមេហ្គាលីស៊ីង ភីអិលស៊ី គឺ ៖ មេហ្គាលីស៊ីង មានបេសកកម្ម ក្នុងការផ្តល់សេវាកម្មហិរញ្ញវត្ថុ ដើម្បីបំពេញតម្រូវការរបស់អតិថិជន ទន្ទឹមគ្នា នឹងការបង្កើតគុណតម្លៃដល់ភាគទុនិក និងអ្នកពាក់ព័ន្ធ ផ្សេងៗទៀត ។

### ២.២.៣. តម្លៃស្នូល

ក្រុមហ៊ុន មេហ្គាលីស៊ីង ភីអិលស៊ី មានតម្លៃស្នូលរបស់ខ្លួនក្នុងការប្រកបអាជីវកម្ម របស់ខ្លួនដល់អតិថិជន ជាពិសេសដើម្បីបង្កើតអោយមានបរិយាកាសការងារល្អប្រសើរសម្រាប់បុគ្គលិក។ តម្លៃស្នូលរបស់ក្រុមហ៊ុនរួមមាន៖

- ✓ សុចរិតភាព
- ✓ ធ្វើការងារជាក្រុម
- ✓ គណនេយ្យភាព
- ✓ ការគោរពគ្នាទៅវិញទៅមក

## ២.៣. អត្តសញ្ញាណ របស់គ្រឹះស្ថាន

### ២.៣.១. ផ្លាកសញ្ញា និង នាមករណ៍

ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ មេហ្គាលីស៊ីង ភីអិលស៊ី

**Mega leasing Plc.**

[13] នាយកដ្ឋានធនធានមនុស្ស, ការបណ្តុះបណ្តាលបុគ្គលិកថ្មីឆ្នាំ ២០១៧, ទំព័រទី ១,២

**២.៣.២. រូបសញ្ញា**[14]

ក. រូបមានរាងជា បួនជ្រុង ដោយផ្ទៃខាងក្នុងមានអក្សរ M និង សញ្ញា √ ។

ខ. មានពណ៌ខៀវ និង ពណ៌បៃតង ។

**២.៣.៣. អត្ថន័យ**[15]

ក. តួអក្សរ M : តំណាងអោយពាក្យ មេហ្គា មានន័យថា ធំសម្បើមអស្ចារ្យ និងមានការរីកចម្រើនលូតលាស់ជាលំដាប់ ។

ខ. សញ្ញា √ : មានន័យថា ក្រុមហ៊ុន ផ្តល់នូវទំនុបចិត្តខ្ពស់ដល់អតិថិជនរបស់ខ្លួន ។

គ. ពណ៌ខៀវ: តំណាងអោយភាពរឹងមាំ និងនិរន្តភាព

ឃ. ពណ៌បៃតង: តំណាងអោយភាពរីករាយការធ្វើអោយប្រសើរឡើងនូវលក្ខខណ្ឌជីវភាពកាន់ តែប្រសើររបស់អតិថិជនទាំងឡាយ កើតចេញពីការប្រើប្រាស់ សេវាកម្មរបស់ក្រុមហ៊ុន មេហ្គា លីស៊ីង ភីអិលស៊ី ។

## ២.៤. រចនាសម្ព័ន្ធ

ខាងក្រោមនេះជារចនាសម្ព័ន្ធ នៃក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ មេហ្គា សាខាភ្នំពេញ៖




នៅក្នុងសាខាភ្នំពេញមានបុគ្គលិកសរុបចំនួន ៣១ នាក់ ក្នុងនោះមាន ប្រធានមន្រ្តីឥណទាន ៥ នាក់ មន្រ្តីឥណទាន ១៦ នាក់ មន្រ្តីផ្នែកលក់ ១នាក់ ហេរញ្ញិក ៦ នាក់ បេឡាករ ១នាក់ គណនេយ្យករ ១ នាក់ និង អ្នកអនាម័យ ១ នាក់ ។

## ២.៥. តួនាទី និងភារៈកិច្ចរបស់ផ្នែកនិមួយៗ

នៅក្នុង ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ មេហ្គាលីស៊ីង ភីអិលស៊ី សាខាភ្នំពេញ រួមទាំងអនុសាខា

[14]មន្រ្តីបណ្តុះបណ្តាលធនធានមនុស្ស, ការពណ្តុះបណ្តាលបុគ្គលិកថ្មី, ២០១៧, ស្លាយទី ២

[15] មន្រ្តីបណ្តុះបណ្តាលធនធានមនុស្ស, ការពណ្តុះបណ្តាលបុគ្គលិកថ្មី, ២០១៧,ស្លាយទី៣

ចំនួន បួនទៀត នាពេលបច្ចុប្បន្ននេះមានបុគ្គលិកចំនួន ដែលមានតួនាទី និភារៈកិច្ចរៀងៗ ទៅតាមផ្នែកខុសៗគ្នា៖

### ២.៥.១. ប្រធានសាខា

ប្រធានសាខាមានតួនាទីសំខាន់ជាងគេ នៅក្នុងការគ្រប់គ្រងប្រតិបត្តិការទាំងអស់របស់សាខាភ្នំពេញ ។ ប្រធានសាខា គឺជាអ្នករៀបចំផែនការយុទ្ធសាស្រ្ត និងចាត់ចែងដឹកនាំការងារគ្រប់ផ្នែកនៅក្នុងសាខារួមមាន៖ កិច្ចការធនធានមនុស្ស ទីផ្សារ ភតិសន្យាហិរញ្ញវត្ថុ គណនេយ្យហិរញ្ញវត្ថុ បច្ចេកទេសពត៌មាន ច្បាប់ និងអភិបាលការងារ សាខា ។ លើសពីនេះទៀត ប្រធានសាខា ត្រូវធ្វើការត្រួតពិនិត្យការអនុវត្តន៍ផែនការងារគ្រប់ផ្នែក ដោះស្រាយ នូវរាល់បញ្ហាដែលបានកើតឡើង និងតម្រង់ទិសការងារពេលដំណើរការអនុវត្តន៍ផែនការអោយបានត្រឹមត្រូវ ទាន់ពេលវេលា និងរៀបចំរបាយការណ៍ ផ្ញើរជូនទៅប្រធានផ្នែកភតិសន្យាហិរញ្ញវត្ថុ ។

### ២.៥.២. ប្រធានមន្ត្រីឥណទាន ឬប្រធានអនុសាខា

ប្រធានមន្ត្រីឥណទានគឺជាអ្នក បែងចែក ដឹកនាំ និងគ្រប់គ្រងមន្ត្រីឥណទាន ដោយផ្ទាល់ ។ ប្រធានឥណទាន គឺជា អ្នកហ្វឹកហ្វឺន បណ្តុះបណ្តាល និងជាអ្នកចូលរួម ដោយផ្ទាល់ជាមួយបុគ្គលិកដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់គាត់ ឬមន្ត្រីឥណទាន ដើម្បីធ្វើយ៉ាងណា អោយការអនុវត្តន៍ការងាររបស់មន្ត្រីឥណទាន ឬបុគ្គលិកក្រោមការគ្រប់គ្រងរបស់គាត់ មានប្រសិទ្ធិពល និងមានប្រសិទ្ធិភាព ។ លើសពីនេះទៀតប្រធានមន្ត្រីឥណទាន មានតួនាទី រៀបចំរបាយការណ៍ ផ្សេងៗជូនប្រធានសាខា ឬអនុប្រធានសាខា ។

### ២.៥.៣. មន្ត្រីឥណទាន

មន្ត្រីឥណទាន គឺជាឆ្អឹងខ្នង ក្នុងការតំណើរការប្រតិបត្តិការអាជីវកម្ម ភតិសន្យាហិរញ្ញវត្ថុ មួយអោយទទួលបានជោគជ័យ ។ មន្ត្រីឥណទាន គឺជាអ្នកអនុវត្តនូវរាល់ផែនការប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុ ។ បុគ្គលិកផ្នែកនេះមានតួនាទី ផ្សព្វផ្សាយ ប្រឹក្សាយោបល់ដល់អតិថិជន រៀបចំ និងបញ្ចេញភតិសន្យាហិរញ្ញវត្ថុអោយបានគ្រប់ទៅតាមផែនការដែលបានកំណត់ដោយប្រធានរបស់ខ្លួន និងទប់ស្កាត់ ដោះស្រាយនៅរាល់ភតិសន្យាហិរញ្ញវត្ថុឡាយណាដែលមានបញ្ហា ។

### ២.៥.៤. គណនេយ្យសាខា ( Branch Account )

គណនេយ្យសាខា មានតួនាទីគ្រប់គ្រង នូវរាល់ប្រតិបត្តិការហិរញ្ញវត្ថុទាំងអស់របស់សាខា រួមមាន៖ ការរៀបចំឯកសារ និងកត់ត្រា ចំណូលចំណាយដែលបានកើតឡើង និង ជាអ្នកដឹកនាំគ្រប់គ្រងបេឡាករ និងហិរញ្ញឹកដោយផ្ទាល់ ។

### ២.៥.៥. បេឡាករ និងហេរញ្ញិក

នៅក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ មេហ្គា លីស៊ីង ភីអិលស៊ី សាខាភ្នំពេញមានបេឡាករ មួយនាក់ និងហេរញ្ញិក ប្រាំមួយ នាក់ ។ ចំពោះបេឡាករ មានតួនាទី គ្រប់គ្រងរាល់ប្រតិបត្តិការសាច់ប្រាក់ទាំងអស់របស់សាខា រក្សាទុកសាច់ប្រាក់អោយមានប្រសិទ្ធិភាព និងសុវត្ថិភាព ដាក់ និងដកសាច់ប្រាក់ពីគណនេយ្យធនាគាររបស់ក្រុមហ៊ុន ។ លើសពីនេះទៀត បេឡាករ មានតួនាទី រក្សាទុកនូវរាល់ឯកសារភតិសន្យាហិរញ្ញវត្ថុទាំងអស់ របស់សាខាភ្នំពេញ ទាំងឯកសារភតិសន្យាហិរញ្ញវត្ថុ ( Lease File ) និង ទ្រព្យធានា ឬបញ្ចាំផ្សេងៗ (Collateral ) អោយមានប្រសិទ្ធភាព និងអនុលោមទៅតាមគោលនយោបាយរក្សាទុក ឯកសារភតិសន្យាហិរញ្ញវត្ថុ របស់ក្រុមហ៊ុន។ ចំពោះហេរញ្ញិក មានតួនាទី រៀបចំឯកសារបញ្ចេញសាច់ប្រាក់ ទៅអោយអតិថិជន ( Lease disbursement ) ឬមន្ត្រីឥណទាន និងប្រមូលប្រាក់ឈ្នួល ពីអតិថិជនរួចបញ្ចូលទិន្នន័យទៅក្នុងប្រព័ន្ធរបស់ក្រុមហ៊ុន អោយបានត្រឹមត្រូវ និងគ្រប់គ្រាន់ ។ លើសពីនេះទៀត ហេរញ្ញិក មានតួនាទីផ្តល់សេវាប្រឹក្សាយោបល់ អំពីសេវាកម្មរបស់ក្រុមហ៊ុនទៅអតិថិជនទៀងផង៕

## ២.៦. តំបន់ប្រតិបត្តិការ សាខាភ្នំពេញ

ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ មេហ្គា លីស៊ីង សាខាភ្នំពេញត្រូវបានបង្កើតឡើងស្របពេលដែលក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ មេហ្គាលីស៊ីង ភីអិលស៊ីត្រូវបានបង្កើតនៅឆ្នាំ ២០១៣ ដើម្បីធ្វើប្រតិបត្តិការ ផ្តល់សេវាភតិសន្យាហិរញ្ញវត្ថុ ។ ដោយក្រុមហ៊ុនបានមើលឃើញពីតម្រូវការទីផ្សារលើវិស័យភតិសន្យាហិរញ្ញវត្ថុមានការកើនឡើង និងដើម្បីផ្តល់សេវាកម្មជូនអតិថិជនអោយកាន់តែងាយស្រួល ក្រុមហ៊ុន បន្តបើកអនុសាខាចំនួន បួនបន្ថែមទៀត ដែលមានទីតាំងដូចខាងក្រោមៈ

### ២.៦.១. ទីតាំងសាខាភ្នំពេញ

- ✓អាស័យដ្ឋាន : វិថីចំការដូង ( ២១៧ ) រាជធានីភ្នំពេញ
- ✓ទូរស័ព្ទ : ០៦៩ ៧៨១ ៦៦៦




( រូបភាពទី២ អាគារសាខាភ្នំពេញ )

### ២.៦.២. អនុសាខាគីរីរម្យ

អនុសាខា គីរីរម្យ គឺជាអនុសាខាមួយដែលស្ថិតនៅក្រោមអាណាព្យាបាល របស់សាខាភ្នំពេញដែលមានទីតាំងដូចខាងក្រោម៖

✓អាស័យដ្ឋាន : ស្ថិតនៅអាគារលេខ៦៧ ជាន់ទីផ្ទាល់ដី ផ្លូវ ១២៥ សង្កាត់វាលវង់ ខណ្ឌ ៧មករា រាជធានីភ្នំពេញ




( រូបទី៣ អាគារអនុសាខាគីរីរម្យ )

✓ទូរស័ព្ទ : ០២៣ ២១៤ ៧៥៦

### ២.៦.៣. អនុសាខាតាខ្មៅ

អនុសាខាតាខ្មៅ ជាអនុសាខាមួយដែលស្ថិតនៅក្រោមអាណាព្យាបាល របស់សាខាភ្នំពេញ ដែលមានទីតាំងដូចខាងក្រោម ៖

- ✓ អាស័យដ្ឋាន : ភូមិតាក្តុល សង្កាត់ តាក្តុល ខណ្ឌតាខ្មៅ ខេត្តកណ្តាល
- ✓ ទូរស័ព្ទ : ០៦៩ ៨៤៥ ៦៦៦

### ២.៦.៤. អនុសាខាខ្សាច់កណ្តាល

អនុសាខាខ្សាច់កណ្តាល គឺជាអនុសាខា ដែលស្ថិតនៅក្រោមអាណាព្យាបាល របស់សាខាភ្នំពេញ ដែលមានទីតាំងដូចខាងក្រោម៖

- ✓ អាស័យដ្ឋាន : ភូមិព្រៃកតាម៉ាក់ ឃុំ ព្រៃកតាម៉ាក់ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល




- ✓ ទូរស័ព្ទ : ០៦៩ ៧៨១៦៦៦

(រូបទី ៤ អាគារអនុសាខាខ្សាច់កណ្តាល)

### ២.៦.៥. អនុសាខាបែកចាន

អនុសាខាបែងចាន ក៏ជាអនុសាខាដែលស្ថាននៅក្រោមអាណាព្យាបាល សាខាភ្នំពេញដែរ ដែលមានទីតាំងដូចខាងក្រោម៖

- ✓ អាស័យដ្ឋាន : ផ្ទះលេខ ២៨០ ភូមិ បែងចាន ឃុំបែង ស្រុកអង្គស្នួល ខេត្តកណ្តាល
- ✓ ទូរស័ព្ទលេខ : ០៦៩ ៧៨១ ៦៦៦




( រូបទី ៥ អាគារអនុសាខា បែងចាន )

## ២.៧. សេវាកម្ម និង ផលិតផលភតិសន្យាហិរញ្ញវត្ថុ

សេវាភតិសន្យាហិរញ្ញវត្ថុ គឺជាសេវាកម្មតែមួយគត់ របស់ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ មេហ្គាលីស៊ីង ភីអិលស៊ី ។ ភតិសន្យាហិរញ្ញវត្ថុ គឺជាទ្រព្យសកម្មដ៏រឹងមាំ របស់ក្រុមហ៊ុនមេហ្គា ភីអិលស៊ី ដូចនេះការផ្តល់សេវាភតិសន្យាហិរញ្ញវត្ថុ ត្រូវតែមានលក្ខណៈច្បាស់លាស់ និងសុក្រិត មុននឹងផ្តល់ជូន ។ ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ បាន និងកំពុងផ្តល់សេវាមួយចំនួន រួមមាន៖ ភតិសន្យាហិរញ្ញវត្ថុលើរថយន្តទេសចរណ៍ ភតិសន្យាហិរញ្ញវត្ថុលើរថយន្តដឹកទំនិញ គ្រឿងចក្រកសិកម្ម គ្រឿងចក្រធនធ្ងន់ ទោចក្រយានយន្ត គ្រឿងសង្ហារឹម និងភតិសន្យាហិរញ្ញវត្ថុលើ គ្រឿងអេឡិចត្រូនិច ប៉ុន្តែខ្ញុំបាទ បានយកមកសិក្សាស្រាវជ្រាវ ក្នុងរបាយការណ៍ចុះកម្មសិក្សានេះតែ បីផលិតផលប៉ុណ្ណោះគឺ ភតិសន្យាហិរញ្ញវត្ថុលើ រថយន្តទេសចរណ៍ ទោចក្រយានយន្ត និងរថយន្តដឹកទំនិញ។

### ២.៧.១.ភតិសន្យាហិរញ្ញវត្ថុលើរថយន្តទេសចរណ៍

ដើម្បីសម្រេចនូវបេសកម្ម និងទស្សនៈវិស័យរបស់ខ្លួន ក្រុមហ៊ុនបានបង្កើតផលិតផលភតិសន្យាហិរញ្ញវត្ថុមួយចំនួនសម្រាប់បំពេញតម្រូវការ និងជួយសម្រួលដល់ស្ថានភាពសេដ្ឋកិច្ចរបស់អតិថិជនផងដែរ។ ដូចគ្នានេះដែរផលិតផលភតិសន្យាហិរញ្ញវត្ថុលើរថយន្តទេសចរណ៍ ក៏ត្រូវបានបង្កើតឡើង ដើម្បីជួយដល់ អតិថិជនដែលមានបំណង និងតម្រូវការលើសម្ភារៈនេះ ។ អតិថិជនអាចធ្វើការស្នើសុំភតិសន្យាហិរញ្ញវត្ថុលើរថយន្តទេសចរណ៍គ្រប់ប្រភេទដែលបាន កំណត់ដោយរដ្ឋាភិបាល ។

### ២.៧.២. ភតិសន្យាហិរញ្ញវត្ថុលើរថយន្តដឹកទំនិញ

ដោយមើលឃើញថា តម្រូវការលើរថយន្តដឹកទំនិញមានការកើនឡើង ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ មេហ្គាលីស៊ីង ភីអិលស៊ីបានបង្កើតអោយមានសេវាភតិសន្យាហិរញ្ញវត្ថុលើ រថយន្តដឹកទំនិញ ដើម្បីសម្រួលដល់អតិថិជនដែលមិនមានលទ្ធភាពទិញសម្ភារៈនេះមកប្រើប្រាស់ ក្នុងអាជីវកម្មរបស់ខ្លួន និងធ្វើអោយសេដ្ឋកិច្ចគ្រួសាររបស់ប្រជាជនកម្ពុជាកាន់តែប្រសើរឡើងតាមរយៈការផ្តល់សេវាភតិសន្យាហិរញ្ញវត្ថុនេះ ។

### ២.៧.៣. ភតិសន្យាហិរញ្ញវត្ថុលើ ទោចក្រយានយន្ត

ទោចក្រយានយន្ត គឺជាឧបករណ៍ធ្វើដំណើរដែលមានការពេញនិយមបំផុត ពីសំណាក់ប្រជាជន ប្រជាជនកម្ពុជា នាពេលបច្ចុប្បន្ន ហើយក៏ជាប្រភេទ នៃមធ្យោបាយធ្វើដំណើរដែលកំពុងតែមានតម្រូវខ្ពស់បំផុត ។ នេះជាហេតុនាំអោយ មានក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុមេហ្គាលីស៊ីង បង្កើត និង ផ្តល់សេវាភតិសន្យាហិរញ្ញវត្ថុលើទោចក្រយានយន្តដែលបានកំណត់ដោយរដ្ឋាភិបាលដល់អតិថិជន ។

**ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ នឹងផ្តល់ភាពងាយស្រួល ដល់លោកអ្នក**

តទៅនេះដើម្បីទទួលបានសេវាភតិសន្យាហិរញ្ញវត្ថុ ទាំងអស់របស់ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ មេហ្គាលីស៊ីង ភីអិលស៊ី លោកអ្នកគ្រាន់តែអនុវត្តនូវជំហ៊ានងាយៗ ដូចខាងក្រោម៖

- ✓ លោកអ្នកគ្រាន់តែទៅរកមើលសម្ភារៈទាំងឡាយណាដែលលោកអ្នកត្រូវការ និងពេញចិត្ត រួចធ្វើការចរចាតម្លៃជាមួយអ្នកលក់ រួចរាល់ហើយ លោកអ្នកអាចជួបបុគ្គលិករបស់ក្រុមហ៊ុនមេហ្គា ដែលចុះនៅតាមភូមិ ឬនៅទីស្នាក់ការរបស់ក្រុមហ៊ុនដែលនៅជិតលោកអ្នកបំផុត
- ✓ ដាក់ពាក្យស្នើសុំសេវាភតិសន្យាហិរញ្ញវត្ថុ ជាមួយមន្រ្តីភតិសន្យាហិរញ្ញវត្ថុ នូវចំនួនទឹកប្រាក់ដែលស្នើសុំភតិសន្យាហិរញ្ញវត្ថុ និងរយៈពេលប្រើប្រាស់
- ✓ ផ្តល់ពត៌មានងាយៗ និងឯកសារមួយចំនួនអោយបុគ្គលិក មេហ្គាលីស៊ីង ដើម្បីអោយបុគ្គលិកធ្វើការបំពេញឯកសារភតិសន្យាហិរញ្ញវត្ថុជូនលោកអ្នក
- ✓ អ្នកនៅលីវក៏អាចស្នើសុំសេវាភតិសន្យាហិរញ្ញវត្ថុនេះពីក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ មេហ្គាលីស៊ីង ភីអិលស៊ី បានដែរ គ្រាន់តែមានអ្នកធានាម្នាក់ទៅជាការស្រេច ។

# ជំពូកទី៣ ការគ្រប់គ្រងភតិសន្យាហិរញ្ញវត្ថុ របស់ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ មេហ្គាលីស៊ីង ភីអិលស៊ី សាខាភ្នំពេញ

## ៣.១. ការកំណត់ គោលការណ៍ ឬគោលនយោបាយលើ ភតិសន្យាហិរញ្ញវត្ថុ

ដើម្បីអោយការអនុវត្តន៍ការងារ ក្នុងការផ្តល់សេវាភតិសន្យាហិរញ្ញវត្ថុ ដល់អតិថិជនអោយកាន់តែមានប្រសិទ្ធិភាព ក្រុមហ៊ុនមេហ្គាលីស៊ីង បានរៀបចំគោលការណ៍ ឬគោលនយោបាយផ្សេង ៗ អោយសមស្របទៅនឹង តម្រូវការ និងតម្លៃទីផ្សារ លើសម្ភារៈដែលត្រូវបានកំណត់ និងផ្តល់ជូនដល់អតិថិជនតាមរយៈសេវាភតិសន្យាហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមេហ្គាលីស៊ីង ។ គោលការណ៍ឬ គោល នយោបាយភតិសន្យាហិរញ្ញវត្ថុ ត្រូវបានបត់បែនទៅតាមប្រភេទ នៃផលិតផលភតិសន្យាហិរញ្ញវត្ថុ របស់ក្រុមហ៊ុនមេហ្គាលីស៊ីង រួមមានដូចខាងក្រោមៈ

### ៣.១.១. ភតិសន្យាហិរញ្ញវត្ថុ លើរថយន្តទេសចរណ៍

ក្រុមហ៊ុនមេហ្គាបានកំណត់ នូវគោលការណ៍ ឬគោលនយោបាយលើផលិតផល ភតិសន្យាហិរញ្ញវត្ថុលើរថយន្តទេសចរណ៍នេះដូចខាងក្រោមៈ

- ✓ ផ្តល់ជូនគ្រប់អតិថិជនដែលមានបំណងប្រើប្រាស់សម្ភារៈនេះតាមរយៈសេវាភតិសន្យហិរញ្ញវត្ថុ ទាំងរូបវន្តបុគ្គល និងនីតិបុគ្គល
- ✓ទំហំភតិសន្យាហិរញ្ញវត្ថុ ពី ១,០០០ ដុល្លារ ទៅ ១០០,០០០ ដុល្លារអាមេរិក
- ✓រយៈពេលប្រើប្រាស់ភតិសន្យាហិរញ្ញវត្ថុ ពី ១ ឆ្នាំ ទៅ ៥ ឆ្នាំ
- ✓បន្ទុកហិរញ្ញវត្ថុ ១.៧% ទៅ ១.៩៩% ទៅក្នុងមួយខែ
- ✓របៀបបង់សង: បង់រំលស់ដើមការថេរ ជារៀងរាល់ខែ ( Fixed Payment )
- ✓កម្រៃរដ្ឋបាល: អាស្រ័យលើទំហំនៃការបង់រំលស់
- ✓អ្នកធានា: យ៉ាងតិចមួយនាក់
- ✓សាច់ប្រាក់បដិភាគ: អតិថិជនត្រូវមានប្រាក់បដិភាគស្មើនឹង ២០% នៃតម្លៃរថយន្តទេស ចរណ៍ដែលត្រូវបានស្នើសុំភតិសន្យាហិរញ្ញវត្ថុ ៕

### ៣.១.២. ភតិសន្យាហិរញ្ញវត្ថុលើរថយន្តដឹកទំនិញ

ក្រុមហ៊ុនមេហ្គាបានកំណត់ នូវគោលការណ៍ ឬគោលនយោបាយលើផលិតផល ភតិសន្យាហិរញ្ញវត្ថុលើរថយន្តដឹកទំនិញនេះមានដូចខាងក្រោមៈ

- ✓អតិថិជនអាចធ្វើការស្នើសុំសេវា ភតិសន្យាហិរញ្ញវត្ថុលើ រថយន្តដឹកទំនិញគ្រប់ប្រភេទ ដែលអាចផ្ទុកទម្ងន់ចាប់ពី ១.៥ តោនឡើងទៅ

- ✓អតិថិជនគោលដៅ: សម្រាប់អតិថិជនចាស់ ឬថ្មីដែលមានបំណង និងតម្រូវការសេវាភតិសន្យាហិរញ្ញវត្ថុលើរថយន្តដឹកទំនិញ
- ✓ទំហំភតិសន្យាហិរញ្ញវត្ថុលើផលិតផលនេះ ពី ៥០០ដុល្លារ ទៅ ៥០,០០០ ដុល្លារអាមេរិក
- ✓រយៈពេលនៃការប្រើប្រាស់ភតិសន្យាហិរញ្ញវត្ថុលើផលិតផលនេះ ពី ១ឆ្នាំទៅ ៥ឆ្នាំ
- ✓បន្ទុកហិរញ្ញវត្ថុ ពី ១.៤៥% ទៅ ១.៧% ដល់ក្នុងមួយខែ
- ✓បង់ប្រាក់ឈ្នួលជាប្រចាំខែ
- ✓កម្រៃរដ្ឋបាល: អាស្រ័យលើទំហំបង់រំលស់

### ៣.១.៣. ភតិសន្យាហិរញ្ញវត្ថុ លើទោចក្រយានយន្ត

ក្រុមហ៊ុនមេហ្គាបានកំណត់ នូវគោលការណ៍ ឬគោលនយោបាយលើផលិតផល ភតិសន្យាហិរញ្ញវត្ថុលើទោចក្រយានយន្តនេះមានដូចខាងក្រោមៈ

- ✓អតិថិជនគោលដៅៈ សម្រាប់អតិថិជនចាស់ និងថ្មី ដែលមានបំណង និងតម្រូវការប្រើប្រាស់លើទោចក្រយានយន្តតាមរយៈសេវាភតិសន្យាហិរញ្ញវត្ថុរបស់ក្រុមហ៊ុន មេហ្គាលីស៊ីង
- ✓អតិថិជនអាចធ្វើការបង់រំលស់គ្រប់ប្រភេទនៃទោចក្រយានយន្តដែលបានកំណត់ដោយរដ្ឋាភិបាល
- ✓ទំហំៈ ពី ១០០ ដុល្លារ ទៅ ៥,០០០ ដុល្លារអាមេរិក
- ✓រយៈពេលៈ ពី ១ ឆ្នាំ ទៅ ៤ ឆ្នាំ
- ✓បន្ទុកហិរញ្ញវត្ថុៈ ១.៧០% ទៅ ១.៩០% ក្នុងមួយខែ អត្រាការប្រាក់អាស្រ័យលើរយៈពេលនៃការប្រើប្រាស់សេវាភតិសន្យាហិរញ្ញវត្ថុនេះ
- ✓កម្រៃរដ្ឋបាលៈ កម្រៃរដ្ឋបាលគឺអាស្រ័យលើសាខានិមួយៗ ជាអ្នកកំណត់

### ៣.១.៤. ការជ្រើសរើសអតិថិជន

ការជ្រើសរើសអតិថិជន គឺជា គោលនយោបាយមួយយ៉ាងសំខាន់របស់ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុមេហ្គាលីស៊ីង ក្នុងការជ្រើសរើសអតិថិជន និងផ្តល់ភតិសន្យាហិរញ្ញវត្ថុ អោយចំគោលដៅដើម្បីចូលរួមលើកស្ទួយជីវភាពប្រជាជនកម្ពុជា អោយកាន់តែប្រសើរឡើង ។

#### ❖ លក្ខខណ្ឌអតិថិជន

ដើម្បីកាត់បន្ថយហានិភ័យ អតិថិជនត្រូវបំពេញ នូវលក្ខខណ្ឌមួយចំនួនដូចខាងក្រោម ដើម្បីទទួលបានសេវាភតិសន្យាហិរញ្ញវត្ថុ ពីក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ មេហ្គាលីស៊ីងៈ

- ✓មានអាយុពី ១៨ ឆ្នាំទៅ ៦០ ឆ្នាំ

✓ មានមុខរបរ ឬការងារស្របច្បាប់

✓ មានសញ្ជាតិខ្មែរ និងមិនដែលធ្លាប់ជាប់ទោសឧក្រិដ្ឋណាមួយ

✓ មានអាស័យដ្ឋានបច្ចុប្បន្នអចិន្ត្រៃយ៍និងមានលំនៅដ្ឋានក្នុងតំបន់ប្រតិបត្តិការយ៉ាងតិច ៣ខែ

✓ ស្ថានភាពគ្រួសារៈ

- ចំពោះអ្នកដែលរៀបការរួចទាំងប្តី និងប្រពន្ធត្រូវផ្តិតមេដៃរួមគ្នាលើឯកសារពាក់ព័ន្ធនឹងការបង់រំលស់ ឬភតិសន្យាហិរញ្ញវត្ថុ
- ចំពោះអ្នកនៅលីវ មេម៉ាយ ឬពោះម៉ាយ គឺត្រូវផ្តិតមេដៃចូលរួមពីសមាជិកគ្រួសារដែលមានចំណូល លើឯកសារភតិសន្យាហិរញ្ញវត្ថុ ឬបង់រំលស់

### ៣.១.៥. ការកំណត់សាច់ប្រាក់បដិភាគ

សាច់ប្រាក់បដិភាគ ប្រៀបដូចជា ទ្រព្យធានាដែលត្រូវបានដាក់ធានា ដើម្បីទទួលបានកម្ចី ពីធនាគារ ឬគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ។ ដូចនេះដើម្បីធានាសុវត្ថិភាព ភតិសន្យាហិរញ្ញវត្ថុដែលបានផ្តល់ជូនអតិថិជន ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ មេហ្គាលីស៊ីង គ្រប់អតិថិជនដែលចង់ប្រើប្រាស់ សេវាភតិសន្យាហិរញ្ញវត្ថុទាំងអស់ ត្រូវតែមានសាច់ប្រាក់បដិភាគយ៉ាងតិច ២០ ភាគរយ នៃតម្លៃសរុបសម្ភារៈនោះ ។

**ឧទាហរណ៍:** មីង យឿន បានដាក់ពាក្យស្នើសុំ សិទ្ធិប្រើប្រាស់លើ ម៉ូតូថ្មីមួយគ្រឿង តាមរយៈភតិសន្យាហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមេហ្គាលីស៊ីង ។ ទោចក្រយានយន្តនោះមានតម្លៃលើទីផ្សារ ស្មើ ១,៨០០ ដុល្លារ ។ តើគាត់ត្រូវមានសាច់ប្រាក់បដិភាគចំនួនប៉ុន្មានដើម្បីទទួលបានសេវាភតិសន្យាហិរញ្ញវត្ថុនោះពីក្រុមហ៊ុនមេហ្គាលីស៊ីង ?

**ដំណោះស្រាយ:** ដោយសម្ភារៈនោះមានតម្លៃ ១,៨០០ ដុល្លារ

➡ សាច់ប្រាក់បដិភាគដែលគាត់ត្រូវមាន = ១,៨០០ដុល្លារ * ០.២ = **៣៦០ ដុល្លារ**

### ៣.១.៦. ការកំណត់សមត្ថភាពអតិថិជន ក្នុងការបង់សង

គ្រប់អតិថិជនរបស់ក្រុមហ៊ុនមេហ្គាលីស៊ីងសាខាភ្នំពេញទាំងអស់ មានសិទ្ធិទទួល បានទំហំបង់រំលស់ ឬកម្ចីទៅតាមសមត្ថភាព ដែលអាចសងត្រលប់មកវិញបាន ។ អតិថិជនអាចធ្វើការបង់រំលស់ ឬកម្ចីបានចំនួនពីរ ក្នុងពេលតែមួយទោះបីមិនទាន់បង់រំលស់ ឬកម្ចីទីមួយដាច់ក៏ដោយ អោយតែអតិថិជននៅមានសមត្ថភាពសងត្រលប់មកវិញ ។ ទាំងចំណូលពីប្រាក់ខែ និងមុខរបរអតិថិជន និងអ្នករួមខ្ចីត្រូវបានរួមបញ្ចូលទៅក្នុងលំហូរសាច់ប្រាក់សម្រាប់ធ្វើការគណនាសមត្ថភាពបង់សងត្រលប់មកវិញ ។ ដើម្បីវាស់វែងសមត្ថភាពបង់សងរបស់អតិថិជន គឺតម្រូវអោយផលធៀប

រវាងសាច់ប្រាក់ដែលនៅសល់ក្រោយពីកាត់កងចំណាយទាំងអស់របស់អតិថិជនរួច ជាមួយនឹងប្រាក់ត្រូវបង់ប្រចាំខែ ត្រូវធំជាង ឬស្មើ ១.៥ មានន័យថា អតិថិជននៅមានសមត្ថភាពបង់សងត្រលប់ចំនួន១៥០ភាគរយ នៃប្រាក់ដែលត្រូវបង់សងប្រចាំខែ។ខាងក្រោមនេះជារូបមន្តៈ

**សមត្ថភាពបង់សង = ប្រាក់នៅសល់ពីចំណាយ / ប្រាក់ដែលត្រូវបង់ប្រចាំខែ**

**ឧទាហរណ៍:** ពូ សំ បានដាក់ពាក្យស្នើសុំ ទិញរថយន្តទេសចរណ៍មួយប្រភេទ តាមរយៈសេវាភតិសន្យាហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមេហ្គាលីស៊ីង ក្នុងតម្លៃ ១ ម៉ឺនដុល្លារ ហើយលោកពូមានលុយបដិភាគចំនួន ៤០០០ ដុល្លារដើម្បីចូលរួមទិញសម្ភារៈនោះ ដោយគាត់ត្រូវបង់ប្រាក់ចំនួន ៥០០ដុល្លារក្នុងមួយខែ ។ ពូ សំ ជាប្រធានគ្រប់គ្រងទូទៅ នៅក្រុមហ៊ុន មួយដែលគាត់ទទួលបានប្រាក់ខែ ចំនួន ១៨០០ ដុល្លារ ។ ក្នុងមួយខែគាត់ ចំណាយអស់ ១០០០ ដុល្លារ ។ ចូររកសមត្ថភាពបង់សងរបស់ពូ សំ ?

<u>ចំលើយ</u>

<u>បម្រាប់</u>

- ពូ សំ ស្នើសុំប្រើប្រាស់សេវាភតិសន្យាហិរញ្ញវត្ថុ លើរថយន្តទេសចរណ៍ ក្នុងតម្លៃ ១០,០០០ ដុល្លារ
- គាត់មានប្រាក់បដិភាគចំនួន ៤,០០០ ដុល្លារ
- ប្រាក់ចំណូលសរុប ១,៨០០ ដុល្លារអាមេរិក និង ចំណាយ ១០០០ ដុល្លារក្នុងមួយខែ

សមត្ថភាពបង់សង = ៨០០/៥០០ = ១.៦

ដូចនេះ សមត្ថភាពបង់សងត្រលប់របស់ពូ សំគឺ ១.៦ > ១.៥ ដូចនេះគាត់មានលក្ខណៈគ្រប់គ្រាន់ក្នុងការទទួលបានសេវាភតិសន្យាហិរញ្ញពីក្រុមហ៊ុនមេហ្គាលីស៊ីង ។

## ៣.២. ការផ្សព្វផ្សាយ

ការផ្សព្វផ្សាយពិតជា មានសារៈសំខាន់ខ្លាំងចំពោះអាជីវកម្ម ភតិសន្យាហិរញ្ញវត្ថុ របស់ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ មេហ្គាលីស៊ីង ដើម្បីអោយអតិថិជន បានស្គាល់ កំទ្រ និងប្រើប្រាស់សេវាកម្ម អោយកាន់តែច្រើនពីសំណាក់ប្រជាជនកម្ពុជា ។ ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ បានធ្វើផ្សព្វផ្សាយនៅផលិតផល របស់ខ្លួនតាមរយៈវិធីសាស្ត្រផ្សេងៗ ដូចជាៈ ប្រព័ន្ធទំនាក់ទំនងសង្គម ( Facebook,LinkedIn និងវេបសាយរបស់ក្រុមហ៊ុនផ្ទាល់) ការចុះផ្សព្វផ្សាយផ្ទាល់ដោយបុគ្គលិកមានមន្ត្រីទីផ្សារ និងមន្ត្រីឥណទាន ដោយធ្វើការផ្សព្វផ្សាយទៅតាមតំបន់មូលដ្ឋាននិមួយៗ របស់

ខ្លួន និងផ្សព្វផ្សាយទៅតាម កន្លែងផ្គត់ផ្គង់ និងការចាប់ដៃសហាការគ្នាផ្ដាច់មុខរវាងអ្នកផ្គតផ្គង់ និងក្រុមហ៊ុនមេហ្គាលីស៊ីង។ ការផ្សព្វផ្សាយ នេះជាកតព្វកិច្ចរបស់មន្ត្រីឥណទាន និងមន្ត្រីផ្នែកទីផ្សារសាខាភ្នំពេញ ។ ការផ្សព្វផ្សាយត្រូវបានបែងចែកជា ៣ ដំណាក់កាលធំៗ គឺ ដំណាក់កាលមុនពេលផ្សព្វផ្សាយ ពេលផ្សព្វផ្សាយ និងក្រោយពេលផ្សព្វផ្សាយ ។

### ៣.២.១. មុនពេលផ្សព្វផ្សាយ

តើមុនពេលផ្សព្វផ្សាយ មន្ត្រីឥណទាន ឬមន្ត្រីផ្នែកទីផ្សារ ត្រូវត្រៀមខ្លួនយ៉ាងដូចម៉េច ដើម្បីអោយការផ្សព្វផ្សាយអោយមានប្រសិទ្ធិភាព ? មន្ត្រីភតិសន្យាហិរញ្ញវត្ថុ ឬមន្ត្រីផ្នែកទីផ្សារត្រូវត្រៀមខ្លួនដូចខាងក្រោម មុននឹងចុះផ្សព្វផ្សាយ៖

- ✓ មន្ត្រីភតិសន្យាហិរញ្ញវត្ថុត្រូវតែធ្វើការសិក្សា និង វាយតម្លៃពីតំបន់គោលដៅ ដែលត្រូវចុះផ្សព្វផ្សាយ
- ✓ មន្ត្រីភតិសន្យាហិរញ្ញវត្ថុ ត្រូវរៀបចំផែនការផ្សព្វផ្សាយ ដូចជា កំណត់តំបន់គោលដៅ ចំនួនអតិថិជន ដែលត្រូវធ្វើការផ្សព្វផ្សាយអោយបានច្បាស់លាស់
- ✓ អ្នកផ្សព្វផ្សាយត្រូវធ្វើការរៀបចំសម្ភារៈជំនួយដល់ការផ្សព្វផ្សាយដូចជាលិខិតប័ណ្ណផ្សព្វផ្សាយនិងសម្ភារៈផ្សព្វផ្សាយផ្សេងៗទៀត ដែលត្រូវប្រើក្នុងពេលផ្សព្វផ្សាយ ព្រមទាំងឯកសារភតិសន្យាហិរញ្ញវត្ថុ
- ✓ អ្នកផ្សព្វផ្សាយ ត្រូវរៀបចំខ្លួន ដូចជាការស្លៀកពាក្យ ត្រូវយល់ដឹងអោយបានច្បាស់ ពីគោលនយោបាយផលិតផល និងក្រុមហ៊ុន មុននឹងធ្វើការចុះផ្សព្វផ្សាយ ។

### ៣.២.២. ក្នុងពេលផ្សព្វផ្សាយ

- ✓ មន្ត្រីឥណទាន ត្រូវចុះទៅជួបផ្ទាល់ជាមួយអតិថិជនគោលដៅ ក្នុងតំបន់គោលដៅ ព្រមទាំងពន្យល់ពីក្រុមហ៊ុន គោលបំណង និងពន្យល់ពីលក្ខណៈផលិតផលងាយៗដល់អតិថិជនគោលដៅរួមមាន៖
    - ➢ ប្រភេទផលិតផល និងលក្ខណៈនៃប្រភេទផលិតផលនិមួយៗ
    - ➢ លក្ខណៈសម្បត្តិអតិថិជនដែលអាចទទួលបានសេវាភតិសន្យាហិរញ្ញវត្ថុ
    - ➢ ឯកសារផ្សេងៗដើម្បីទទួលបានផលិតផល ភតិសន្យាហិរញ្ញវត្ថុ
    - ➢ បន្ទុកហិរញ្ញវត្ថុ ( អត្រាប្រាក់ ) និងការគណនា (ប្រសិនបើអតិថិជនចាប់អារម្មណ៍ក្នុងពេលផ្សព្វផ្សាយ ឬអតិថិជនចង់ដឹង )
    - ➢ លទ្ធភាពដែលអាចទទួលបានភតិសន្យាហិរញ្ញវត្ថុ

- ➢ វិធីសាស្ត្រក្នុងការបង់សងត្រលប់
- ➢ និងលក្ខខណ្ឌផ្សេងៗទៀត

✓ បំផុសគំនិតអោយអតិថិជនធ្វើការបង់រំលស់ ឬអោយអតិថិជនចាប់អារម្មណ៍ និង ប្រើប្រាស់សេវាកម្មភតិសន្យាហិរញ្ញវត្ថុណាមួយរបស់ក្រុមហ៊ុន ប៉ុន្តែប្រសិនបើអតិថិជនមានគោលបំណងចង់ប្រើប្រាស់ភតិសន្យាហិរញ្ញវត្ថុនៅពេលណាមួយក្រោយពីផ្សព្វផ្សាយ មន្ត្រីឥណទានត្រូវៈ

- ➢ បំពេញទម្រង់អតិថិជនមានគោលបំណង់ចង់ប្រើប្រាស់សេវាភតិសន្យាហិរញ្ញវត្ថុ
- ➢ មន្ត្រីឥណទានត្រូវស្នើសុំឯកសារដែលអាចធ្វើការស្នើសុំភតិសន្យាហិរញ្ញវត្ថុបាន ( ឯកសារថតចម្លង ) និងរូបថតពីអតិថិជន យកមករក្សាទុកមុន ដើម្បីងាយស្រួលរៀបចំឯកសារនៅពេលដែលអតិថិជនត្រូវការប្រើប្រាស់ភតិសន្យាហិរញ្ញវត្ថុ ។

### ៣.២.៣. ក្រោយពេលផ្សព្វផ្សាយ

បន្ទាប់ពីធ្វើការផ្សព្វផ្សាយរួច មន្ត្រីឥណទានត្រូវតែ ចុះហត្ថលេខាលើទម្រង់អតិថិជនដែលបានផ្សព្វផ្សាយ និងផ្តល់ជូនប្រធានមន្ត្រីភតិសន្យាហិរញ្ញវត្ថុដើម្បីពិនិត្យ រក្សាទុក និងរៀបចំជារបាយណ៍ជូនប្រធានសាខាត្រួតពិនិត្យ ជាប្រចាំខែ ។

មន្ត្រីឥណទានត្រូវធ្វើការទាក់ទង អតិថិជនដែលមានបំណងចង់ប្រើប្រាស់សេវា ភតិសន្យាហិរញ្ញវត្ថុ យ៉ាងហោចណាស់អោយបាន ៣ដង បន្ទាប់ពីបានធ្វើការផ្សព្វផ្សាយ ដើម្បីបំផុសគំនិតនិងជំរុញអតិថិជនបន្ថែមអោយប្រើប្រាស់សេវាកម្មរបស់ក្រុមហ៊ុន ។

## ៣.៣. ការវិភាគ និងវាយតម្លៃភតិសន្យាហិរញ្ញវត្ថុ

ដោយសារតែ ភតិសន្យាហិរញ្ញវត្ថុ គឺជា ទ្រព្យសកម្មដ៏រឹងមាំរបស់ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុមេហ្គាលីស៊ីង ភីអិលស៊ី ដូច្នេះគណគ្រប់គ្រងរបស់ក្រុមហ៊ុន ត្រូវធ្វើការរៀបចំ គោលការណ៍ និងនីតិវិធីអោយបានច្បាស់លាស់ ក្នុងការផ្តល់សេវាភតិសន្យាហិរញ្ញវត្ថុ អោយមានប្រសិទ្ធភាព ខ្ពស់ ។

### ៣.៣.១. ការប្រមូលពត៌មាន

ការប្រមូលពត៌មាន គឺជាកតព្វកិច្ចមួយយ៉ាងសំខាន់របស់ មន្ត្រីឥណទាន បន្ទាប់ពីអតិថិជនបានទាក់ទង និងដាក់ពាក្យស្នើសុំ ប្រើប្រាស់ភតិសន្យាហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ។ មន្ត្រីឥណទានត្រូវប្រមូលពត៌មានអោយបានគ្រប់គ្រាន់ និងត្រឹមត្រូវ នៃពត៌មានអតិថិជន ដែលបានដាក់ពាក្យស្នើ

សុំ ។

ពត៌មានអតិថិជនត្រូវបានបែងចែក ជាពីរប្រភេទ ធំៗគឺ៖ ពត៌មានហិរញ្ញវត្ថុ និងពត៌មានមិនមែន ជាហិរញ្ញវត្ថុ ។ ពត៌មានហិរញ្ញវត្ថុ រួមមាន៖ ប្រភពប្រាក់ចំណូល បរិមាណនៃប្រាក់ចំណូល និង ប្រភពចំណាយផ្សេងៗ ដែលជាកតព្វកិច្ចរបស់ អ្នកស្នើសុំ ។ ពត៌មានមិនមែនហិរញ្ញវត្ថុ រួមមាន៖ អត្តចរិក ការទំនាក់ទំនង ប្រវត្តិនៃការបង់សងប្រាក់ ចំណេះជំនាញវិជ្ជាជីវៈ និងពត៌មានផ្សេងៗដ៏ទៃទៀត ។

តាមរយៈការអង្កេតផ្ទាល់ ពីនីតិវិធី នៃការអនុវត្តន៏ការងារចុះប្រមូលពត៌មានអតិថិជន យើងឃើញថា មន្ត្រីឥណទាន ប្រមូលពត៌មាន បីប្រភពសំខាន់ៗ ដើម្បីកាត់បន្ថយហានិភ័យ ពត៌មាន ឬ ដើម្បីទទួលបាននូវភាពគ្រប់គ្រាន់ និងត្រូវនៃពត៌មានអតិថិជន ។ ប្រភពពត៌មាន សំខាន់ៗ ទាំង បី ប្រភពនោះរួមមាន៖ ការប្រមូលពត៌មានអតិថិជនពីអជ្ញាធរ អ្នកជិតខាង និងពីអតិថិជនផ្ទាល់ ។

### ៣.៣.២. ការការសិក្សា និងវាយតម្លៃអតិថិជន

ការសិក្សា និងវាយតម្លៃឥណទានភតិសន្យា ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ មេហ្គាលីស៊ីង សាខា ភ្នំពេញបានផ្អែកទៅលើលក្ខខណ្ឌសំខាន់ៗ ដូចខាងក្រោម៖ ការវាយតម្លៃលើ អត្តចរិករបស់ អតិថិជន ស្ថានភាពរសនៅ ស្ថានភាពមុខរបរ លំហូរសាច់ប្រាក់របស់អតិថិជន ទ្រព្យសម្បត្តិដាក់ធានា និងស្ថានភាពបំណុល របស់អតិថិជន ដែលអាចជះឥទ្ធិពលដល់ គុណភាពភតិសន្យាហិរញ្ញវត្ថុ ។

#### ៣.៣.២.១. ការវិភាគលើអត្តចរិក

ការសិក្សា និងវាយតម្លៃលើ អត្តចរិកនេះគឺដើម្បីកំណត់ពីឆន្ទៈ នៃការទូទាត់ប្រាក់ឈ្នួលរបស់ ភតិក: ។ ការសិក្សា និងវាយតម្លៃលើអត្តចរិកនេះ គឺជាកតព្វកិច្ចរបស់មន្ត្រីឥណទាន ប្រធាន មន្ត្រីឥណទាន និងអនុប្រធានសាខាភ្នំពេញ ក្នុងការអង្កេតលើអត្តចរិកអតិថិជនមុននឹងផ្តល់ ភតិសន្យាហិរញ្ញវត្ថុដល់អតិថិជន ។ ការសិក្សាលើអត្តចរិកនេះ មន្ត្រីឥណទាន ត្រូវចុះទៅជួប អង្កេតផ្ទាល់ និងសាកសួរអតិថិជន និងអ្នកដែលពាក់ព័ន្ធផ្សេងៗ ( អ្នកជិតខាង និងអាជ្ញាធរ ) ដោយ ពឹងផ្អែកលើ ៖

- ✓ ការអង្កេតអាកប្បកិរិយា៖ មន្ត្រីឥណទាន ត្រូវអង្កេតដោយផ្ទាល់នៅពេលចុះជួបអតិថិជន ដូចជា ការរៀបចំផ្ទះ ការនិយាយស្តី និងការរៀបចំខ្លួន ។

- ✓ការអង្កេតលើទំនួលខុសត្រូវ៖ មន្ត្រីឥណទានត្រូវតែ ត្រួតពិនិត្យលើតារាងបង់ប្រាក់ ប្រសិនបើអតិថិជនមានជាប់បំណុល ជាមួយស្ថានប័នផ្សេងថាតើ គាត់បង់បានទៀងទាត់ល្អដែរ ឬទេ ?
- ✓ការអង្កេតលើ ការទំនាក់ទំនង ៖ ការទំនាក់ទំនងនេះគឺដើម្បីបង្ហាញនូវអត្តចរិករបស់អតិថិជន ដោយការប្រាស្រ័យទាក់ទងក្នុងគ្រួសារ និងអ្នកជិតខាង ដែលនៅក្នុងតំបន់ដែលគាត់រសនៅ ។ ដូចនេះមន្ត្រីឥណទាន ត្រូវតែអង្កេត និងសាកសួរ ពីអ្នកជិតខាង និងអជ្ញាធរ ។

**៣.៣.២.២. ការវិភាគលើ ស្ថានភាពរសនៅ**

ការសិក្សានិងវាយតម្លៃលើស្ថានភាពរសនៅ គឺជាកត្តាមួយយ៉ាងសំខាន់ ដែលមន្ត្រីឥណទានត្រូវតែធ្វើការសិក្សាអោយច្បាស់លាស់ ដើម្បីធានាថា អតិថិជនពិតជាមានស្ថានភាពរសនៅល្អប្រសើរ ឬក៏មិនល្អប្រសើរ ? ការសិក្សា និងវាយតម្លៃលើស្ថានភាពរសនៅនេះ មន្ត្រីឥណទាន ត្រូវតែធ្វើការអង្កេតលើ ទ្រព្យសម្បត្តិទាំងអស់របស់អតិថិជន រួមមាន៖ ផ្ទះដី ឡាន ម៉ូតូ កង់ សាច់ប្រាក់សុទ្ធ សាច់ប្រាក់ក្នុងគណនីសន្សំ ទ្រព្យសកម្ម និងដើមទុនក្នុងអាជីវកម្ម របស់អតិថិជនជាដើម ។

**៣.៣.២.៣. ការវិភាគ លើសមត្ថភាពសងបំណុល**

គោលបំណងដ៏ធំរបស់ ភតិបតី គឺ រាល់ភតិសន្យាហិរញ្ញវត្ថុ ទាំងអស់ដែលបានផ្តល់ជូនអតិថិជន អាចមានលទ្ធភាពប្រមូលមកវិញបានគ្រប់ចំនួនដែលបានព្យាករណ៍ ។ សមត្ថភាពសងបំណុល ពិតជា ជះឥទ្ធិពលខ្លាំងលើគុណភាពភតិសន្យាហិរញ្ញវត្ថុទាំងមូល។ ប្រសិនបើអតិថិជនបាត់បង់សមត្ថភាពសងបំណុល នោះគុណភាពសងបំណុលរបស់ភតិក: ពិតជាធ្លាក់ចុះ ដែលធ្វើភតិបតីមានការខាតបង់ ។ ដូចនេះមន្ត្រីឥណទាន ត្រូវតែធ្វើការសិក្សាអោយបានច្បាស់លាស់ និងម៉ត់ចត់បំផុត លើកត្តាពីរដូចខាងក្រោម៖

- ✓ចំណូល៖ មន្ត្រីឥណទាន ត្រូវតែសិក្សាអោយបានត្រឹមត្រូវ នឹងគ្រប់គ្រាន់ ពីប្រភពចំណូលរបស់អតិថិជន ដើម្បីជៀសវាងពីការសម្រេចចិត្តខុស ឬបាត់បង់ឱកាស ក្នុងការរកប្រាក់ចំណេញ។ មន្ត្រីឥណទាន ត្រូវតែធ្វើការសិក្សាអោយច្បាស់ថា តើអតិថិជន មានប្រភពចំណូលប៉ុន្មាន ហើយមានបរិមាណប៉ុន្មានក្នុងមួយខែៗ ។ លើសពីនេះ មន្ត្រីឥណទាន ត្រូវសិក្សាអោយឃើញថា តើមុខរបរ ការងារ ឬអាជីវកម្ម របស់អតិថិជន ស្របច្បាប់ដែរ ឬទេ ? ថាតើ មុខរបរ ការងារ ឬអាជីវកម្ម នឹងមានការប្រែប្រួលខ្លាំង ឬក៏តិច ដំណើរការក្នុងរយ:ពេលវែង ឬក៏ខ្លី ?
- ✓ចំណាយ៖ ចំណាយពិតជាជះឥទ្ធិពលខ្លាំងដល់សមត្ថភាពសងបំណុលរបស់អតិថិជន ។

ប្រសិនបើអតិថិជន មិនចេះគ្រប់គ្រងចំណាយទេ ទោះបីគាត់មានចំណូលច្រើនក៏ មិនប្រាកដថា គាត់មានសមត្ថភាពទូទាត់បំណុលខ្ពស់ដែរ ឬមានលុយសល់ច្រើនដែរទេ ។ ដូច្នេះមន្ត្រីឥណទាន ត្រូវតែសិក្សាអោយបានគ្រប់គ្រាន់ និងត្រឹមត្រូវ ដើម្បីជៀសវាងនូវផលអវិជ្ជមានផ្សេងៗ ។ មន្ត្រីឥណទាន ត្រូវតែសិក្សាអោយបានដឹងថា តើ ក្នុងមួយខែ ៗ គាត់ចំណាយទៅណាខ្លះ និងចំនួនប៉ុន្មាន ? ថាតើគាត់មានជាប់កតព្វកិច្ច ទូទាត់បំណូលជាមួយនឹងស្ថានប័នផ្សេងដែរឬទេ ?

### ៣.៣.២.៤. ការវិភាគលើលក្ខខណ្ឌផ្សេងៗ

មានកត្តាជាច្រើន ដែលអាចជះឥទ្ធិពលដល់គុណភាពភតិសន្យាហិរញ្ញវត្ថុ ដូចជា អតិផរណា ភូមិឃុំគ្មានសុវត្ថិភាព បញ្ហានយោបាយ ការធ្លាក់ចុះនៃសេដ្ឋកិច្ច និងកត្តាផ្សេងៗទៀត ដែលអាចជះឥទ្ធិពលដល់សមត្ថភាពសងបំណុលរបស់អតិថិជន ។ ដូចនេះមន្ត្រីភតិសន្យាហិរញ្ញវត្ថុ តែងតែធ្វើការសិក្សា យ៉ាងយកចិត្តទុកដាក់បំផុត លើកត្តាជុំវិញមុខរបរ អាជីវកម្ម និងការងារ ដែលអាចជះឥទ្ធិពលអាក្រក់ដល់ចំណូលរបស់អតិថិជនដែលអាចធ្វើអោយចំណូលរបស់អតិថិជនធ្លាក់ចុះឬធ្វើអោយចំណាយប្រចាំថ្ងៃរបស់អតិថិជនមានការកើនឡើងខ្ពស់ ។

## ៣.៤. ការកំណត់សិទ្ធិ ក្នុងការអនុម័តភតិសន្យាហិរញ្ញវត្ថុ [16]

ការកំណត់សិទ្ធិអំណាច ក្នុងការអនុម័តភតិសន្យាហិរញ្ញវត្ថុ គឺជាគោលនយោបាយមួយដែលមានសារៈសំខាន់ ដើម្បីពង្រឹងគុណភាពភតិសន្យាហិរញ្ញវត្ថុ ដោយយោងទៅតាម មុខតំណែង និងបទពិសោធន៍របស់បុគ្គលិកម្នាក់ៗ ដូចខាងក្រោយះ

- ✓ប្រធានមន្ត្រីឥណទាន ឬប្រធានអនុសាខាមានសិទ្ធិអនុម័ត រហូតដល់ ១០០០ដុល្លារអាមេរិក ។ ប៉ុន្តែចំពោះប្រធានមន្ត្រីឥណទានមួយចំនួនដែលទទួលបានការអនុញ្ញាតនិងអនុម័ត ពីនាយក នៃនាយកដ្ឋានប្រតិបត្តិការ នោះគាត់នឹង មានសិទ្ធិពិសេសក្នុងការអនុម័តនូវភតិសន្យាហិរញ្ញវត្ថុ រហូតដល់ចំនួន ២០០០ ដុល្លារអាមេរិក ។
- ✓ប្រធានសាខា ឬនាយកសាខា មានសិទ្ធិអនុម័ត នូវទំហំភតិសន្យាហិរញ្ញវត្ថុរហូតដល់ ៣៥០០ ដុល្លារអាមេរិក ។ប៉ុន្តែចំពោះប្រធានសាខា ដែលមានសិទ្ធិពីសេសពួកគាត់ មានសិទ្ធិអនុម័តទំហំភតិសន្យាហិរញ្ញវត្ថុ រហូតដល់ ៥,០០០ ដុល្លារអាមេរិក
- ✓ប្រធានផ្នែកប្រតិបត្តិការ ភតិសន្យាហិរញ្ញវត្ថុ មានសិទ្ធិអនុម័តទំហំភតិសន្យាហិរញ្ញវត្ថុរហូត

[16] មន្ត្រីផ្នែកអភិវឌ្ឍផលិតផល, គោលនយោបាយផលិតផល, ២០១៧,ទំព័រ ១២

ដល់ ៥,០០១ ទៅ ៧,០០០ ដុល្លារអាមេរិក

- ✓នាយកប្រតិបត្តិការ មានសិទ្ធិអនុម័តរហូតចាប់ពី ៧,០០១ ទៅ ១៥,០០០ ដុល្លារអាមេរិក
- ✓គណៈកម្មាធិការបង់រំលស់ ( អគ្គនាយក នាយកប្រតិបត្តិការ ប្រធានផ្នែកឥណទាន និង ប្រធានសាខា ) មានសិទ្ធិអនុម័ត រហូតដល់ ១០០,០០០ ដុល្លារអាមេរិក
- ✓គណៈកម្មាធិការបង់រំលស់ ( អគ្គនាយក នាយកប្រតិបត្តិការ នាយកហិរញ្ញវត្ថុ និងក្រុម ប្រឹក្សាភិបាល ) មានសិទ្ធិអនុម័តទំហំភតិសន្យាហិរញ្ញវត្ថុ រហូតដល់ ធំជាង ១០០,០០០ ដុល្លារ អាមេរិក ។

## ៣.៥. នីតិវិធីក្នុងការផ្តល់ភតិសន្យាហិរញ្ញវត្ថុ

គ្រប់ក្រុមហ៊ុនទាំងអស់ ដែលបើដំណើរការអាជីវកម្ម តែងតែបង្កើតអោយមាននីតិវិធីទៅតាម ប្រភេទ នៃអាជីវកម្មរបស់ខ្លួន ក្នុងការផ្តល់សេវាកម្ម ឬផលិតផលដល់អតិថិជន ដើម្បីទទួលបាននូវ ប្រសិទ្ធិភាពខ្ពស់ និងសុវត្ថិភាព ។ យ៉ាងណាមិញក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ មេហ្គាលីស៊ីងសាខា ភ្នំពេញក៏មាននីតិវិធីរបស់ខ្លួនក្នុងផ្តល់សេវាភតិសន្យាហិរញ្ញវត្ថុដល់អតិថិជនរបស់ខ្លួន ។

### ៣.៥.១. ការដាក់ពាក្យស្នើសុំ

ការដាក់ពាក្យស្នើសុំ គឺជាដំណើរការដំបូងនៃ ការផ្តល់សេវាភតិសន្យាហិរញ្ញវត្ថុ ។ នៅពេល ដែល អតិថិជនចង់ទទួលបានសម្ភារៈអ្វីមួយ មកប្រើប្រាស់តែគាត់មិនមានលុយគ្រប់គ្រាន់ គាត់ អាច ស្នើសុំសេវាភតិសន្យាហិរញ្ញវត្ថុ ដើម្បីយកសម្ភារៈនោះមកប្រើប្រាស់ ។ អតិថិជនអាចទៅ ជ្រើសរើស សម្ភារៈដែលខ្លួនចង់បានដោយផ្ទាល់នៅកន្លែងផ្គត់ផ្គង់ណាមួយ និងធ្វើការចចារតំលៃ ជាមួយអ្នកផ្គត់ផ្គង់ ។ បន្ទាប់មកអតិថិជន អាចធ្វើការទាក់ទងទៅក្រុមហ៊ុនមេហ្គាលីស៊ីង តាមរយៈម ន្ត្រីឥណទាន ដែលចុះតាមភូមិ ឬមកការិយាល័យក្រុមហ៊ុនមេហ្គាលីស៊ីងសាខាភ្នំពេញផ្ទាល់តែម្តង ដើម្បីដាក់ពាក្យស្នើសុំ ។ អតិថិជនត្រូវយកឯកសារអត្តសញ្ញាណ ឯកសារបញ្ជាក់អាស័យដ្ឋាន និង ឯកសារផ្សេងៗ ទៀត ដើម្បីបំពេញលើពាក្យស្នើសុំ ។

ធាតុសំខាន់ៗនៅក្នុងពាក្យស្នើសុំនោះមាន៖ ឈ្មោះអតិថិជន និងអ្នករួមខ្ចី ( បើមាន ) អាស័យ ដ្ឋាន ចំនួនទឹកប្រាក់ស្នើសុំ ប្រភេទសម្ភារៈ (គោលបំណង ) ការងារ និងចំណូល ចំណាយ របស់ អតិថិជន ។

### ៣.៥.២. ការចុះអង្កេតដល់ទីកន្លែង

រាល់អតិថិជនទាំងដែលស្នើសុំប្រើប្រាស់សម្ភារៈតាមរយៈសេវាភតិសន្យាហិរញ្ញវត្ថុ របស់

ក្រុមហ៊ុនមេហ្គាលីស៊ីង ភីអិលស៊ី គឺក្រុមហ៊ុនតម្រូវអោយបុគ្គលិកចុះត្រួតពិនិត្យដល់ផ្ទះអតិថិជន និងទីកន្លែងធ្វើការងារ ឬអាជីវកម្ម ដើម្បីអោយប្រាកដថា អតិថិជនពិតជាមានទីលំនៅពិតប្រាកដ និងមានការងារច្បាស់លាស់មែន ។ ហើយក្នុងពេលនោះផងដែរមន្ត្រីឥណទាន ត្រូវតែអង្កេតមើលលើលក្ខខណ្ឌផ្សេងៗទៀត ដើម្បីអោយពត៌មានដែលទទួលបាន គឺមានភាពត្រឹមត្រូវ និងគ្រប់គ្រាន់ ។

ជាទូទៅ នៅពេលមន្ត្រីឥណទាន ឬប្រធានមន្ត្រីឥណទាន ចុះទៅដល់ទីកន្លែងដែលអតិថិជនរសនៅ នឹងសាកសួរពត៌មានបន្ថែម និងអង្កេតលើចំនុចមួយចំនួនរួមមានៈ ការអង្កេតលើអត្តចរិកទ្រព្យសម្បត្តិ និងសាកសួរពីប្រវត្តិសងប្រាក់ អង្កេតលើការទំនាក់ទំនងរវាងអ្នកជិតខាង និងអតិថិជន និងអង្កេតលើស្ថានភាពគ្រួសារ ។ ចុះជួបអជ្ញាធរ និងអ្នកជិតខាង ដើម្បីសាកសួរពីពត៌មានអតិថិជន បន្ថែមទៀត ដើម្បីអោយពត៌មានដែលទទួលបាន គឺមានភាពត្រឹមត្រូវ និងគ្រប់គ្រាន់ ។

### ៣.៥.៣. ការអនុម័តផ្តល់សេវាឥតិសន្យាហិរញ្ញវត្ថុ

ការអនុម័តភតិសន្យាហិរញ្ញវត្ថុត្រូវបានធ្វើឡើង ក្នុងរយៈពេលពី ១ ទៅ ៥ ថ្ងៃ នៃថ្ងៃធ្វើការដោយអាស្រ័យលើភាពគ្រប់គ្រាន់នៃលក្ខខណ្ឌដែល ក្រុមហ៊ុនតម្រូវ ។ ហើយការអនុម័តនេះផងដែរ ក៏ត្រូវបានកំណត់ទៅតាមតួនាទី និងបទពិសោធន៍ការងារឥណទាន ដែលបានបង្ហាញនៅចំណុច ៣.៣. ដែលនិយាយពីការកំណត់សិទ្ធិ ក្នុងការអនុម័តភតិសន្យាហិរញ្ញវត្ថុ ។ ប្រសិនបើអតិថិជនស្នើសុំភតិសន្យាហិរញ្ញវត្ថុ ក្នុងទំហំតូចជាង ឬស្មើ ១ ពាន់ដុល្លារ នោះនឹងត្រូវអនុម័តដោយប្រធានមន្ត្រីឥណទាន ប៉ុន្តែបើទំហំភតិសន្យាហិរញ្ញវត្ថុ ធំជាង១ ពាន់ដុល្លារ នោះនឹងត្រូវអនុម័តដោយ ប្រធានសាខា ឬអនុប្រធានសាខា ។ ប្រធានមន្ត្រីឥណទាន ដាក់ពាក្យស្នើសុំភតិសន្យាហិរញ្ញវត្ថុ របស់អតិថិជនទៅប្រធានសាខា ដើម្បីស្នើសុំការអនុម័ត ។

### ៣.៥.៤. ការចុះឈ្មោះអតិថិជននៅក្នុងប្រព័ន្ធ

ប្រធានសាខា ត្រូវតែបញ្ជូនឯកសារភតិសន្យាហិរញ្ញវត្ថុទាំងនោះ មកបេឡាករ តាមរយៈប្រធានមន្ត្រីឥណទាន និង មន្ត្រីឥណទាន ដើម្បីអោយបេឡាចុះឈ្មោះអតិថិជនទៅក្នុងប្រព័ន្ធ និងរៀបចំបើកប្រាក់ ( ឬមូលប្បទានបត្រ ប្រសិនបើទំហំភតិសន្យាហិរញ្ញវត្ថុ ធំជាង ១ពាន់ដុល្លារ ) ជូនមន្ត្រីឥណទាន ដើម្បីយកទៅទូទាត់ថ្លៃទំនិញ ដែលអតិថិជនបានស្នើសុំ ។

មន្ត្រីឥណទាន ត្រូវរៀបចំ និងទាក់ទងទៅអតិថិជនអោយមកទទួលយកសម្ភារៈ ដែលគាត់ស្នើសុំនៅកន្លែងផ្គត់ផ្គង់និងផ្តិតមេដៃលើកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ និងឯកសារពាក់ព័ន្ធផ្សេងៗទៀត ព្រមទាំងផ្តល់តារាងបង់ប្រាក់ ទៅអតិថិជនដើម្បីអោយ គាត់បង់ប្រាក់ទៅតាមចំនួន

និងកាលបរិច្ឆេតដែលបានកំណត់នៅក្នុងតារាងនោះ ។

### ៣.៥.៥. ការរក្សាទុកឯកសារ

ការរក្សាទុកឯកសារ គឺជាតួនាទីយ៉ាងសំខាន់របស់ហិរញ្ញិកនៅសាខា និងជាតួនាទីរបស់បេឡាករបើនៅអនុសាខា ដើម្បីធានាអោយបាននូវសុវត្ថិភាពឯកសារ ព្រោះឯកសារភតិសន្យាហិរញ្ញវត្ថុ គឺជាភស្តុតាងតែមួយគត់ដែល បញ្ជាក់ពីភតិសន្យាហិរញ្ញវត្ថុ រវាងភតិក: និងក្រុមហ៊ុនមេហ្គាលីស៊ីងសាខាភ្នំពេញ ។

ដូច្នេះហើយនៅពេលដែលមន្ត្រីឥណទាន បានទូទាត់ថ្លៃទំនិញ និងផ្តិតមេដៃអតិថិជន រួចហើយមន្ត្រីឥណទានត្រូវ បញ្ជូនឯកសារទាំងនោះទៅហិរញ្ញិក ឬបេឡាករ ដើម្បីពិនិត្យឡើងវិញ និង រៀបចំរក្សាទុកទៅតាមគោលនយោបាយរក្សាទុកឯកសាររបសក្រុមហ៊ុន ។

❖ **ខាងក្រុមនេះជាតារាងដែលបង្ហាញពី នីតិវិធីក្នុងការផ្តល់សេវាភតិសន្យាហិរញ្ញវត្ថុ** [17]

| ល.រ | អ្នកទទួលខុសត្រូវ | បរិយាយការងារ |
|---|---|---|
| ១ | អតិថិជន | ស្នើសុំធ្វើការបង់រំលស់ |
| ២ | មន្ត្រីឥណទាន | ក្រោយពីទទួលបានការស្នើសុំ បង់រំលស់ពិអតិថិជនបុគ្គលិកត្រូវអនុវត្តនៅកតព្វកិច្ចដូចជាៈ<br>- ប្រសិនបើជាអតិថិជនចាស់ សូមត្រួតពិនិត្យមើលប្រវត្តិ ការបង់សងរបស់អតិថិជន<br>- ចុះសិក្សាអតិថិជនដល់ផ្ទះអតិថិជន ពីលក្ខខណ្ឌមួយចំនួនដូចខាងក្រោមៈ<br>• សិក្សាលើអត្តចរិករបស់អតិថិជន<br>• សិក្សាលើស្ថានភាពរសនៅរបស់អតិថិជន<br>• សិក្សាលើសមត្ថភាពសងបំណុលរបស់អតិថិជន<br>• សិក្សាលើ លក្ខខណ្ឌផ្សេងៗ<br>- សិក្សាលើលក្ខខណ្ឌរបស់អ្នកធានា ។ |
| ៣ | មន្ត្រីឥណទាន | • ស្នើសុំឯកសារបញ្ជាក់អត្តសញ្ញាណ និងអាស័យដ្ឋានរបស់អ្នកស្នើសុំ និងអ្នកធានា ព្រមទាំងឯកសារផ្សេងៗទៀត<br>• បំពេញឯកសារដើម្បីទទួលបានការបង់រំលស់ ( ពាក្យស្នើសុំភតិសន្យាហិរញ្ញវត្ថុ ) និងផ្តិចមេដៃអតិថិជន និងអ្នកធានា |

[17] មន្ត្រីអភិវឌ្ឍន៍ផលិតផល, នីតិវិធីនៃការផ្តល់សេវាភតិសន្យាហិរញ្ញវត្ថុ

| | | |
|---|---|---|
| ៤ | មន្ត្រីឥណទាន | • ផ្ទៀងផ្ទាត់ពត៌មានអតិថិជន ជាមួយភាគីទីបី ( អជ្ញាធរមូលដ្ឋាន អ្នកជិតខាង ដែលអាចស្គាល់អតិថិជន )<br>• បញ្ជូនពាក្យស្នើសុំទៅប្រធានមន្ត្រីឥណទាន ដើម្បីត្រួតពិនិត្យ |
| ៥ | ប្រធានឥណទាន | ទទួល និងត្រួតពិនិត្យឯកសារបង់រំលស់៖<br>• បោះពុម្ភ និងផ្ទៀងផ្ទាត់បំណុល ជាមួយរបាយការណ៍ CBC<br>• ត្រូវចុះត្រួតពិនិត្យអតិថិជនដល់ផ្ទះអតិថិជន<br>• ពិនិត្យឯកសារឡើងវិញ និងចុះហត្ថលេខា និងបញ្ជូនឯកសារទៅប្រធានសាខា ដើម្បីត្រួតពិនិត្យ |
| ៦ | ប្រធានសាខា | • ចុះត្រួតពិនិត្យដល់ផ្ទះអតិថិជន<br>• ចុះហត្ថលេខាលើឯកសារផ្សេងៗ និងបញ្ជូនទៅប្រធានមន្ត្រីឥណទានក្រោយពេលអនុម័តរួច |
| ៧ | ប្រធានឥណទាន | • ត្រួតពិនិត្យឯកសារឡើងវិញ និងបញ្ជូនឯកសារដែលពាក់ព័ន្ធទៅ បេឡាករ ក្រោយពេលអនុម័តនិងប្រាប់អោយមន្ត្រីឥណទានណាត់ជាមួយអតិថិជនដើម្បីទទួលយកផលិតផល |
| ៨ | បេឡាករ | • ពិនិត្យ និងផ្ទៀងផ្ទាត់ឯកសារដែលទទួលបាន<br>• បញ្ចូលពត៌មានអតិថិជនចូលទៅក្នុងប្រព័ន្ធ<br>• បោះពុម្ភកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ កិច្ចព្រមព្រៀងធានាភតិសន្យាហិរញ្ញវត្ថុ និងតារាងបង់ប្រាក់ និងបញ្ជូនឯកសារបង់រំលស់ទាំងអស់ទៅប្រធានមន្ត្រីភតិសន្យាហិរញ្ញវត្ថុ |
| ៩ | មន្ត្រីឥណទាន | បំពេញ កិច្ចសន្យាដាក់ទ្រព្យធានា ( បើមាន )<br>បំពេញ កិច្ចសន្យាដាក់ទ្រព្យជំនួស ( បើមាន )<br>បញ្ជូនឯកសារទាំងអស់ទៅប្រធានមន្ត្រីភតិសន្យាហិរញ្ញវត្ថុ ដើម្បីធ្វើការត្រួតពិនិត្យ |
| ១០ | ប្រធានមន្ត្រីឥណទាន | ត្រួតពិនិត្យឯកសារឡើងវិញ<br>ចុះហត្ថលេខា និងបោះត្រាលើឯកសារ |
| ១១ | មន្ត្រីឥណទាន | ត្រួតពិនិត្យឯកសារឡើងវិញ បញ្ជូនឯកសារទាំងអស់ទៅ បេឡាករ |
| ១២ | បេឡាករ | ត្រូវពិនិត្យមើលឯកសារឡើងវិញទាំងអស់ អោយបានត្រឹមត្រូវ<br>រៀបចំបើកប្រាក់តាមនីតិវិធីនាយកដ្ឋានហិរញ្ញវត្ថុ<br>បញ្ជូនឯកសារទាំងអស់ ទៅមន្ត្រីឥណទាន ដើម្បីទូទាត់ថ្លៃទំនិញនៅកន្លែងផ្គត់ផ្គង់ |
| ១៣ | មន្ត្រីឥណទាន | ណាត់អតិថិជនអោយមកទទួលយកសម្ភារៈដែលគាត់បង់រំលស់ នៅកន្លែងផ្គត់ផ្គង់<br>ទទួលទាត់ថ្លៃទំនិញជាមួយអ្នកផ្គត់ផ្គង់ និងប្រគល់សម្ភារៈទៅអតិថិជនប្រើប្រាស់<br>ផ្ដិតមេដៃអតិថិជនលើកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ កិច្ចព្រមព្រៀងធានាភតិសន្យាហិរញ្ញវត្ថុ និងឯកសារផ្សេងៗទៀត ដែលមិនទាន់បានផ្ដិចមេដៃអតិថិជន |

| | | |
|---|---|---|
| | | បញ្ជូនឯកសារទាំងនោះទៅហិរញ្ញិក ដើម្បីរក្សាទុក |
| ១៤ | ហិរញ្ញិក | ត្រួតពិនិត្យឯកសារឡើងវិញទាំងអស់ ថាតើវាគ្រប់គ្រាន់ និងពេញលេញដែរ ឬទេ ? ចុះហត្ថលេខា និងរក្សាទុកតាមគោលនយោបាយរក្សាទុកឯកសារភតិសន្យាហិរញ្ញវត្ថុ |

## ៣.៦. ការគ្រប់គ្រងប្រាក់ឈ្នួល

ការគ្រប់គ្រងប្រាក់ឈ្នួល គឺជា កត្តាយ៉ាងសំខាន់ វាទាក់ទងទៅនឹងសន្ទនីយភាពសាច់ប្រាក់ ដូច្នេះអ្នកគ្រប់គ្រងប្រាក់ឈ្នួលត្រូវធ្វើយ៉ាងណា អោយភតិសន្យាហិរញ្ញវត្ថុ ដែលបានបញ្ចេញ នឹងអាចប្រមូលបានគ្រប់ចំនួន ។ អ្នកគ្រប់គ្រងប្រាក់ ឈ្នួលត្រូវតែបង្កើតគោលនយោបាយក្នុងការប្រមូលប្រាក់ឈ្នួល ធ្វើយ៉ាងណាអោយក្រុមហ៊ុនប្រមូលប្រាក់ឈ្នួលបានគ្រប់គ្រាន់ និងទាន់ពេលវេលា ។ លើសពីនេះទៀត ក្រុមហ៊ុនត្រូវធ្វើយ៉ាងណាអោយមានភាពងាយស្រួល និងសុវត្ថិភាពសម្រាប់អតិថិជនក្នុងការបង់ប្រាក់ ដើម្បីជៀសវាង នៅហានិភ័យនៃការបាត់បង់ប្រាក់នៅពេលអតិថិជនបង់ ។ ការគ្រប់គ្រងប្រាក់ឈ្នួលបានល្អ នឹងធ្វើអោយមានសន្ទនីយភាពសាច់ប្រាក់ និងភាពជួបជ័យក្នុងអាជីវកម្មមួយនេះ ។

### ៣.៦.១. វិធីសាស្ត្រ នៃការបង់សង

វិធីសាស្ត្រ នៃការបង់សងមានច្រើនប្រភេទ ប៉ុន្តែចំពោះក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ មេហ្គាលីស៊ីង សាខាភ្នំពេញ បានអនុវត្តនូវវិធីសាស្ត្រតែមួយគត់ គឺវិធីសាស្ត្ររំលស់ថេរ ( Fixed Payment ) ។

វិធីសាស្ត្រនេះ ជាវិធីសាស្ត្រ ដែលមានភាពងាយស្រួល សម្រាប់អតិថិជន ក្នុងការចាំនូវចំនួនសរុបដែលត្រូវបង់ប្រចាំគ្រានិមួយៗ ។ វិធីសាស្ត្រនេះមានរូបមន្តដូចខាងក្រោម៖

$$C = P/ ((1-1/ (1+ r) ^t)/r)$$

**កំណត់សម្គាល់:** C = ចំនួនទឹកប្រាក់សរុបដែលត្រូវបង់ប្រចាំគ្រា និមួយៗ

P = ប្រាក់ដើម, r = អត្រាការប្រាក់ប្រសិទ្ធភាព និង t = រយៈពេលរំលោះ

**ឧទាហរណ៍:** លោកពូ សៅ ភឿន បានស្នើសុំភតិសន្យាហិរញ្ញវត្ថុ លើទោចក្រយានយន្តនៅថ្ងៃទី ១០ ខែ ០៥ ឆ្នាំ ២០១៧ ចំនួន ១០០០ដុល្លារ ពីក្រុមហ៊ុនមេហ្គាលីស៊ីង ដែលមានរយៈពេល ១ ឆ្នាំ ។

ចូររកចំនួនទឹកប្រាក់ដែលគាត់ត្រូវបង់ប្រចាំគ្រានិមួយ ៗ ។

**ចំលើយ**

ដោយពូ សៅ គៀន បានទទួលសេវាភតិសន្យាហិរញ្ញវត្ថុ នៅថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០១៧

ទំហំភតិសន្យាហិរញ្ញវត្ថុ ឬទំហំដែលត្រូវបង់រំលស់ គឺ ១,៧00 ដុល្លារ

បន្ទុកហិរញ្ញវត្ថុ ( flat rate ) គឺ ១.៧% ក្នុងមួយខែ និង អត្រាប្រសិទ្ធិភាព ២.៩៩%ក្នុងមួយខែ ភតិសន្យាហិរញ្ញវត្ថុនេះមានរយៈពេល ១ ឆ្នាំ ស្មើ ១២ ខែ

លោកពូ សៅ គៀនស្នើសុំបង់លើកទីមួយ នៅថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៧

⇒ **C = 1700/ ((1-1/ (1+ 0.0299)^12)/0.0299= $ 170.68**

ដូចនេះចំនួនទឹកប្រាក់ដែលគាត់ត្រូវបង់ប្រចាំគ្រា ( C ) គឺ 170.68 ដុល្លារអាមេរិក ។

ខាងក្រោមនេះជាតារាងដែលបង្ហាញពី ចំនួនទឹកប្រាក់ដែលគាត់ត្រូវបង់ប្រចាំគ្រា និមួយៗ៖

**កាលវិភាគបង់ប្រាក់**

| | | | |
|---|---|---|---|
| លេខងតិថិជន: CU 7077 | | លេខកិច្ចសន្យា: LC1804113421 | |
| ឈ្មោះអតិថិជន: សៅ គៀន | លេខគណនីអតិថិជន: DD034424 | បញ្ចប់កិច្ចសន្យា: 13/05/18 | |
| ចំនួនសរុបនៃភតិសន្យាហិរញ្ញវត្ថុ: 1,700 $ | | រយៈពេល | : 12 ខែ |
| អាស័យដ្ឋាន: ភ្នាត ស្ទឹងមានជ័យ មានជ័យ ភ្នំពេញ | ថ្ងៃខែឆ្នាំប្រសិទ្ធិភាព: 13/04/17 | អត្រាការប្រាក់ | : 2.99% |
| | អត្រាការប្រាក់: 1.70%/ខែ | ប្រសិទ្ធិភាព | |

| ល.រ | កាលបរិច្ឆេត | ប្រាក់ដើមជំពាក់ | ប្រាក់ដើមត្រូវបង់ | ការប្រាក់ | ប្រាក់ត្រូវបង់ | សមតុល្យ |
|---|---|---|---|---|---|---|
| 1 | 13-06-17 | 1,700 | 120 | 51 | 171 | 1,580 |
| 2 | 13-07-17 | 1,580 | 123 | 47 | 171 | 1,457 |
| 3 | 13-08-17 | 1,457 | 127 | 44 | 171 | 1,330 |
| 4 | 13-09-17 | 1,330 | 131 | 40 | 171 | 1,199 |
| 5 | 13-10-17 | 1,199 | 135 | 36 | 171 | 1,064 |
| 6 | 13-11-17 | 1,064 | 139 | 32 | 171 | 925 |
| 7 | 13-12-17 | 925 | 143 | 28 | 171 | 782 |
| 8 | 13-01-18 | 782 | 147 | 23 | 171 | 635 |
| 9 | 13-02-18 | 635 | 152 | 19 | 171 | 483 |
| 10 | 13-03-18 | 483 | 156 | 14 | 171 | 327 |

| | | | | | | |
|---|---|---|---|---|---|---|
| 11 | 13-04-18 | 327 | 161 | 10 | 171 | 166 |
| 12 | 13-05-18 | 166 | 166 | 5 | 171 | (0) |

( តារាងទី ១ តារាងបង់ប្រាក់ )

### ៣.៦.២. ការទារប្រមូលប្រាក់ឈ្នួល

នៅក្រុមហ៊ុន និងគ្រឹះស្ថានមួយចំនួន បានបង្កើតនូវគោលនយោបាយផ្សេងៗ ក្នុងការទារប្រមូលប្រាក់ពីអតិថិជន យ៉ាងណាមិញសម្រាប់ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុមេហ្គាលីស៊ីង ក៏បានកំណត់នូវ គោលនយោបាយមួយដែរ ក្នុងការទារប្រមូលប្រាក់ពីអតិថិជន ដើម្បីអោយការទារ ប្រមូលប្រាក់ឈ្នួលពីអតិថិជន មានប្រសិទ្ធិភាព មានសុវត្ថិភាព ចំណេញពេលវេលា និងមានភាពងាយស្រួល សម្រាប់អតិថិជន និងក្រុមហ៊ុនមេហ្គាលីស៊ីង ភីអិលស៊ី ។

រាល់អតិថិជនដែលបានទទួលសេវាភតិសន្យាហិរញ្ញវត្ថុពីក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុមេហ្គាលីស៊ីង គឺក្រុមហ៊ុនតម្រូវអោយអតិថិជន មកបង់ប្រាក់ឈ្នួលដោយខ្លួនឯង ទៅតាមទីតាំងមួយចំនួន

ដូចជា៖ នៅតាមការិយាល័យក្រុមហ៊ុនផ្ទាល់ តាមរយៈភ្នាក់ងារផ្ទេរប្រាក់ ( វីង ទ្រូម៉ាន់នី ) ដែលអតិថិជនគិតថានៅជិតបំផុត ដែលអាចផ្តល់ភាពងាយស្រួល ចំណេញពេលវេលា និងសុវត្ថិភាពចំពោះអតិថិជន និងក្រុមហ៊ុន។

ចំពោះអតិថិជនដែលធ្លាប់មានប្រវត្តិបង់សងយឺតយ៉ាវ មន្ត្រីឥណទាន មានតួនាទី តាមដាន និងត្រាសរំលឹកអោយអតិថិជនបង់សងបានទាន់ពេលវេលា ប៉ុន្តែមន្ត្រីឥណទានមិនមានសិទ្ធិទទួលយកប្រាក់ពីអតិថិជនឡើយ ។

ចំពោះអតិថិជន ដែលមានបញ្ហាយឺតយ៉ាវខ្លាំង ( None Performance Lease ) ឬ ភតិសន្យាហិរញ្ញវត្ថុដែលស្ថិតក្នុងការសង្ស័យ ( Default ) ឬបាត់បង់ ( Loss ) មន្ត្រីឥណទាន មានតួនាទី តាមដាន និងចាត់វិធានការដោះស្រាយ ធ្វើយ៉ាងណាអោយ អតិថិជនបង់សងប្រាក់មកក្រុមហ៊ុនវិញ។ អតិថិជនប្រភេទនេះ ភាគច្រើន ធ្វើការបង់សងតាមរយៈមន្ត្រីឥណទាន នៅពេលដែល មន្ត្រីឥណទាន ចុះធ្វើការដោះស្រាយ ប៉ុន្តែមន្ត្រីឥណទានត្រូវ ស្នើសុំ ការយល់ព្រមពីប្រធានផ្ទាល់របស់ខ្លួន ដើម្បីទទួលយកប្រាក់ដែលអតិថិជនបង់ ។

## ៣.៧. ការដោះស្រាយភតិសន្យាហិរញ្ញវត្ថុមានបញ្ហា

កាលណាមានភតិសន្យាហិរញ្ញវត្ថុមានបញ្ហាច្រើន នោះនឹងធ្វើអោយសាខាទាំងមូលប្រឈមនឹងការខាតបង់ និងក្ស័យធន ពីព្រោះភតិសន្យាហិរញ្ញវត្ថុ គឺជាទ្រព្យសកម្មយ៉ាងរឹងមាំរបស់ក្រុម

ហ៊ុនភតិសន្យាហិរញ្ញវត្ថុមេហ្កាលីស៊ីង សាខាភ្នំពេញ ។ ការដោះស្រាយភតិសន្យាហិរញ្ញវត្ថុ ដែលមានបញ្ហា គឺជាទំនួលខុសត្រូវរបស់ បុគ្គលិកទាំងអស់ នៅក្នុងសាខាភ្នំពេញ ដែលត្រូវបំពេញយ៉ាងយកទុកដាក់ ដើម្បីស្តារភតិសន្យាហិរញ្ញវត្ថុដែលមានបញ្ហាអោយបង់សងត្រលប់វិញ ។

សមាសភាពសំខាន់ៗ ដែលត្រូវចូលរួមក្នុងការដោះស្រាយភតិសន្យហិរញ្ញវត្ថុដែលមានបញ្ហា រួមមាន៖ មន្ត្រីឥណទាន ប្រធានមន្ត្រីឥណទាន ប្រធានសាខា និងមន្ត្រីស្តារបំណុល ។

### ៣.៧.១. គោលបំណង នៃការដោះស្រាយអតិថិជនមានបញ្ហា

គោលបំណងដែលជំរុញ អោយមានការដោះស្រាយអតិថិជនដែលមានបញ្ហារួមមាន៖

- ✓ ដើម្បីស្តារភតិសន្យាហិរញ្ញវត្ថុដែលមានបញ្ហាអោយបង់សងទាន់ពេលវេលាវិញ
- ✓ ដើម្បីពង្រឹងការបង់សងត្រលប់របស់អតិថិជន
- ✓ ដើម្បីទប់ស្កាត់ នូវភតិសន្យាហិរញ្ញវត្ថុដែលបាត់បង់
- ✓ ដើម្បីបង្កើននិរន្តភាព នៃប្រាក់ចំណេញរបស់សាខាភ្នំពេញ
- ✓ ដើម្បីទទួលបានលទ្ធផលការងារល្អនៅក្នុងសាខាទាំងមូល

### ៣.៧.២. នីតិវិធី នៃការដោះស្រាយអតិថិជនមានបញ្ហា

ខាងក្រោមនេះជាតារាង ដែលបង្ហាញពីនីតិវិធី នៃការដោះស្រាយអតិថិជនមានបញ្ហា[18]៖

| ល.រ | រយៈពេលយឺត | សមាសភាពដែលត្រូវទទួលខុសត្រូវ | ការងារចម្បងៗ |
|---|---|---|---|
| ១ | ២ ដល់៩ ថ្ងៃ | មន្ត្រីឥណទាន និងប្រធានមន្ត្រីឥណទាន | ចុះជួបផ្ទាល់ ឬទាក់ទងតាមទូរស័ព្ទ៖<br>១. ចុះពិភាក្សាពីបញ្ហាដែលនាំអោយមានការយឺត<br>២. រំលឹកពីផលវិបាក នៃការបង់សងយឺតរបស់អតិថិជន<br>៣. ធ្វើកិច្ចព្រមព្រៀងផ្ទាល់មាត់<br>៤. ផ្តល់ពត៌មានទៅប្រធានមន្ត្រីឥណទាន ដោយផ្ទាល់មាត់ពីបញ្ហាដែលអតិថិជនយឺត<br>៦. ត្រូវធ្វើរបាយការណ៍ជូនទៅប្រធានសាខាជាប្រចាំនូវរាល់ការដោះស្រាយបញ្ហាអតិថិជនយឺត |

[18] មន្ត្រីផ្នែកអភិវឌ្ឍន៍ផលិតផល, នីតិវិធី នៃការដោះស្រាយអតិថិជនមានបញ្ហា

| | | | |
|---|---|---|---|
| ២ | ១០ ដល់ ២៩ ថ្ងៃ | ក្រុមដោះស្រាយបញ្ហាកម្រិតសាខា | ចុះជួបអតិថិជនដល់ផ្ទះ និងកំណត់រយៈពេលសងសំរាប់ការបង់សង ( លើកទី២ ) ។ប្រធានសាខាត្រូវចុះវាយតម្លៃ និងប្រមូលពត៌មានដោយផ្ទាល់ពីអតិថិជនដែលមានបញ្ហា ។<br>១. ចុះពិភាក្សាពីបញ្ហាម្តងទៀត<br>២. ចុះទៅជួបអតិថិជននៅកន្លែងធ្វើអាជីកម្ម ឬការងារ ឬនៅផ្ទះរបស់អតិថិជន<br>៣. ជូនលិខិតជូនដំណឹងពីការសងយឺត និងកំណត់រយៈពេលសងចុងក្រោយ<br>៤. ប្រាប់អតិថិជន អំពីការចាត់វិធានការពិន័យធ្ងន់ធ្ងរជាងមុន<br>៥. អាចពិចារណា ក្នុងការធ្វើការសម្រួលការសងក្នុងករណីដែលអតិថិជនមានប្រាក់សងមិនបានគ្រប់ចំនួន ( ប្រធានសាខា/ប្រធានមន្ត្រីឥណទាន ដែលជាប្រក្រុម ដោះស្រាយបំណុល មានការសិទ្ធិអនុម័តទៅលើការសម្របសម្រួលនេះ<br>៦. ធ្វើកិច្ចព្រមព្រៀងកំណត់អោយសងក្នុង៣ថ្ងៃ<br>៧. ត្រូវធ្វើរាយការណ៍ រាយការណ៍ទៅប្រធានសាខា ជាប្រចាំនៅរាល់ពេលចុះដោះស្រាយ ។ |
| ៣ | ៣០ដល់ ៦០ ថ្ងៃ | | ដំណាក់កាលនេះត្រូវមានការចូលរួមពីប្រធានសាខា ឬអនុប្រធានសាខា ក្នុងការចុះវាយតម្លៃ និងប្រមូលពត៌មានដោយផ្ទាល់ពីបញ្ហាទាំងអស់នៅតាមសាខាដែលមានបញ្ហា៖<br>១. ធ្វើរបាយការណ៍ ជាលាយលាក់អក្សរជូនប្រធានផ្នែកឥណទានពីស្ថានភាពអតិថិជនដើម្បីរកវិធីសាស្រ្តស្តារបំណុលឡើងវិញ<br>២. រៀបចំលិខិតអញ្ជើញ ដើម្បីកោះអញ្ជើញ អតិថិជន និងអ្នកធានាអោយចូលខ្លួនដោះស្រាយនៅសាខា ឬអនុសាខាភ្នំពេញ<br>៣. ពន្យល់ និងពិភាក្សាពីច្បាប់ដែលទាក់ទងនឹង កិច្ចសន្យា ឬកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ឬការខាតបង់ផ្សេងៗនៅពេលដាក់ពាក្យបណ្តឹងទៅតុលាការ<br>៤. ដាក់លក្ខខណ្ឌសងចុងក្រោយ ដើម្បីតាមដានពីប្រសិទ្ធិភាពសង<br>៥. ប្រធានមន្ត្រីឥណទាន ត្រូវដាក់ពាក្យបណ្តឹងទប់ស្កាត់នៅ ភូមិ ឃុំ និងប៉ុស្តិ៍ប៉ូលីស ។ |

| | | | |
|---|---|---|---|
| ៤ | ៦១ដល់ ១២០ ថ្ងៃ | | ដំណាក់កាលនេះមានការចូលរួមពីប្រធានផ្នែកភតិសន្យាហិរញ្ញវត្ថុ ក្នុងការចុះវាយតម្លៃ និងប្រមូលពត៌មានដោយផ្ទាល់ ពីបញ្ហាទាំងអស់ទៅតាមសាខាដែលមានបញ្ហាៈ<br>១. បន្តធ្វើរបាយការណ៍សង្ខេបជាលាយលក្ខអក្សរ ជូនមន្ត្រីប្រធានផ្នែកភតិសន្យាហិរញ្ញវត្ថុ ទាំងពីស្ថានភាពសងយឺត ដើម្បីរកវិធីដោះស្រាយ<br>២. ផ្តល់មតិយោបល់ពីលទ្ធភាពសង និងឆន្ទៈសងរបស់អតិថិជន និងអ្នកធានា ត្រូវទៅជួបអតិថិជនដើម្បីធ្វើការសម្របសម្រួលក្នុងការលក់ទ្រព្យធានារបស់អតិថិជន ឬអ្នកធានាដោយមានជំនួយពីអនុប្រធានសាខា ឬប្រធានផ្នែកភតិសន្យាហិរញ្ញវត្ថុ ។ |
| ៥ | ១២១ ថ្ងៃឡើងទៅ | មន្ត្រីស្តារបំណុល និង ក្រុមដោះស្រាយបំណុលកម្រិតសាខា | ១. ទ្រព្យដែលអតិថិជនប្រគល់បានប្រគល់អោយមន្ត្រីភតិសន្យាហិរញ្ញវត្ថុ ត្រូវរក្សាទុកនៅទីកន្លែងមានសុវត្ថិភាព<br>២. ត្រូវទាក់ទងទៅអតិថិជនបង់សងយឺត និងអ្នកធានាដើម្បីអោយពួកគាត់ពិចារណាក្នុងការសងត្រលប់មកវិញ នូវសមតុល្យដែលនៅសល់ ទាំងអស់មុនពេលមុនពេលដែលក្រុមហ៊ុនប្រកាសលក់ទ្រព្យទាំងនោះ ។ |
| ៦ | អតិថិជនលុបបំណុល | | ក. តំណើរការនៃការដោះស្រាយអតិថិជនដេលបានលុបបំណុលៈ<br>១. មន្ត្រីភតិសន្យាហិរញ្ញវត្ថុ និងមន្ត្រីស្តារបំណុល<br>- ធ្វើផែនការចុះដោះស្រាយជាមួយអតិថិជនឡើងវិញ<br>- ចុះជួបអតិថិជននៅកន្លែងធ្វើអាជីវកម្ម ឬផ្ទះអតិថិជន<br>- សម្របសម្រួលជាមួយអតិថិជនអោយធ្វើការបង់សង ទៅតាមលទ្ធភាព |

# ជំពូកទី ៤ ការវិភាគទិន្នន័យ នៃប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុ

## ៤.១. កម្មវត្ថុ នៃការវិភាគទិន្នន័យ

ការវិភាគទិន្នន័យ គឺជាការវែកញែកលម្អិតដើម្បីបង្ហាញអោយឃើញពីលទ្ធផលជាក់ស្តែង នៃការអនុវត្តន៍ផែនការអាជីកម្មមួយ ។ កម្មវត្ថុនៃការវិភាគទិន្នន័យរួមមាន៖

- ✓ ដើម្បីបង្ហាញអោយឃើញពីចំណុចខ្លាំង និងចំណុចខ្សោយរបស់ក្រុមហ៊ុនមេហ្គាលីស៊ីង
- ✓ ដើម្បីបង្ហាញពី សក្តានុពល នៃផលិតផលនិមួយៗ របស់ក្រុមហ៊ុន
- ✓ ដើម្បីបង្ហាញអោយឃើញពីវឌ្ឍនភាព នៃក្រុមហ៊ុនពីមួយត្រីមាសទៅមួយត្រីមាស
- ✓ ដើម្បីទប់ស្កាត់ហានិភ័យ
- ✓ ដើម្បីងាយស្រួលក្នុងការសម្រេចចិត្ត ។ល។

## ៤.២. ការវិភាគទិន្នន័យ ភតិសន្យាហិរញ្ញវត្ថុ

### ៤.២.១. ការវិភាគទិន្នន័យលើរថយន្តទេសចរណ៍

ខាងក្រោមនេះ គឺជា តារាងដែលបង្ហាញអោយឃើញពីវឌ្ឍនភាពនៃ ភតិសន្យាហិរញ្ញវត្ថុ រថយន្តទេសចរណ៍នៅក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុមេហ្គាលីស៊ីង សាខាភ្នំពេញ ពីឆ្នាំ ២០១៦ ទៅឆ្នាំ ២០១៧ ដោយធ្វើការវិភាគទៅតាម ឆមាសនីមួយៗ នៃឆ្នាំ ។

តារាងបង្ហាញពីបម្រែបម្រួលសមតុល្យភតិសន្យាហិរញ្ញវត្ថុ ជាសាច់ប្រាក់($)

| Leases | 2016 | | 2017 | |
|---|---|---|---|---|
| | Term 1 | Term 2 | Term 1 | Term 2 |
| Amount | $ 1,197,070.43 | $ 975,717.83 | $ 908,773.46 | $ 872,625.57 |
| Variances ($) | $ - | $ (221,352.60) | $ (66,944.37) | $ (36,147.89) |
| Variances in (%) | 0% | -18% | -7% | -4% |

( តារាងទី ២ តារាងវិភាគទិន្នន័យភតិសន្យាហិរញ្ញវត្ថុ លើរថយន្តទេសចរណ៍ )

ព្យាក្រាមបង្ហាញពីបម្រែបម្រួល សមតុល្យភតិសន្យាហិរញ្ញវត្ថុជា សាច់ប្រាក់ ( $ )




( ដ្យាក្រាមទី ១ ការវិភាគទិន្នន័យលើរថយន្តទេសចរណ៍ )

បើយើងទៅតាមដ្យាក្រាមខាងលើបានបង្ហាញអោយឃើញថា ចំនួនភតិសន្យាហិរញ្ញវត្ថុនៅឆមាសទី២ នៃឆ្នាំ ២០១៦ មានទឹកប្រាក់ចំនួន ៩៧៥,៧១៧.៨៣ដុល្លារអាមេរិក មានការធ្លាក់ចំនួន ២២១,៣៥១.៦០ ដុល្លារ ឬស្មើ ១៨% បើធៀបទៅនឹង ឆមាសទី១ នៃឆ្នាំ ២០១៦ ដែលមានទឹកប្រាក់ចំនួន ១,១៩៧,០៧០,៤៣ ដុល្លារអាមេរិក។ នៅឆមាសទី១ នៃឆ្នាំ ២០១៧ ភតិសន្យាហិរញ្ញវត្ថុសរុប មានចំនួន ៩០៨,៧៧៣.៤៦ដុល្លារអាមេរិក ចំនួននេះបានបង្ហាញថាចំនួនភតិសន្យាហិរញ្ញវត្ថុនៅតែបន្តធ្លាក់ចុះ ចំនួន ៦៦,៩៤៤.៣៧ដុល្លារ ឬស្មើនឹង ៧%បើធៀបទៅនឹង ឆមាសទី២ នៃឆ្នាំ ២០១៦។

លើសពីនេះទៀត បើយើងមើលលើដ្យាក្រាម នៅឆមាសទី២ ឆ្នាំ ២០១៧ មានភតិសន្យាហិរញ្ញវត្ថុ សរុបចំនួន ៨៧២,៦២៥.៧៤ ដុល្លារអាមេរិក នូវចំនួននេះ វានៅតែបន្តធ្លាក់ចុះ ចំនួន ៣៦,១៤៧.៨៩ ដុល្លារអាមេរិក ឬស្មើនឹង ៤% បើធៀបទៅនឹង ឆមាសទី ១ នៃឆ្នាំដដែល ។

### ៤.២.២. ការវិភាគទិន្នន័យលើ ទោចក្រយានយន្ត

ខាងក្រោមនេះ គឺជាតារាងដែលបង្ហាញអោយឃើញពីវឌ្ឍនភាពនៃ ភតិសន្យាហិរញ្ញវត្ថុ លើទោចក្រយានយន្ត នៅក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុមេហ្គាលីស៊ីង សាខាភ្នំពេញ ពីឆ្នាំ ២០១៦ ទៅឆ្នាំ ២០១៧ ដោយធ្វើការវិភាគទៅតាម ឆមាសនិមួយៗ នៃឆ្នាំ ។

## តារាងបង្ហាញពីបម្រែបម្រួលសមតុល្យភតិសន្យាហិរញ្ញវត្ថុ ជាសាច់ប្រាក់( $ )

| Leases | 2016 | | 2017 | |
|---|---|---|---|---|
| | Term 1 | Term 2 | Term 1 | Term 2 |
| Portfolio ($ ) | $ 777,142.28 | $ 553,796.39 | $ 598,879.79 | $ 577,890.87 |
| Variance ( $ ) | $ - | $ (223,345.89) | $ 45,083.40 | $ (20,988.92) |
| Variance ( % ) | 0% | -29% | 8% | -4% |

( តារាងទី៣ ការវិភាគទិន្នន័យ លើទោចក្រយានយន្ត )

## ព្យាក្រាម បង្ហាញពីបម្រែបម្រួលសមតុល្យភតិសន្យាហិរញ្ញវត្ថុ ជាសាច់ប្រាក់ ( $ )




( ដ្យាក្រាមទី២ ការវិភាគទិន្នន័យ លើទោចក្រយានយន្ត )

បើយោងទៅតាមដ្យាក្រាមខាងក្រោមបានបង្ហាញអោយឃើញថា ចំពោះភតិសន្យាហិរញ្ញវត្ថុ លើទោចក្រយានយន្ត នៅឆមាសទី ២ នៃឆ្នាំ ២០១៦ មានចំនួន ៥៥៣,៧៩៦.៣៩ដុល្លារអាមេរិក មានការធ្លាក់ចុះ ចំនួន ២២៣,៣៤៥.៨៩ ដុល្លារអាមេរិក ឬស្មើនឹង ២៩% បើធៀបទៅនឹង ឆមាសទី ១ នៃឆ្នាំដដែល ដែលមានចំនួន ៧៧៧,១៤២.២៨ ដុល្លារអាមេរិក ។ នៅឆមាសទី ១ នៃឆ្នាំ ២០១៧ មានសមតុល្យភតិសន្យាហិរញ្ញវត្ថុសរុបចំនួន ៥៧៨,៨៧៩.៧៩ ដុល្លារ ចំនួននេះបានបង្ហាញអោយឃើញថាសមតុល្យភតិសន្យាហិរញ្ញវត្ថុ មានការកើនឡើងចំនួន ៤៥,០៨៣.៤០ ដុល្លារ ឬ ៨ % បើធៀបទៅនឹង ឆមាសទី ២ ឆ្នាំ ២០១៦ ។ ក៏ប៉ុន្តែនៅឆមាសទី ២ នៃឆ្នាំ ២០១៧ សមតុល្យភតិសន្យាហិរញ្ញវត្ថុមានចំនួន ៥៧៧,៨៩០.៨៧ ដុល្លារអាមេរិក ដែលបានធ្លាក់ចុះចំនួន

២០,៩៨៨.៩២ ដុល្លារ ឬស្មើនឹង ៩% បើធៀបទៅនឹង ឆមាសទី ១ នៃឆ្នាំដដែល ។

### ៤.២.៣. ការវិភាគទិន្នន័យលើរថយន្តដឹកទំនិញ

ខាងក្រោមនេះ គឺជាតារាងដែលបង្ហាញអោយឃើញពីវឌ្ឍនភាពនៃ ភតិសន្យាហិរញ្ញវត្ថុ រថយន្តដឹកទំនិញ នៅក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុមេហ្គាលីស៊ីង សាខាភ្នំពេញ ពីឆ្នាំ ២០១៦ ទៅឆ្នាំ ២០១៧ ដោយធ្វើការវិភាគទៅតាម ឆមាសនិមួយៗ នៃឆ្នាំ ។

តារាងបង្ហាញពីបម្រែបម្រួលសមតុល្យភតិសន្យាហិរញ្ញវត្ថុ ជាសាច់ប្រាក់( $ )

| Lease | 2016 | | 2017 | |
|---|---|---|---|---|
| | Term 1 | Term 2 | Term 1 | Term 2 |
| Portfolio ( $ ) | $ 15,000.00 | $ 39,478.96 | $ 230,626.59 | $ 284,945.60 |
| Variance ( $ ) | $ - | $ 24,478.96 | $ 191,147.63 | $ 54,319.01 |
| Variance ( % ) | 0 | 163% | 484% | 24% |

( តារាងទី ៤ ការវិភាគទិន្នន័យ លើរថយន្តដឹកទំនិញ )

ព្យាក្រាម បង្ហាញពីបម្រែបម្រួលសមតុល្យភតិសន្យាហិរញ្ញវត្ថុ ជាសាច់ប្រាក់ ( $ )




( ដ្យាក្រាមទី៣ ការវិភាគទិន្នន័យលើរថយន្តដឹកទំនិញ)

បើយោងទៅតាមដ្យាក្រាមខាងលើនេះ បានបង្ហាញអោយឃើញថា នៅឆមាសទី ២ ឆ្នាំ ២០១៦ ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុមេហ្គាលីស៊ីង ភីអិលស៊ី សាខាភ្នំពេញ មានសមតុល្យភតិសន្យាហិរញ្ញវត្ថុសរុបចំនួន៣៩,៤៧៨.៩៦ ដុល្លារអាមេរិក មានការកើនឡើងចំនួន ២៤,៤៧៨.៩៦ ដុល្លារ ឬស្មើ នឹង ១៦៣% បើធៀបទៅនឹង ឆមាសទី ១ ឆ្នាំដដែល ។ នៅឆមាសទី ១ ឆ្នាំ ២០១៧

ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ មេហ្គាលីស៊ីង ភីអិលស៊ី មានសមតុល្យភតិសន្យាហិរញ្ញវត្ថុសរុបចំនួន ២៣០,៦២៦.៥៩ ដុល្លារអាមេរិក ។ ចំនួននេះបានបង្ហាញអោយឃើញថា សមតុល្យភតិសន្យាហិរញ្ញវត្ថុសរុប មានការកើនឡើងគួរអោយកត់សម្គាល់ គឺបានកើនឡើងចំនួន ១៩១,១៩៧.៦៣ ដុល្លារ ឬស្មើនឹង ៤៨៤% បើធៀបទៅនឹង ឆមាសទី ២ ឆ្នាំ ២០១៦ ។ ហើយចំពោះ ឆមាសទី ២ ឆ្នាំ ២០១៧ យើងឃើញមានសមតុល្យភតិសន្យាហិរញ្ញវត្ថុសរុបចំនួន ២៨៤,៩៤៥.៦០ ដុល្លារអាមេរិក ។ ចំនួននេះអាចអោយយើងធ្វើការបកស្រាយបានថា សមតុល្យភតិសន្យាហិរញ្ញវត្ថុសាខាភ្នំពេញ នៅតែបន្ត កើនឡើង ចំនួន ៥៤,៣១៩.០១ ដុល្លារអាមេរិក ឬស្មើនឹង ២៤% បើធៀបទៅនឹង ឆមាសទី ១ នៃឆ្នាំដដែល ។

## ៤.៣. ការវិភាគទិន្នន័យរួម

ខាងក្រោមនេះ គឺជាការវិភាគទិន្នន័យរួមលើ ផលិតផលបី រួមមាន៖ ភតិសន្យាហិរញ្ញវត្ថុលើរថយន្ត ទេសចរណ៍ ទោចក្រយានយន្ត និងរថយន្តដឹកទំនិញ ដើម្បីបង្ហាញអោយឃើញនៅចំនុចរួមមួយនៃតំណើរការអាជីវកម្មភតិសន្យាហិរញ្ញវត្ថុរបស់ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុមេហ្គាលីស៊ីង ភីអិលស៊ី សាខាភ្នំពេញ ។ ថាតើលទ្ធផលដែលទទួលបានប្រចាំឆមាសនិមួយៗមានការធ្លាក់ចុះ ឬក៏កើនឡើង ។

**តារាងបង្ហាញពីបម្រែបម្រួលសមតុល្យភតិសន្យាហិរញ្ញវត្ថុ ជាសាច់ប្រាក់( $ )**

| Leases | 2016 | | 2017 | |
|---|---|---|---|---|
| | Term 1 | Term 2 | Term 1 | Term 2 |
| Amount | $ 1,989,212.71 | $ 1,568,993.18 | $ 1,738,279.84 | $ 1,735,462.04 |
| Variances ($) | $ - | $ (420,219.53) | $ 169,286.66 | $ (2,817.80) |
| Variances in (%) | 0% | -21% | 11% | 0% |

( តារាងទី ៥ ការវិភាគទិន្នន័យរួម )

ព្យាក្រាម បង្ហាញពីបម្រែបម្រួលសមតុល្យភតិសន្យាហិរញ្ញវត្ថុ ជាសាច់ប្រាក់ ( $ )




( ដ្យាក្រាមទី ៤ ការវិភាគទិន្នន័យរួម លើភតិសន្យាហិរញ្ញវត្ថុ )

បើយោងទៅតាមដ្យាក្រាម ខាងលើយើង អាចបង្ហាញបានថា នៅឆមាសទី ២ ឆ្នាំ ២០១៦ ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ មេហ្គាលីស៊ីង ភីអិលស៊ី សាខាភ្នំពេញមានសមតុល្យភតិសន្យាហិរញ្ញវត្ថុសរុប ១,៥៦៨,៩៩៣.១៨ ដុល្លារអាមេរិក។ តាមរយៈដ្យាក្រាមនេះ យើងឃើញថា សមតុល្យភតិសន្យាហិរញ្ញវត្ថុ មានការធ្លាក់ចុះចំនួន ៤២០,២១៩.៥៣ ដុល្លារអាមេរិក ឬស្មើនឹង ២១% បើធៀបទៅនឹង ឆមាសទី ១ ឆ្នាំដដែល ។ ចំណែកឯនៅឆមាសទី ១ ឆ្នាំ២០១៧ យើងឃើញមានសមតុល្យភតិសន្យាហិរញ្ញវត្ថុសរុបចំនួន ១,៧៣៨,២៧៩.៨៤ ដុល្លារអាមេរិក ។ ចំនួននេះយើងឃើញថា សមតុល្យនៅឆមាសទី ១ ឆ្នាំ ២០១៧ មានការកើនឡើងវិញចំនួន ១៦៩,២៨៦.៦៦ ដុល្លារ ឬស្មើនឹង ១១% បើធៀបទៅនឹង ឆមាសទី២ ឆ្នាំ ២០១៦ ដែលមានការធ្លាក់ចុះយ៉ាងខ្លាំង ។ នៅឆមាសទី ២ ឆ្នាំ ២០១៧ ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុមេហ្គាលីស៊ីង ភីអិលស៊ី មានសមតុល្យភតិសន្យាហិរញ្ញវត្ថុសរុប ១,៧៣៥,៤៦២.០៤ ដុល្លារអាមេរិក ។ តាមរយៈតួលេខក្នុងដ្យាក្រាមខាងលើបានបង្ហាញអោយឃើញថា សមតុល្យភតិសន្យាហិរញ្ញវត្ថុ មានការធ្លាក់ចុះចំនួន ២,៨១៧.៨០ ដុល្លារ ឬស្មើ នឹង ០.១៦% បើធៀបទៅនឹង ឆមាសទី ១ ឆ្នាំដដែល ។

## ៤.៤. ការវិភាគ SWOT

បន្ទាប់ពីខ្ញុំបាទ បានចុះកម្មសិក្សានៅ ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុដោយផ្ទាល់រួចមក ខ្ញុំបាទក៏បានឃើញនូវចំណុច ខ្លាំង និងខ្សោយមួយចំនួនរបស់ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ ។ ហើយចំ

ណុចខ្លាំង និងចំណុចខ្សោយទាំងនោះរួមមានដូចខាងក្រោម៖

### ៤.៤.១. ចំណុចខ្លាំង

✓ មានផលិតផលច្រើន ក្នុងការបំពេញតម្រូវការរបស់អតិថិជន

✓ មានគោលនយោបាយ និងនីតិវិធីច្បាស់លាស់ ចំពោះប្រតិបត្តិការអាជីវកម្ម

✓ មានរចនាសម្ព័ន្ធតួនាទី និងទំនួលខុសត្រូវច្បាស់លាស់

✓ ពង្រីកសាខា និងអនុសាខាច្រើន នៅទូទាំងភ្នំពេញ និងរាជធានីខេត្ត

✓ មានផ្តល់ជាពានរង្វាន់លើកទឹកចិត្តដល់សាខាដែលទទួលបានលទ្ធផលល្អជាងគេប្រចាំឆ្នាំ

### ៤.៤.២. ចំណុចខ្សោយ

✓ ការសិក្សា និងវាយតម្លៃអតិថិជន នៅមានកម្រិត

✓ ប្រព័ន្ធផ្សព្វផ្សាយរបស់ក្រុមហ៊ុន នៅមិនទាន់មានភាពទូលំទូលាយនៅឡើយបុគ្គលិកដែលពាក់ព័ន្ធផ្សេងៗ និងការទំនាក់ទំនងជាមួយអ្នកផ្គត់ផ្គង់ ជាពិសេស Facebook website

✓ ការគ្រប់គ្រងឯកសារភតិសន្យាហិរញ្ញវត្ថុនៅមិនទាន់មានរបៀបរៀបរយ និងស្របតាមគោលនយោបាយរៀបចំទុកដាក់ឯកសាររបស់ក្រុមហ៊ុនមេហ្គាលីស៊ីងភីអិលស៊ីនៅឡើយ

✓ សមត្ថភាពបុគ្គលិកនៅមានកម្រិត

✓ ដើមទុននៅមានកម្រិត ដែលមានការលំបាកក្នុងការប្រគួតប្រជែងជាមួយដៃគូ

✓ ការធ្វើបំណែងចែកអតិថិជនគោលដៅទៅតាមតំបន់គោលដៅនិមួយៗ នៅមិនទាន់មានប្រសិទ្ធភាពនៅឡើយ ដែលធ្វើអោយការលក់គ្មានប្រសិទ្ធភាព

### ៤.៤.៣. ឱកាស

ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ មេហ្គាលីស៊ីង ភីអិលស៊ី មានឱកាសក្នុងការអភិវឌ្ឍ ខ្លួនអោយកាន់រីកចម្រើនជាងនេះបន្ថែមទៀត ។ ខាងក្រោមនេះ ជាចំណុចឱកាសរបស់ ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុមេហ្គាលីស៊ីង ភីអិលស៊ី មានឱកាសក្នុងការអភិវឌ្ឍខ្លួនដូចជា៖

✓ វិស័យភតិសន្យាហិរញ្ញវត្ថុនៅកម្ពុជា ជាវិស័យថ្មីមួយដែលទើបតែរីកលូតលាស់ ។ ដូចនេះវាជាឱកាសរបស់ក្រុមហ៊ុនក្នុងការវាយលុក និងពង្រីកទីផ្សារលើវិស័យភតិសន្យាហិរញ្ញវត្ថុបន្ថែមទៀត ។

✓ បច្ចុប្បន្នមានប្រជាជន ភាគច្រើនយល់ដឹង នឹងគាំទ្រលើការប្រើប្រាស់សេវាភតិសន្យាហិរញ្ញវត្ថុវាជាឱកាសល្អសម្រាប់ការពង្រឹងនិងការពង្រីកតំបន់ប្រតិបត្តិការរបស់ខ្លួនអោយកាន់តែទូលំទូលាយ នៅកម្ពុជា

✓ បច្ចុប្បន្នរដ្ឋាភិបាលកំពុងតែជំរុញ និងលើកំពស់លើវិស័យហិរញ្ញវត្ថុនៅកម្ពុជា នេះជាឱកាសសម្រាប់ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុមេហ្គាលីស៊ីង ភីអិលស៊ី ក្នុងការជំរុញ និងអភិវឌ្ឍ ខ្លួនអោយក្លាយជា ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុធំជាងគេនៅកម្ពុជា ។

### ៤.៤.៤. ភាពគម្រាមកំហែង

ទន្ទឹម នឹងក្រុមហ៊ុនមានឱកាសច្រើនក្នុងការអភិវឌ្ឍន៍ខ្លួន ក៏ក្រុមហ៊ុនត្រូវទទួលរងនៅការគម្រាមកំហែងមួយចំនួនដូចខាងក្រោម៖

✓ បច្ចុប្បន្នយើងឃើញមានការកើនឡើងច្រើន នូវក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុថ្មីៗ ជាច្រើន ដូចនេះក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ មេហ្គាលីស៊ីង ភីអិលស៊ី នឹងមានដៃគូរប្រគួតប្រជេងច្រើន ក្នុងការផ្តល់សេវាភតិសន្យាហិរញ្ញវត្ថុ ជូនអតិថិជន

✓ ក្រុមហ៊ុនត្រូវទទួលរងនូវ បន្ទុកហិរញ្ញវត្ថុច្រើនជាងក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុដ៏ទៃទៀត

✓ ភតិសន្យាហិរញ្ញវត្ថុអាចប្រឈមទៅនឹង ភតិសន្យាហិរញ្ញវត្ថុ ស្ថិតក្នុងការសង្ស័យ ឬបាត់បង់តែម្តង ដោយសារតែកង្វះខាតសមត្ថភាពរបស់មន្ត្រីឥណទានក្នុងការសិក្សា និងវាយតម្លៃអតិថិជន

✓ ទទួលរងនូវការគម្រាមកំហែង ពីច្បាប់ និងបទបញ្ញាត្តិ ពាក់ព័ន្ធផ្សេងៗ នៅកម្ពុជា ។

# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

យោងតាមការចុះកម្មសិក្សាដោយផ្ទាល់នៅក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុមេហ្គាលីស៊ីង ភីអិលស៊ីសាខាភ្នំពេញរួចមកយើងខ្ញុំបានសង្កេតឃើញថាក្រុមហ៊ុនបានកំណត់នូវ គោលនយោបាយ និងនីតិវិធីច្បាស់លាស់ក្នុងការគ្រប់គ្រងភតិសន្យាហិរញ្ញវត្ថុ រួមមាន៖ គោលនយោបាយ និងនីតិវិធី ក្នុងការផ្តល់សេវាភតិសន្យាហិរញ្ញវត្ថុ គោលនយោបាយក្នុងការប្រមូលប្រាក់ ការកំណត់ទំហំ បន្ទុកហិរញ្ញវត្ថុរបៀបនៃការបង់សង លើផលិតផលភតិសន្យាហិរញ្ញវត្ថុនីមួយៗគោលនយោបាយក្នុងការត្រួតពិនិត្យ និងតាមដានអតិថិជនក្រោយពេលផ្តល់សេវាភតិសន្យាហិរញ្ញវត្ថុ និងនីតិវិធីក្នុងការដោះស្រាយពេលអតិថិជនមានបញ្ហា ។

ប៉ុន្តែបើទោះបីជាក្រុមហ៊ុនមានគោលនយោបាយ និងនីតិវិធីល្អប្រសើរយ៉ាងណាក៏ដោយ ក៏យើងឃើញការអនុវត្តន៍ នៅមិនទាន់មានលក្ខណៈល្អប្រសើរនៅឡើយ ដោយសារតែកត្តាមួយចំនួនរួមមាន៖ កត្តាសមត្ថភាពមន្ត្រីឥណទាននៅមានកម្រិត កត្តាប្រជាជនកម្ពុជា ដែលមិនទាន់មានជំនឿ និងទំនុកចិត្តលើវិស័យភតិសន្យាហិរញ្ញវត្ថុ កត្តាដៃគូប្រគួតជែងច្រើន និងកត្តាផ្សេងៗទៀត ដែលអាចបង្អាក់ការរីកលូតលាស់របស់ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុមេហ្គាលីស៊ីង ។

បើយើងមើលទៅលើសមតុល្យភតិសន្យាហិរញ្ញវត្ថុខាងលើ យើងឃើញថា សមតុល្យភតិសន្យាហិរញ្ញវត្ថុ មានការប្រែប្រួលខ្លាំង ( ធ្លាក់ចុះ )។ បើយើងធ្វើការប្រៀបធៀប សមតុល្យភតិសន្យាហិរញ្ញវត្ថុ នៅឆមាសទី ២ ទៅនឹងឆមាសទី ១ ឆ្នាំ ២០១៦ យើងឃើញថា សមតុល្យបានធ្លាក់ចុះរហូតដល់ ២១% ។

ជាចុងបញ្ចប់ ដោយយោងតាមខ្លឹមសារខាងលើយើងអាចសន្និដ្ឋានបានថា ការគ្រប់គ្រងភតិសន្យាហិរញ្ញវត្ថុរបស់ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុមេហ្គាលីស៊ីង ភីអិលស៊ី សាខាភ្នំពេញ នៅមិនទាន់មានលក្ខណៈល្អប្រសើរនៅឡើយ ជាមួយនឹងការផ្សព្វផ្សាយ ការសិក្សា វិភាគ និងវាយតម្លៃអតិថិជន ការរក្សាអតិថិជន( ជាពិសេសអតិថិជនដែលមានស្រាប់ ) ការដោះស្រាយអតិថិជនមានបញ្ហា និងប្រតិបត្តិការផ្សេងៗទៀត ។

## ២. អនុសាសន៍

ក្នុងកំឡុងពេលដែលខ្ញុំបាទបានចុះកម្មសិក្សានៅក្រុមហ៊ុនភតិសន្យាហរិញ្ញវត្ថុមេហ្គាលី ស៊ីង ភីអិលស៊ី សាខាភ្នំពេញកន្លងមកនេះ ខ្ញុំបាទបានសង្កេតឃើញថា ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុមេហ្គាលីស៊ីង គឺជាក្រុមហ៊ុនធំមួយ បើប្រៀបធៀបនឹង ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុផ្សេងទៀត ដែលបានដំណើរការអាជីវកម្ម ដោយអនុលោមទៅតាម ច្បាប់ភតិសន្យាហិរញ្ញវត្ថុ នៅកម្ពុជា ។ ក្រុមហ៊ុនមានរចនាសម្ព័ន្ធគ្រប់គ្រង និងបែងចែកតួនាទីបានត្រឹមត្រូវ មានគោលនយោបាយ និងនីតិវិធីច្បាស់លាស់ ។ ប៉ុន្តែបើទោះបីជាក្រុមហ៊ុនមេហ្គាលីស៊ីង មានគោលនយោបាយ និងនីតិវិធីច្បាស់លាស់យ៉ាងណាក្តី ក៏ខ្ញុំបាទ បានមើលឃើញនូវចំណុចមួយចំនួនដែលបានជះឥទ្ធិពលអាក្រក់ដល់ប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុ របស់ក្រុមហ៊ុន និងអាចធ្វើអោយក្រុមហ៊ុនប្រឈមទៅនឹង ការខាតបង់ ។ ចំណុតទាំងនោះរួមមានដូចខាងក្រោមះ

- ✓ ការពង្រឹងប្រសិទ្ធភាពលើ ការសិក្សា វិភាគ និងវាយតម្លៃអតិថិជន ដើម្បីធានាអោយបាន នូវគុណភាពភតិសន្យាហិរញ្ញវត្ថុ
- ✓ ការពង្រឹងប្រសិទ្ធភាពលើការធ្វើប្រេកង់ តំបន់គោលដៅ ដើម្បីជម្រុញអោយការលក់មានប្រសិទ្ធិភាព ( ដើម្បីលក់អោយចំ អតិថិជនគោលដៅ )
- ✓ បន្តធ្វើការយកចិត្តទុកដាក់ លើការប្រមូលបំណុលដែលបានលុបចោល ពីប្រពន្ធ័ទិន្នន័យ
- ✓ មន្ត្រីឥណទាន ឬប្រធានមន្ត្រីឥណទាន គួរតែរៀបចំនូវ យុទ្ធសាស្ត្រអ្វីមួយដើម្បីរក្សាអតិថិជនល្អៗ ដែលមានស្រាប់អោយបន្តប្រើប្រាស់សេវាកម្មរបស់គ្រឹះស្ថាន
- ✓ គ្រឹះស្ថានគួរតែយកចិត្តទុកដាក់បន្ថែមទៀតក្នុងការជម្រុញអោយប្រព័ន្ធផ្សព្វផ្សាយរបស់ក្រុមហ៊ុនមានប្រសិទ្ធិភាពខ្ពស់
- ✓ គ្រឹះស្ថានគួរតែបន្តស្វែងរកដើមទុនបន្ថែមទៀតដើម្បីពង្រីកតំបន់ប្រតិបត្តិការអាជីវកម្មអោយកាន់តែទូលំទូលាយ ៕

# ឯកសារយោង


១. របាយការណ៍ធនាគារជាតិ នៃកម្ពុជា, ២០១៧, ទំព័រ ।

២. ធនាគារជាតិនៃកម្ពុជា, ច្បាប់ភតិសន្យាហិរញ្ញវត្ថុ,២០០៩, និង ២០១១

៣. ធនាគារជាតិនៃកម្ពុជា, ប្រកាស ឆ្នាំ ២០០២, ចំណាត់ថ្នាក់ និងសំវិធានធនលើឥណទាន

៤. ផែនសុខហេង, របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា ២០១៦, ការគ្រប់គ្រងឥណទានអាជីវកម្ម និងកសិកម្ម

៥. របាយការណ៍សវនកម្មឯករាជ្យ,២០១៦, ទំព័រទី ១០

៦. នាយកដ្ឋានធនធានមនុស្ស, ការបណ្តុះបណ្តាលបុគ្គលិកថ្មីឆ្នាំ ២០១៨, ទំព័រទី ១,២

៧. មន្ត្រីផ្នែកអភិវឌ្ឍផលិតផល, គោលនយោបាយផលិតផល, ២០១៧,ទំព័រ ១២

៨. មន្ត្រីអភិវឌ្ឍន៍ផលិតផល, នីតិវិធីនៃការផ្តល់សេវាភតិសន្យាហិរញ្ញវត្ថុ

៩. មន្ត្រីផ្នែកអភិវឌ្ឍន៍ផលិតផល, នីតិវិធី នៃការដោះស្រាយអតិថិជនមានបញ្ហា

១០. ប្រព័ន្ធអីនធើណែត

- https://www.postkhmer.com/ (03 April 2018)
- https://www.facebook.com/Khemsarithedu/posts/961379903955028 (03 April 2018)
- https://www.professionalacademy.com/blogs-and-advice/marketing-theories---the-marketing-mix---from-4-p-s-to-7-p-s, 20/05/18
- https://www.nbc.org.kh/download_files/legislation/prakas_kh/5028b7-010-172.pdf (២០/០៥/១៨)